ក្រសួងអប់រំ យុវជន និងកីឬា

Ministry of Education Youth and Sport

កម្រងវិញ្ញាសា និងអត្រាកំណែ

ប្រវត្តិវិទ្យា ថ្នាក់ទី១២

ថ្នាក់វិទ្យាសាស្ត្រ និងសង្គម

សម្រាប់ក្លិបសិក្សាគណិតវិទ្យា និងវិទ្យាសាស្ត្រ

ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

រៀបរៀង និងចងក្រងដោយ:

ក្រុមនិស្សិតស្ម័គ្រចិត្តក្រសួងអប់រំ យុវជន និងកីឬា

អារម្ភកថា

សួស្ដី លោកគ្រូ អ្នកគ្រូ ប្អូនៗសិស្សានុសិស្ស និងប្រិយមិត្តអ្នកអានទាំងអស់ជាទីមេត្រី!

សៀវភៅ **កម្រងវិញ្ញាសា និងអត្រាកំណែ ប្រវត្តិវិទ្យាថ្នាក់ទី១២** ដែលលោកគ្រូ អ្នកគ្រូ ប្អូនៗ សិស្សានុសិស្ស និងប្រិយមិត្តកំពុងអាននេះ យើងខ្ញុំបានចងក្រងឡើង ក្នុងគោលបំណងទុកជាឯកសារ សម្រាប់សិស្សានុសិស្សកម្រិតវិទ្យាល័យ ស្វែងសិក្សា យល់ពីគំរូវិញ្ញាសាចាស់ៗ និងដំណោះស្រាយ ដើម្បីជាមូលដ្ឋានក្នុងការសិក្សាអំពី កម្រិតស្ដង់ដាឬកម្រិតវិញ្ញាសាប្រវត្តិវិទ្យាដែលធ្លាប់ចេញក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីងាយស្រួលក្នុងការកំណត់ផ្នែកសំខាន់ៗ ក្នុងមេរៀនដែលត្រូវរៀនដោយយកចិត្តទុកដាក់ និងស៊ីជម្រៅ ។ ម្យ៉ាងទៀត ដើម្បីពង្រឹងសមត្ថភាព ក៏ដូចជាត្រៀមខ្លួនក្នុងការប្រឡង សញ្ញាបត្រមធ្យមសិកស្សាទុតិយភូមិនៅថ្ងៃខាងមុខនេះផងដែរ។ យើងខ្ញុំសូមអធ្យាស្រ័យ ចំពោះកំហុសអចេតនាដែលមាននៅក្នុងសៀវភៅកម្រងវិញ្ញាសានេះ យើងខ្ញុំនឹងរង់ចាំទទួលមតិស្ថាបនាកែលំអបន្ថែម ពីសំណាក់លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត និងអ្នកសិក្សាគ្រប់មជ្ឈដ្ឋានទាំងអស់ដោយក្ដីរីករាយ។

សូមជូនពរដល់អ្នកសិក្សាគ្រប់រូប មានសុខភាពល្អ និងទទួលបានជោគជ័យក្នុងដំណើរជីវិត ហើយខិតខំប្រឹងប្រែងរៀនសូត្រដើម្បីប្រទេសជាតិនៃមាតុភូមិរបស់យើង។

សូមអរគុណ!

ឈ្មោះអ្នករៀបរៀង

១. ធី វិសាល	២. ក. អ៊ំ មិនា
៣. ក. ភឿ សានិត	៤. ក. ផាន់ ស្រីនិ
៥. ខែន រៀម	៦. ថន ពុធដារ៉ូ
៧. ក. ធន នាត	៨. អ៊ំ ប៊ុនណា

៩. អុល ម៉ែងឡាង

មាតិកា

<u>ផ្នែកទី១</u> កម្រងវិញ្ញាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (២០១៤-២០១៩)

១.១. វិញ្ញាសា និងអត្រាកំណែថ្នាក់វិទ្យាសាស្ត្រពិត (២៩១៤ - ២០១៩) ១

១.២. វិញ្ញាសា និងអត្រាកំណែថ្នាក់វិទ្យាសាស្ត្រសង្គម (២០១៤ - ២០១៩) ២៨

<u>ផ្នែកទី២</u> កម្រងវិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

២.២. វិញ្ញាសារត្រៀមប្រឡងមធ្យមសិក្សាទុតិយភូមិថ្នាក់វិទ្យាសាស្ត្រពិត

២.២.១. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រពិតទី១..... ៦៦

២.២.២. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រពិតទី២ ..... ៦៦

២.២.៣. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រពិតទី៣..... ៧២

២.២.៤. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រពិតទី៤..... ៧៦

២.២.៤. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រពិតទី៥..... ៨០

២.២.៤. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រពិតទី៥..... ៨៤

២.៣. វិញ្ញាសារត្រៀមប្រឡង មធ្យមសិក្សាទុតិយភូមិថ្នាក់វិទ្យាសាស្ត្រសង្គម ៩០

២.៣.១. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រសង្គមទី១ ..... ៩១

២.៣.២. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រសង្គមទី២ ..... ៩៥

២.៣.៤. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រសង្គមទី២..... ១០០

២.៣.៤. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រសង្គមទី២..... ១០៥

២.៣.៥. វិញ្ញាសាត្រៀមប្រឡងថ្នាក់វិទ្យាសាស្ត្រសង្គមទី២..... ១១២

ផ្នែកទី៣

ឯកសារពិគ្រោះ

ផ្នែកទី១

ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
សម័យប្រលង ០៤ សីហា ២០១៤
វិញ្ញាសា : ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)
រយៈពេល ៦០នាទី ពិន្ទុ ៥០
ប្រធានៈ

១. តើពិភពលោកកំពុងជួបប្រទះនឹងបញ្ហាធំៗអ្វីខ្លះ ? (១៥ពិន្ទុ)

២.ពណ៌នាអំពីវិនាសកម្មនៅក្រោមរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ និងការស្តាបនាកម្ពុជាឡើងវិញ ។(១៥ពិន្ទុ)

៣.តើការដាក់ប្រសាទព្រះវិហារចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកមានអត្ថន័យដូចម្តេចសម្រាប់កម្ពុជា ? (២០ពិន្ទុ)

អត្ថាកំណែ

១. ពិភពលោកកំពុងជួបប្រទះនឹងបញ្ហាធំៗដូចជា៖

- បរិស្ថាន៖ រញ្ជួយដី ខ្យល់ព្យុះ ទឹកជំនន់ កំណើនកម្តៅ រាំងស្ងួត
- កំណើនប្រជាជន៖ កង្វះការងារ កង្វះអនាម័យ បញ្ហាជំងឺ បញ្ហាសុខភាព
- អន្តោប្រវេសន៍៖ ចំណាក់ស្រុក កើតចលាចល មានបញ្ហាប្រកាន់ជំនឿសាសនាជម្រុះ
- សន្តិសុខស្បៀង៖ ស្បៀងឡើងថ្លៃ បញ្ហាឥទ្ធិពលបដិវត្ត
- ភេរវកម្មអន្តរជាតិ៖ សង្គ្រាម បង្កើតចលាចលសង្គម ការកាប់សម្លាប់ ជួញដូរមនុស្ស គ្រឿងញៀន
- មានមតិត្រឹមត្រូវផ្សេងទៀត ។

២.វិនាសកម្មក្រោយរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ
និងការស្តាបនាកម្ពុជាឡើងវិញមានដូចជា៖

❖ វិនាសកម្មក្រោមរបបប្រល័យពូជសាសន៍៖

- វិស័យសង្គម៖ សម្លាប់រង្គាល បង្អត់អាហារ ធ្វើការជាទម្ងន់ បំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ជម្លៀសប្រជាជនចេញពីទីក្រុងទៅជនបទ ពីតំបន់មួយទៅតំបន់មួយ
- វិស័យវប្ផធម៌៖ បំបាត់សាសារៀន វត្តអារាម ជំនឿសាសនា ទំនៀមទម្លាប់ប្រពៃណី
- ហេដ្ឋារចនាសម្ព័ន្ធ៖ សាលារៀន ផ្លូវថ្នល់ សំណង់សាធារណៈត្រូវខ្ទេចខ្ទាំ
- វិស័យសេដ្ឋកិច្ច៖ បំបាត់ទីផ្សារ រូបិយបណ្ណ ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស កម្មសិទ្ធិឯកជន
- នយោបាយ៖ អនុវត្តនយោបាយផ្តាច់ការ បំភិតបំភ័យ និងសម្លាប់ ព្រមទាំងផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសមួយចំនួនលើពិភពលោក

❖ ការស្តាបនាកម្ពុជាឡើងវិញ៖

- ការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃ ដើម្បីជួយដល់ស្ត្រីមេម៉ាយ ចាស់ជរា កុមារកំព្រា និងគ្មានគោក្របី
- ស្តារចនាសម្ព័ន្ធគ្រប់គ្រង
- ការស្តារវិស័យសេដ្ឋកិច្ច កសិកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្ម
- វប្ផធម៌ អប់រំ៖ បង្កើតសាលារៀនគ្រប់កម្រិតសិក្សា បង្កើតវត្តអារាម ជំនឿសាសនា
- វិស័យនយោបាយ៖ បង្រួបបង្រួមជាតិ ហើយទៅដល់ការបញ្ចប់សង្គ្រាមស៊ីវិល (២៣ តុលា ១៩៩៣)

- មានមតិត្រឹមត្រូវផ្សេងទៀត ។

៣. ការដាក់ប្រាសាទព្រះវិហារក្នុងបេតិកភណ្ឌពិភពលោកបានផ្តល់នូវអត្ថន័យដល់កម្ពុជាដូចជា៖

❖ រក្សាបូរភាពទឹកដី

- ពិភពលោកជួយការពារ និងទទួលស្គាល់ផ្តល់កំណើនសេដ្ឋកិច្ចតាមរយៈទេសចរណ៍
- បង្ហាញពីស្ថាបត្យកម្មនៃបុព្វបុរសខ្មែរ និងសិល្ប:
- បង្ហាញពំអំណាច និងវិសាលភាពរបស់ព្រះរាជាសម័យមុន
- បង្ហាញពីអត្តសញ្ញាណជាតិខ្មែរ
- បង្ហាញពីទេព្យកោសល្យព្រះរាជា និងអាទិទេព
- ជាអត្ថន័យប្រវត្តិសាស្ត្រធ្វើឱ្យជាតិខ្មែរល្បីរន្ធឺពេញពិភពលោក ប្រកបដោយមោទនភាពជាទីបំផុត
- បណ្តុះស្មារតីកូនខ្មែរជំនាន់ក្រោយត្រូវចេះស្រលាញ់គ្នា រក្សា ការពារ
- សម្បត្តិវប្ផធម៌ដ៏ខ្ពង់ខ្ពស់របស់បុព្វបុរស ។
- មានមតិត្រឹមត្រូវផ្សេងទៀត ។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
សម័យប្រលង ២៤ សីហា ២០១៥
វិញ្ញាសា : ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)
រយៈពេល ៦០នាទី ពិន្ទុ ៥០
ប្រធាន:

១. តើកម្ពុជាទទួលឯករាជ្យពីបារាំងនៅឆ្នាំណា ?(៥ពិន្ទុ)
២.តើការទទួលឯករាជ្យនេះមានន័យយ៉ាងដូចម្តេចសម្រាប់កម្ពុជា ? (១០ពិន្ទុ)
៣.ចូរពណ៌នាពីមូលហេតុដែលកម្ពុជាទទួលយកអាណានិគមនិយមបារាំង។ (១០ពិន្ទុ)
៤.ចូរវិភាគពីតម្លៃសន្តិភាពដែលកម្ពុជាទទួលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។(១០ពិន្ទុ)
៥.ចូរបកស្រាយពីតួនាទីនៃ “ វប្បធម៌សន្ធនា” នៅក្នុងសង្គមប្រជាធិបតេយ្យ។ (១៥ពិន្ទុ)

អត្ថាកំណែ

១.កម្ពុជាទទួលឯករាជ្យពីបារាំងនៅឆ្នាំ ១៩៥៣ (០៩ វិច្ឆិកា ១៩៥៣)។

២.ការទទួលឯករាជ្យនេះមានន័យ សម្រាប់កម្ពុជាដូចជា៖

- ការទទួលឯករាជ្យនេះមានសម្រាប់កម្ពុជាដូចជា
- កម្ពុជារួចផុតពីនឹមអាណានិគបារាំង
- កម្ពុជាទទួលបានអធិបតេយ្យភាព បូរណភាពទឹកដី និងឯករាជ្យ
- កម្ពុជាមានសេរីភាព មានសិទ្ធិសម្រេចលើជោគវាសនាខ្លួន
- កម្ពុជារួចផុតពីការគាបសង្កត់ កេងប្រវ័ញ្ច ជិះជាន់ និងការប្រមូលពន្ធជារសព្វសារពើយ៉ាងធ្ងន់ធ្ងរដូចមុន
- អន្តរជាតិទទួលស្គាល់ឯករាជ្យរបស់កម្ពុជា និងមានមុខមាត់លើឆាកអន្តរជាតិ
- មានមតិត្រឹមត្រូវផ្សេងទៀត ។

៣. មូលហេតុដែលបណ្តាលឱ្យកម្ពុជាទទួលយកអាណានិគមបារាំងព្រោះ

- ❖ មូលហេតុនយោបាយ៖
  - ○ សៀម និងយួន គាបសង្កត់ ព្រមទាំងឈ្លានពានកម្ពុជា
  - ○ ខ្មែរយកមហាអំណាចអឺរ៉ុបជាបង្អែក ដើម្បីការពារប្រទេស ពុជសាសន៍ខ្មែរ
  - ○ ធ្វើឱ្យមានឯកភាពអំណាចរាជបល្ល័ង្ក
- ❖ មូលហេតុសេដ្ឋកិច្ច៖
  - ○ បារាំងបើកប្រាក់បៀវត្សរ៍ឱ្យមន្ត្រីរាជការ រាជវង្សានុវង្ស ព្រះមហាក្សត្រខ្ពស់
  - ○ បារាំងជាអ្នកពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ជាអ្នកកាន់កាប់ពន្ធដារ
  - ○ សេដ្ឋកិច្ចខ្មែរធ្លាក់ចុះខ្សោយ និងបិតនៅក្រោមការគាបសង្កត់របស់សៀម និងយួន
- ❖ មូលហេតុសង្គម៖
  - ○ រៀបចំប្រព័ន្ធតុលាការថ្នាក់មូលដ្ឋាន ខេត្ត ក្រុង
  - ○ រៀបចំប្រព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋានខេត្ត ក្រុង
  - ○ ធ្វើឱ្យសង្គមខ្មែរមានស្ថេរភាព
  - ○ មានមតិត្រឹមត្រូវផ្សេងទៀត ។

៤.តម្លៃសន្តិភាពដែលកម្ពុជាទទួលបានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមគឺ

- ❖ តម្លៃសន្តិភាព៖ កម្ពុជាបានសុខសន្តិភាពជៀសផុតពីសង្គ្រាម

- ❖ តម្លៃសេដ្ឋកិច្ច៖
  - ○ ជួយជម្រុញវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ឱ្យមានការអភិវឌ្ឍ
  - ○ ងាយស្រួលក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាង
- ❖ តម្លៃសង្គម៖
  - ○ មានការទប់ស្កាត់សង្គ្រាម និងការទាស់ទែងខ្វែងគំនិតគ្នាក្នុងសង្គម
  - ○ លើកស្ទួយការគោរពសិទ្ធិមនុស្ស សេរីភាព ក្នុងសង្គមប្រជាធិបតេយ្យ
  - ○ ការពារ និងទប់ស្កាត់អំពើពុករលួយ
  - ○ ធ្វើឱ្យរដ្ឋមានលទ្ធភាពសម្រេចផែនការនានាតាមការកំណត់
  - ○ ជួយឱ្យមានសន្តិភាព និងសន្តិសុខសង្គម
  - ○ មានមតិត្រឹមត្រូវផ្សេងទៀត ។

៥. តួនាទីនៃវប្បធម៌សន្ធនាក្នុងសង្គមប្រជាធិបតេយ្យគឺ

- ផ្តល់ប្រយោជន៍ដល់ជាតិធំជាងប្រយោជន៍បុគ្គល
- បញ្ចៀសបានសង្គ្រាមពាក្យសម្តី និងទំនាស់ផ្សេងៗក្នុងសង្គម
- ជាវេទិកាជជែកដេញដោល និងពិភាក្សាឈរលើគោលការណ៍ស្មើភាពគ្នា
- ជាគំរូល្អក្នុងសង្គមជាតិប្រកបដោយភាពជឿជាក់ពីសំណាក់រាស្ត្រ
- មានទំនួលខុសត្រូវលើប្រយោជន៍ក្នុងសង្គមប្រជាធិបតេយ្យ
- បញ្ចៀសរាល់អំពើហិង្សា និងសង្គ្រាម
- ដោះស្រាយបញ្ហាផ្សេងៗ ដោយសន្តិវិធី
  - ផ្តល់នូវភាពស្មោះត្រង់ និងភាពជឿជាក់គ្នាទៅវិញទៅមក
  - បង្កើនសាមគ្គីភាព និងសហប្រតិបត្តិការប្រសើរជាងមុន
  - ពុំមានការគំរាមគំហែងគ្នាទៅវិញទៅមក
  - គោរពគ្នាទៅវិញទៅមកក្នុងភាពថ្លៃថ្នូរ...។
  - មានមតិត្រឹមត្រូវផ្សេងទៀត ។

ប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
សម័យប្រលង ២២ សីហា ២០១៦
វិញ្ញាសា : ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)
រយៈពេល ៦០នាទី ពិន្ទុ ៥០
ប្រធាន:

១.អ្នកប្រាជ្ញខ្មែរឈ្មោះអ្វី ដែលបានរៀបចំវចនានុក្រមខ្មែរ? (៥ពិន្ទុ)
២.តើអាណាព្យាបាលបារាំងពីឆ្នាំ ១៨៦៣-១៩៥៣ មានចំណុចវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះដល់កម្ពុជា? (១០ពិន្ទុ)
៣.ចូរពិពណ៌នាសមិទ្ធផលសង្គមរាស្ត្រនិយមពីឆ្នាំ ១៩៥៣-១៩៧០។ (១០ពិន្ទុ)
៤.ចូរពិពណ៌នាពីមូលហេតុដែលធ្វើឱ្យសង្គ្រាមស៊ីវិលផ្ទុះឡើងពីឆ្នាំ ១៩៧០-១៩៧៥។ (១០ពិន្ទុ)
៥.តើសង្គ្រាមពីឆ្នាំ ១៩៧០-១៩៧៥ មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា? (១៥ពិន្ទុ)

អត្ថាកំណែ

១.អ្នកប្រាជ្ញខ្មែរដែលបានរៀបចំវចនានុក្រមខ្មែរ គឺសម្តេចសង្ឆ ជួន ណាត ។

២.ចំណុចវិជ្ជមាន និងអវិជ្ជមានសម្រាប់ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំងរួមមាន៖

- ចំណុចវិជ្ជមាន៖
  - បារាំងជួយការពារទឹកដី ព្រមទាំងពូជសាសន៍ខ្មែរឱ្យនៅគង់វង្ស
  - បារាំងបានធ្វើឱ្យខ្មែររួចផុតពីនឹមត្រួតត្រា ការឈ្លានពាន របស់សៀម និងយួន
  - បង្កើតសាលាចុងបូព៌ាប្រទេស សម្រាប់សិក្សាស្រាវជ្រាវ និងចងក្រងពីអារិយធម៌ប្រវត្តិសាស្ត្រខ្មែរទុកជាប្រយោជន៍ដល់កូនខ្មែរជំនាន់ក្រោយ
  - បារាំងជួយកំណែទម្រង់រដ្ឋបាល សង្គម និងសេដ្ឋកិច្ចខ្មែរ
  - ជួយកសាងហេដ្ឋារចនាសម្ព័ន្ធ មានសាលារៀន មន្ទីរពេទ្យ ស្ពាន ផ្លូវថ្នល់ជាដើម
  - បារាំងជួយថែរក្សា និងជួសជុលប្រាសាទបុរាណខ្មែរ និងកសាងសារមន្ទីរដើម្បីថែរក្សាវត្ថុបុរាណ
  - ១៩០៤ បារាំងបានទាមទារខេត្តកោះកុង ម្លូព្រៃ និងស្ទឹងត្រែងឱ្យខ្មែរវិញ
  - ១៩០៧ បារាំងបានទាមទារខេត្តសៀមរាប បាត់ដំបង និងសេរីសោភ័ណឲ្យខ្មែរវិញ
  - ១៩០៨ បារាំងបានបង្កើតផែនទីដងរែក
- ចំណុចអវិជ្ជមាន៖
  - បារាំងបានធ្វើឱ្យខ្មែរកាន់តែក្រីក្រ ដោយបារាំងបានធ្វើការដិះជាន់ កេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ
  - បារាំងកេណ្ឌខ្មែរឲ្យទៅជួយច្បាំងស្លាប់របួសជួសបារាំងក្នុងសមរភូមិសង្គ្រាមលើកទាំងពីរលើក
  - បារាំងបានប្រមូលកេតនកណ្ឌខ្មែរទៅស្រុកបារាំង
  - បារាំងបានកាត់ទឹកដីខ្មែរឲ្យទៅសៀមនិងយួន ស្រេចតែចិត្តដូចជា ១៩៤៧ កាត់ខេត្តត្រួតត្រាឲ្យសៀម និង ០៤ មិថុនា ១០៤៩ កាន់ទឹកដីកម្ពុជាក្រោមឱ្យទៅយួន
  - មានមតិត្រឹមត្រូវផ្សេងទៀត ។

៣. ពិពណ៌នាសមិទ្ធផលសម័យសង្គមរាស្ត្រនិយម៖

- វិស័យនយោបាយ៖
  - អនុវត្តនយោបាយអព្យាក្រឹត ធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមានសន្តិភាពអស់រយៈពេល ១៥ ឆ្នាំ (១៩៥៥-១៩៧០) ស្របពេលដែលប្រទេសជិតខាងកំពុងជួបប្រទះនឹងសង្គ្រាម

- ○ កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ១៤ ធ្នូ ១៩៥៥
- ○ ឈ្នះក្តីរឿងក្តីប្រាសាទព្រះវិហារ (១៥ មិថុនា ១៩៦២)

- – វិស័យកសិកម្ម៖
  - ○ ផលិតផលស្រូវ កប្បាស ការចិញ្ចឹមសត្វ ការនេសាទកើនឡើង (ពង្រីកផ្ទៃដីដាំដុះ នយោបាយទឹក ការជ្រើសរើសពូជ)
  - ○ វិស័យឧស្សាហកម្ម៖ កំណើនរោងចក្រ សហគ្រាសដូចជា រោងចក្រក្រដាស រ៉ាយនកណ្ឌ កែវ ស៊ីម៉ង់ត៍ ក្តារបន្ទះ ត្រាក់ទ័រ ស្រាបៀរ រោងចក្រកៅស៊ូ...
  - ○ វិស័យគមនាគមន៍៖ កសាងផ្លូវថ្នល់ ផ្លូវរថភ្លើង ស្ពាន កំពង់ផែ អាកាសយានដ្ឋាន...
- – វិស័យពាណិជ្ជកម្ម៖ មានការរីកចម្រើនផ្នែកពាណិជ្ជកម្មទាំងក្នុងនិងក្រៅប្រទេស
- – ធនាគារ៖ ប្រាក់រៀលក្លាយជារូបិយបណ្ណជាតិ និងមានការកើនឡើងនូវធនាគារជាតិ និងឯកជន
- – វិស័យវប្បធម៌៖
  - ○ បង្កើតសាលារៀននៅទីក្រុងល់ជនបទដូចជា សាលមតេយ្យ ឧត្តមសិក្សាជាដើម
  - ○ គ្រូបង្រៀនមានការកើនឡើង និងបង្កើតអន្តេវាសិកដ្ឋាន
  - ○ កីឡាមានកសាងពហុកីឡាដ្ឋានពីទីក្រុងដល់ជនបទ
- – វិស័យសង្គម ៖ សាសនា វត្តអារាមកើនឡើង និមានការបង្កើត សាលាពុទ្ធិកបឋមសិក្សា ដល់ពុទ្ធិកមហាវិទ្យាល័យ
- – វិស័យសេដ្ឋកិច្ច៖
  - ○ សុខាភិបាលមានការកសាងមន្ទីរពេទ្យជាច្រើន
  - ○ បង្កើតច្បាប់ជាច្រើន ផ្តល់សិទ្ធិឱ្យស្ត្រីបោះឆ្នោត
  - ○ មានមតិត្រឹមត្រូវផ្សេងទៀត។

៤. មូលហេតុដែលឱ្យមានសង្គ្រាមស៊ីវិលផ្ទុះឡើងនៅក្នុងកម្ពុជាឆ្នាំ ១៩៧០-១៩៧៥ ព្រោះ

- – ដោយសារឥទ្ធិពលនៃសង្គ្រាមត្រជាក់
- – ការអនុវត្តនយោបាយអព្យាក្រិតរបស់ព្រះបាទនរោត្តមសីហនុមិនចំទិសដៅ ឬលម្អៀង
- – អំពើពុករលួយបក្សពួកនិយម កុប្បកម្មពេញផ្ទៃប្រទេស
- – មន្ត្រីសម្តេចសីហនុក្បត់នឹងព្រះអង្គ
- – ការជ្រៀតជ្រែករបស់វៀតណាម ចិន សហរដ្ឋអាមេរិកក្នុងនយោបាយខ្មែរ
- – ការបង្កើតរណសិរ្ស្ជួបរួមជាតិកម្ពុជារបស់ព្រះបាទនរោត្តមសីហនុ

- មានមតិត្រឹមត្រូវផ្សេងទៀត ។

៥. ផលវិបាកនៃសង្គ្រាម ១៩៧០-១៩៧៥ មានដូចជា

- វិស័យសង្គម៖
  - សង្គ្រាមបានសម្លាប់ជីវិតមនុស្សជាងមួយលាននាក់
  - បន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា ជនពិការ
  - ប្រជាជនកៀសខ្លួនពីជនបទចូលមកទីក្រុងរស់ដោយទុក្ខវេទនា
  - អំពើពុករលួយ ភាពអយុត្តិធម៌ អនាធិបតេយ្យទូទាំងប្រទេស
  - បំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម
- វិស័យសេដ្ឋកិច្ច៖
  - ដីស្រែចម្ការបោះបង់ចោល ក្លាយជាចម្ការមីន រណ្តៅគ្រាប់បែក
  - រោងចក្រសហគ្រាស ៧៥% ត្រូវបំផ្លិចបំផ្លាញ
  - ចម្ការកៅស៊ូត្រូវបោះបង់ចោល
  - ផ្លូវថ្នល់ ស្ពាន ៧០% ត្រូវអន្តរាយ
  - សេដ្ឋកិច្ចជាតិត្រូវធ្លាក់ចុះ
- វិស័យនយោបាយ៖
  - ប្រទេសជាតិត្រូវបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ កិត្យានុភាព លើឆាកអន្តរជាតិ
  - អស្ថេរភាពនយោបាយ ដោយសង្គ្រាមស៊ីវិលបានបង្កវិនាសកម្មលើគ្រប់វិស័យ
  - ផ្តល់ឱកាសពួកខ្មែរក្រហមឡើងកាន់អំណាច
  - គឺកម្ពុជាធ្លាក់ទៅក្នុងរបបអន្ធកាលនៃអំពើប្រល័យពូជសាសន៍...។
  - មានមតិត្រឹមត្រូវផ្សេងទៀត ។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រឡង ២១ សីហា ២០១៧

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)

រយៈពេល ៦០ នាទី ពិន្ទុ៥០

ប្រធាន

(៥ពិន្ទុ) ១.តើព្រះមហាក្សត្រអង្គណា ដែលបានសម្រេចទាមទារឯករាជ្យពីបារាំង?

(១០ពិន្ទុ)២. តើសង្គ្រាមត្រជាក់ក្នុងទសវត្សឆ្នាំ១៩៥០ និង ១៩៦០ នាំអ្វីខ្លះមកដល់ឧបទ្វីបឥណ្ឌូចិន?

(១០ពិន្ទុ)៣. ចូរពណ៌នាពីកត្តាសំខាន់ៗ ដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរដួលរលំ ?។

(១០ពិន្ទុ)៤ ចូរពណ៌នាពីចលនាតស៊ូរំដោះប្រទេសកម្ពុជា ពីរបបប្រល័យពូជសាសន៍
កម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់១៩៧៩)។

(១០ពិន្ទុ)៥. ចូរពណ៌នាពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលពីឆ្នាំ ១៩៩៣ ដល់ពេលបច្ចុប្បន្ន ។

អត្ថាធិប្បាយ

១.ព្រះមហាក្សត្រអង្គណា ដែលបានសម្រេចទាមទារឯករាជ្យពីបារាំង គឺសម្តេចព្រះនរោត្តមសីហនុ ។

២. សង្គ្រាមត្រជាក់ក្នុងទសវត្សឆ្នាំ១៩៥០ និង ១៩៦០ នាំមកដល់ឧបទ្វីបឥណ្ឌូចិន រួមមាន៖

- ប្រទេសក្នុងតំបន់ឥណ្ឌូចិនទទួលបានឯករាជ្យ
- មានស្វ័យភាពក្នុងការដឹកនាំប្រទេស
- ប្រទេសកម្ពុជាទទួលបានអព្យាក្រឹត្យ
- កម្ពុជាមានស្ថេរភាព និងចូលជាសមាជិកអង្គការសហប្រជាជាតិ
- មានការអភិវឌ្ឍលើគ្រប់វិស័យ
- ការគាបសង្កត់ពីមហាអំណាចសេរី និងកុំម្មុយនីស្ត
- សង្គ្រាមនៅវៀតណាមកើតឡើង
- វៀតណាមបែងចែកជាពីរ (កុំម្មុយនីស្ត និងសេរី)
- ប្រទេសឡាវចែកជាពីរ (កុំម្មុយនីស្ត និងសេរី)
- កម្ពុជាមានទំនាស់ជាមួយប្រទេសជិតខាង
- មានមតិត្រឹមត្រូវផ្សេងទៀត ។

៣. កត្តាសំខាន់ៗ ដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរ(ឆ្នាំ១៩៧០ ដល់១៩៧៥) ដួលរលំ មានដូចជា ៖

- ប្រជាជនតំបន់រំដោះ និងក្រុងភ្នំពេញនឿយណាយនឹងរបបសាធារនរដ្ឋខ្មែរ ដែលប្រកបដោយអមពើពុករលួយ និងភាពអាប់អួរ
- ប្រជាជនកៀសសឹកមកកាន់ភ្នំពេញ ដែលមានការកើនឡើងប្រមាណពីរលាននាក់
- ប្រជាជនរស់នៅដោយឥតការងារធ្វើ និងខ្វះស្បៀងអាហារ
- អតិផរណា (ទំនិញឡើងថ្លៃ ប្រាក់រៀលចុះថោក)

- ការដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវដែលអាមេរិកឧបត្ថម ប្រជាជនក្រុងភ្នំពេញ និងរបបលន់ នល់ ត្រូវបានកាត់ផ្តាច់ទាំងស្រុង
- នៅថ្ងៃទី០១ ខែមេសា លោក លន់ នល់ បានភៀសខ្លួនតាមយន្តហោះចេញពីកម្ពុជា និងទៅរស់នៅសហរដ្ឋអាមេរិក
- ពួកខ្មែរក្រហមធ្វើការតតាំងនឹង ការឡោមពទ្ធ៍ទីក្រុងភ្នំពេញ ពិសេសការនាំចុលស្បៀង
- ការចរចារវាងរបបសាធារណរដ្ឋខ្មែរ និងសម្តេចសីហនុ ពុំទទួលបាននូវ លទ្ធផលអ្វីសោះ
- អាមេរិកបញ្ឈប់ការផ្តល់ជំនួយ
- មានមតិត្រឹមត្រូវផ្សេងទៀត ។

៤ ពណ៌នាពីចលនាតស៊ូរំដោះប្រទេសកម្ពុជា ពីរបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់១៩៧៩)

- នៅខែមករា ឆ្នាំ១៩៧៦ ហូ នឹម បានចេញមុខប្រឆាំង នឹង ប៉ុល ពត
- ដើមខែមីនា ឆ្នាំ១៩៧៦ ប្រជាជននៅចម្ការហ្លួង សៀមរាប ទាមទារឱ្យដំឡើងកម្រិតជីវភាព
- ដើមខែមករា ឆ្នាំ១៩៧៧ ប្រជាជននៅភូមិភាគខាងជើង(ឧត្តរ) និង បាត់ដំបង បានប្រឆាំង ប៉ុលពត
- ដើមខែមីនា និង មេសា ឆ្នាំ១៩៧៧ ប្រជាជន នៅកំពង់ធំ កំពង់ឆ្នាំង មណ្ឌលគិរី និង ចម្ការហ្លួង បានងើបឡើងប្រឆាំង
- នៅឆ្នាំ១៩៧៧ លោក ហ៊ុន សែន បានរត់ទៅប្រទេសវៀតណាម ដើម្បីបង្កើតទ័ព ប្រឆាំងនឹង ខ្មែរក្រហម
- ថ្ងៃទី០២ ធ្នូ ឆ្នាំ១៩៧៨ មានមហាសន្និបាទ សម្រេចបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលដឹកនាំដោយលោក ហេង សំរិន
- មានជំនួយពីវៀតណាម និងប្រជាជនកម្ពុជា

- ក្នុងរយៈពេលបីសប្តាហ៍ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និង កងទ័ពរំដោះបានប្រជាជនស្ទើរតែទាំងស្រុង
- ថ្ងៃ០៧ មករា ឆ្នាំ ១៩៧៩ ប្រជាជនខ្មែរបានរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម
- មានមតិត្រឹមត្រូវផ្សេងទៀត ។

៥. សមិទ្ធផលរបស់រាជរដ្ឋាភិបាលពីឆ្នាំ ១៩៩៣ ដល់ពេលបច្ចុប្បន្ន មានដូចជា៖

❖ ក្នុងប្រទេស

- អនុវត្តនយោបាយឈ្នះ ឈ្នះ (ដោយរំលាយអង្គការចាត់តាំងរបស់ខ្មែរក្រហម និងធ្វើសមាហណកម្ម កងកម្លាំងខ្មែរក្រហម ឱ្យចូលមករួមរស់ជាមួយរដ្ឋាភិបាលនៅឆ្នាំ ១៩៩៨ និងបាននាំមកនូវសន្តិភាពនិយកម្មមកកម្ពុជា)
- រៀបចំការបោះឆ្នោតដោយខ្លួនឯង ប្រកបដោយជោគជ័យទៅតាមលទ្ធិប្រជាធិបតេយ្យ
- ធ្វើកំណែទម្រង់គ្រប់វិស័យ (អប់រំ សេដ្ឋកិច្ច រដ្ឋបាល តុលាការ និង កងកម្លាំងប្រដាប់អាវុធ)
- កម្ពុជាប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីបហុបក្ស
- រាជរដ្ឋាភិបាលបានអនុវត្តនយោបាយ យុទ្ធសាស្ត្រ (ត្រីកោណ និង ចតុកោណ)
- មានមតិត្រឹមត្រូវផ្សេងទៀត ។

❖ នយោបាយក្រៅប្រទេស

- កម្ពុជាក្លាយជាសមាជិកអាស៊ាន (ស្មើមុខមាត់ជាមួយបណ្តាប្រទេសក្នុងតំបន់)
- កម្ពុជាបានចូលជាសមាជិក WTO និងអង្គការនានា ...
- ចូលរួមថែរក្សាសន្តិភាពពិភពលោក (កងទ័ពមួកខៀវ)
- ធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំអាស៊ាន
- មានមតិត្រឹមត្រូវផ្សេងទៀត

❖ ផ្នែកសេដ្ឋកិច្ច

– វិស័យកសិកម្ម មានការរីកចម្រើន ដោយរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ក្នុងការបង្កើតប្រពន្ធ័ធារាសាស្ត្រ ការបង្កាត់ពូជ

– អនុវត្តសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាបានក្លាយជាកន្លែងវិនិយោគដ៏ទាក់ទាញ

– វិស័យឧស្សាហកម្មមានការរីកចម្រើន ផ្នែករោងចក្រសហគ្រាស

– ការធ្វើពាណិជ្ជកម្មមានភាពងាយស្រួល

– ប្រជាជនមានការងារធ្វើយ៉ាងទូលំទូលាយ ទាំងក្នុងប្រទេស និងតំបន់

– សេដ្ឋកិច្ចមានកំណើនខ្ពស់ក្នុងរយៈពេលវែង និងមានចំណូលកើនឡើងជាប្រចាំ

– មានកំណើនទេសចរ ដែលធ្វើឱ្យសេដ្ឋកិច្ចកើនឡើង ប្រជាជនមានការងារធ្វើ

– មានការកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ស្ពានអាកាស ផ្លូវថ្នល់ និង អាកាសយានដ្ឋាន

❖ វិស័យអប់រំ វប្បធម៌

– កសាងសាលារៀន ពីទីក្រុងដល់ជនបទដាច់ស្រយាល (ចំណេះដឹង អាហារូបករណ៍ សម្រាប់និស្សិត និង លើកតម្កើនឱ្យសិស្សរៀនបានខ្ពស់

– បង្កើត និងជួសជុលកីឡាដ្ឋានជាតិ បណ្តុះបណ្តាលជំនាញ កីឡាករទទួលបានមេដាយមាស ប្រាក់ សំរិទ្ធ លើឆាកអន្តរជាតិ

– អភិរក្សសម្បត្តិវប្បធម៌ ទាំងរូបី និង អរូបី

– មានមតិត្រឹមត្រូវផ្សេងទៀត

❖ ផ្នែកសង្គមកិច្ច

– កម្ពុជាទទួលបានកិច្ចសហការ ជាមួយប្រទេសក្នុងតំបន់ និងពិភពលោក ក្នុងការថែរក្សាសន្តិភាព និងសន្តិសុខសង្គម ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និង អំពើកេរវកម្ម

– មានការកសាងមណ្ឌលសុខភាព មន្ទីរពេទ្យនៅតាមឃុំសង្កាត់ ស្រុក ខណ្ឌ

- មានសេរីភាពសារពត៌មាន និងអនុញ្ញាតឱ្យមានសិទ្ធសេរីភាពក្នុងការបង្កើតអង្គការសង្គមស៊ីវិល
- មានសមភាពយេនឌ័រ
- មានការជួយគ្នាទៅវិញទៅមក រវាងប្រទេសសមាជិក តាមរយៈការផ្ទេរបទពិសោធន៍
- មានមតិត្រឹមត្រូវផ្សេងទៀត

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រឡង ២០ សីហា ២០១៨

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)

រយៈពេល ៦០ នាទី ពិន្ទុ៥០

ប្រធាន

(៥ពិន្ទុ)១. តើអ្នកនយោបាយខ្មែររូបណា ដែលបានបញ្ចប់សង្គ្រាមក្នុងស្រុកឆ្នាំ ១៩៩៨?

(១០ពិន្ទុ)២. តើអាណាព្យាបាលបារាំង បាននាំអ្វីខ្លះមកដល់កម្ពុជា?

(១០ពិន្ទុ)៣. ចូរពណ៌នាពីកត្តាសំខាន់ៗ ដែលនាំឱ្យកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់១៩៧៩) ដួលរលំ ?

(១០ពិន្ទុ)៤.ចូរពណ៌នាពីតួនាទី របស់សហគមន៍អាស៊ាននៅអាស៊ីអាគ្នេយ៍។

(១៥ពិន្ទុ)៥. តើសន្តិភាពដែលសម្រេចបានចាប់ពីឆ្នាំ ១៩៩៨ បាននាំអ្វីខ្លះ មកដល់កម្ពុជា?

អត្ថាកំណែ

១. អ្នកនយោបាយខ្មែរដែលបានបញ្ចប់សង្គ្រាមក្នុងស្រុកឆ្នាំ ១៩៩៨ គឺសម្តេចអគ្គមហាសេនាបតី ហ៊ុន សែន ។

២. អាណាព្យាបាលបារាំង បាននាំមកដល់កម្ពុជា

- ❖ លទ្ធផលវិជ្ជមាន
  - – ការពារទឹកដី និងពូជសាសន៍ខ្មែរឱ្យនៅគង់វង្ស
  - – កែទម្រង់សង្គមខ្មែរ ប្រពន្ធ័ច្បាប់តុលាការ រដ្ឋបាល ពន្ធដារ ការចុះបញ្ជីអប់រំ ...សិក្សាធិការ ឱ្យមានលក្ខណៈប្រសើរជាងមុន
  - – សិក្សាស្រាវជ្រាវ ចងក្រង អារិយធម៌ ប្រវត្តិសាស្ត្រខ្មែរ និងធ្វើការផ្សព្វផ្សាយទៅលើឆាកអន្តរជាតិ និងជួយជួសជុលប្រាសាទខ្មែរ ឱ្យគង់វង្ស តាមរយៈសាលាចុងបូព៌ា
  - – សាងសង់ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ និង សមិទ្ធផលផ្សេងៗទៀត
  - – ទាមទារយកខេត្តខ្មែរពីសៀមវិញ ដូចជា
    - ▪ ខេត្តស្ទឹងត្រែង ១៨៩៣
    - ▪ ខេត្តត្រាត កោះកុង ម្លូរព្រៃ ទន្លេរពៅ នៅឆ្នាំ១៩០៤
    - ▪ ខេត្តសៀមរាប បាត់ដំបង សេរីសោភណ ឆ្នាំ១៩០៧
    - ▪ គូរផែនទីដងរែកឆ្នាំ ១៩០៨សម្រាប់ជាប្រយោជន៍ដល់ខ្មែរ
- ❖ លទ្ធផលអវិជ្ជមាន
  - ○ ជំរិតទារពន្ធយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យប្រជាជនខ្មែរកាន់តែក្រីក្រ និងធ្វើឱ្យមានគម្លាតរវាងអ្នកមាន និងអ្នកក្រ អ្នកទីក្រុង និងជនបទ
  - ○ កេណ្ឌប្រជាជនខ្មែរឱ្យទៅច្បាំង ក្នុងសង្គ្រាមលោកទាំងពីរលើក

- ○ ប្រមូលយកកេតនកណ្ឌ និងសម្បត្តិមានតម្លៃយកទៅស្រុកបារាំង
- ○ កាត់ទឹកដីខ្មែរឱ្យសៀម និង យួនស្រេចតែចិត្ត ដូចជា ៖
  - ▪ ១៩០៧ កាត់ខេត្តត្រាតឱ្យសៀម
  - ▪ ៣១ មករា ១៩៣៩ បារាំងដាក់បញ្ចូលកោះត្រល់ក្នុងដែនរដ្ឋបាល កូសាំងស៊ីន
  - ▪ ០៤ មិថុនា ១៩៤៩ បារាំងកាត់ដែនដីកូសាំងស៊ីន (កម្ពុជាក្រោម) ឱ្យទៅមហាអំណាចវៀតណាម ។
  - ▪ មានមតិត្រឹមត្រូវផ្សេងទៀត ។

(១០ពិន្ទុ)៣. កត្តាដែលនាំឱ្យកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥ ដល់១៩៧៩) ដួលរលំ មាន៖

- – ការស្អប់ខ្ពើមរបប ប៉ុល ពត របស់ប្រជាជនកម្ពុជា ព្រោះរបបនេះបាន
  - ○ ធ្វើទារុណកម្ម និងបានកាប់សម្លាប់ប្រជាជន
  - ○ បង្ខំឱ្យមនុស្សធ្វើការជាទម្ងន់ សុខភាពទ្រុឌទ្រោម និងបាក់កម្លាំង
  - ○ កង្វះអាហារ កង្វះសម្លៀកបំពាក់ គ្មានថ្នាំព្យាបាល រងចាំតែក្តីស្លាប់ `
  - ○ បំបិទសិទ្ធសេរីភាព ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់
- – ការសម្រិតសម្រាំងយកមនុស្សបដិវត្តបរិសុទ្ធ
  - ○ នៅពាក់កណ្តាលឆ្នាំ១៩៧៦ មានការសម្រិតសម្រាំង យកមនុស្សបដិវត្តបរិសុទ្ធ ក្នុងចំណោមសមាជិកសំខាន់ៗ ក្នុងបក្សកុំម្មុយនីស្តកម្ពុជា
  - ○ ការសម្រិតសម្រាំង យកមនុស្សបដិវត្តបរិសុទ្ធ ក្នុងចំណោមសមាជិកសំខាន់ៗ ក្នុងបក្សកុំម្មុយនីស្តកម្ពុជា បានធ្វើឱ្យបែកបាក់ផ្ទៃក្នុង ពិសេសជួរអ្នកដឹកនាំ
- – ការធ្វើសង្គ្រាមជាមួយវៀតណាម
  - ○ ចាប់ពីឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យ ចាប់ផ្តើមបង្កជម្លោះនៅតាមព្រំដែន ជាមួយប្រទេសវៀតណាមដោយពុំប្រមាណកម្លាំងរបស់ខ្លួន (កងទ័ពខ្មែរក្រហមមានចំនួនតិច

យុទ្ធសាស្ត្រធ្វើសង្គ្រាមខ្សោយ តែកងទ័ពវៀតណាម មានអាវុធទំនើប និងយុទ្ធសាស្ត្រធ្វើសង្គ្រាមពូកែ)

- ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា
  - នៅថ្ងៃទី០២ ធ្នូ ១៩៧៨ ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្កើតឡើងដែលមានបំណងផ្ដួលរំលំ របបកម្ពុជាប្រជាធិបតេយ្យ
  - ថ្ងៃទី២៥ ធ្នូ ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្មគ្រ័ចិត្តវៀតណាម បានបើកការវាយប្រហារលើកម្ពុជាប្រជាធិបតេយ្យ រហូតបានជោគជ័យនៅថ្ងៃទី០៧ មករា ឆ្នាំ១៩៧៩
  - មានមតិត្រឹមត្រូវផ្សេងទៀត .។

៤.តួនាទី របស់សហគមន៍អាស៊ានៅអាស៊ីអាគ្នេយ៍ មានដូចជា ៖

- ផ្នែកនយោបាយ
  - រក្សាសន្តិសុខ សន្តិភាព ក្នុងតំបន់ និងអន្តរជាតិ
  - ចូលរួមដោះស្រាយវិវាទ ឬជម្លោះក្នុងតំបន់ និងអន្តរជាតិ
  - ធ្វើឱ្យមានឯកភាពក្នុងការដឹកនាំ ស្របតាមលទ្ធិប្រជាធិបតេយ្យ
- ផ្នែកសេដ្ឋកិច្ច
  - ជម្រុញការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក
  - ជម្រុញកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម និងការអភិវឌ្ឍទីផ្សារដើម្បីប្រកួតប្រជែងជាមួយប្រទេសជឿនលឿន
  - បង្កើនកិច្ចសហប្រតិបត្តិការ លើផ្នែកទេសចរណ៍ ដើម្បីបង្កើនការងារ និងប្រាក់ចំណូលដល់ប្រជាជន
- ផ្នែកសង្គម

- ○ ជម្រុញកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ ជំនឿ សាសនា និង ប្រពៃណីទំនៀមទម្លាប់
- ○ ផ្លាស់ប្តូរបទពិសោធន៍ ផ្នែកអប់រំសិក្សាធិការ ការបណ្តុះបណ្តាលធនធានមនុស្ស បច្ចេកវិទ្យា វិទ្យាសាស្ត្រ
- ○ លើកកម្ពស់សិទ្ធមនុស្ស និងសមភាពយេនឌ័រក្នុងតំបន់
- ○ បង្កើតទមនាក់ទំនងល្អៗជាមួយប្រជាជាតិនានាក្នុងតំនប់ និងពិភពលោក
- ○ មានមតិត្រឹមត្រូវផ្សេងទៀត ។

៥. សន្តិភាពដែលសម្រេចបានចាប់ពីឆ្នាំ ១៩៩៨ បាននាំមកដល់កម្ពុជា លើគ្រប់វិស័យដូចជា៖

❖ វិស័យនយោបាយ

- ○ នយោបាយក្នុងប្រទេស
  - • កម្ពុជាទទួលបានសុខសន្តិភាព និងស្ថេរភាពនយោបាយ
  - • មានការបោះឆ្នោតជ្រើសរើសមេដឹកនាំ
- ○ នយោបាយក្រៅប្រទេស
  - • ១៩៩៩ កម្ពុជាបានក្លាយជាសមាជិកអាស៊ាន
  - • ២០០៤ ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក
  - • ២០១២ កម្ពុជាបានធ្វើជាប្រធានអាស៊ាន
  - • កម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់ និងក្នុងពិភពលោក

❖ វិស័យសេដ្ឋកិច្ច

- • កសិកម្ម មានកំណើនទិន្នផលកសិកម្មព្រោះសំបូរទីផ្សារ
- • ឧស្សាហកម្ម កំណើនរោងចក្រ សហគ្រាស .....
- • ពាណិជ្ជកម្ម សំបូរវិនិយោគគិន សំបូរទីផ្សារ

- ទេសចរណ៍ បង្កើនភ្ញៀវទេសចរ បង្កើនការងារនិងប្រាក់ចំណូល ដល់ប្រជាជន
- ហិរញ្ញវត្ថុ ស្ថិរភាពអត្រាប្តូរប្រាក់
- គមនាគមន៍ មានការសាងសង់ស្ពាន ផ្លូវពីទីក្រុងដល់ជនបទ ដោយមានប្រពន្ធ័ទឹកភ្លើង និងមានកំណើនសេដ្ឋកិច្ចរាល់ឆ្នាំ

❖ វិស័យសង្គម

○ វិស័យអប់រំ មានសាលារៀនគ្រប់កម្រិត គ្រប់ទីកន្លែង និងមានធនធានមនុស្ស

○ វប្បធម៌ គាស់កកាយវប្បធម៌ឱ្យរស់ឡើងវិញ ដាក់បញ្ចូលសម្បត្តិវប្បធម៌ ជាបេតិកភណ្ឌពិភពលោក

○ សុខដុមរមនាក្នុងសាសនា

○ សុខាភិបាល មានការបង្កើតមន្ទីរពេទ្យ មណ្ឌលសុខភាព ពីទីក្រុងដល់ជនបទ

○ ផ្តល់សិទ្ធិដល់ស្ត្រី (សមភាពយេនឌ័រ)

○ មានមតិត្រឹមត្រូវផ្សេងទៀត .។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រឡង ២០ សីហា ២០១៩

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)

រយៈពេល ៦០ នាទី ពិន្ទុ៥០

ប្រធាន

១.ចូររៀបរាប់ពីមេដឹកនាំខ្មែរក្រហមសំខាន់ៗចំនួន ៥រូប ។ (៥ពិន្ទុ)

២. ចូរអ្នកពណ៌នាពីចលនាតស៊ូរបស់កម្ពុជា ដើម្បីទទួលបានឯករាជពីបារាំង ។ (១០ពិន្ទុ)

៣. ចូរអ្នកពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។(១០ពិន្ទុ)

៤. មូលហេតុអ្វីបានជាមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តសីហនុ ឆ្នាំ១៩៧០ ? រដ្ឋប្រហារនេះ
មានផលវិបាកអ្វីខ្លះដល់កម្ពុជា ? (១៥ពិន្ទុ)

អត្ថាកំណែ

១. មេដឹកនាំសំខាន់ៗមានដូចជា សាឡុត ស (ប៉ុល ពត), ន្ជន ជា, ខៀវ សំផន, អៀង សារី, សុន សេន, អៀង ធារិទ្ធ, វន វ៉ែត , សោ ភឹម, ឈិត ជឿន .....។

២. ចលនាតស៊ូរបស់កម្ពុជា ដើម្បីទទួលបានឯករាជពីបារាំង មាន ៖

- ការតស៊ូដោយហឹង្សា ៖ គឺជាចលនាដោយប្រើអាវុធ ប្រយុទ្ធបង្ហូរឈាម ដើម្បីទាមទារឯករាជ្យ ដោយចលនាតស៊ូរបស់ខ្មែរឥស្សរៈ ដែលក្រុមនេះបានពង្រីកក្រុមខ្លួន ទូទាំងប្រទេស
- ការតស៊ូដោយអហឹង្សា ៖ គឺជាចលនាតស៊ូដោយសន្តិវិធី តាមរយៈមធ្យោបាយការទូត ពោលគឺធ្វើតាមរយៈនយោបាយក្រៅប្រទេស ជាមួយបារាំង កាណាដា សហរដ្ឋអាមេរិក ថៃ តាមរយៈនយោបាយការទូត និង ការសែត។
- ព្រះបាទនរោត្តម សីហនុ បានមានព្រះបន្ទូលថា «បើបារាំងមិនព្រមប្រគល់ឯករាជ្យឱ្យកម្ពុជាទេ នោះកម្ពុជាក្លាយជាប្រទេសកុម្មុយនីស្ត»
- សកម្មភាពខាងក្នុងប្រទេសព្រះអង្គបានគង់នៅតំបន់ស្វយ័តក្នុងខេត្តសៀមរាប បាត់ដំបង កំពង់ធំ ដោយមិនយាងមកភ្នំពេញ ហើយទ្រង់បានបង្កើតកងជីវពលនារីក្លាហាន ដើម្បីឱ្យប្រជារាស្ត្រក្រោកឈរឡើងទាមទារឯករាជ្យបរិបូរណ៍។

៣. ចូរពណ៌នាពីរបបសាធារណៈប្រជាមានិតកម្ពុជា

- អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិត្យកម្ពុជាគ្រប់គ្រងដោយបក្សតែមួយគឺ គណបក្សប្រជាជនបដិវត្តន៍កម្ពុជា និងមានអង្គការគ្រប់គ្រងសំខាន់ៗ៤គឺ ៖
  - គណបក្សប្រជាជនបដិវត្តន៍កម្ពុជា
  - ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រី
  - ក្រុមប្រឹក្សារដ្ឋ
  - រដ្ឋសភាជាតិ
- រដ្ឋអំណាចខ្មែរ:
- ដំណាក់កាលដំបូង: ក្រសួងសំខាន់ៗគ្រប់គ្រង ដោយមនុស្សពីរក្រុមគឺ អ្នកតស៊ូចាស់ៗនៅតាមភូមិភាគបូព៌ា(សមមិត្ត ហេង សំរិន, ជាស៊ីម, ហ៊ុន សែន)

និងអ្នករៀននៅវៀតណាម ក្រោយសន្និសីទទីក្រុងហ្ស៊ីណែវ ឆ្នាំ១៩៥៤ (សមមិត្ត ប៉ែន សុវណ្ណ, និង ចាន់ ស៊ី)

– ដំណាក់កាលបន្ទាប់: ពេលប្រទេសមានសន្តិសុខ មានលំនឹងរដ្ឋាភិបាលជ្រើសរើសអ្នកមានសមត្ថភាពឱ្យបម្រើក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ។

- **ជំនាញការ និងកងទ័ពវៀតណាម:**
  - អ្នកជំនាញវៀតណាម: អមរដ្ឋអំណាចខ្មែរទាំងពីថ្នាក់ក្រសួងដល់ថ្នាក់មូលដ្ឋាន ដើម្បីជួយពង្រឹងរដ្ឋបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា
  - កងទ័ពវៀតណាម: នៅពេញផ្ទៃប្រទេសកម្ពុជា ដើម្បីជួយទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា(០៧ មករា ១៩៧៩- ៣០ មេសា ១៩៨៩) មានការកិច្ចចាំបាច់ពីរគឺ ការកសាងសន្តិភាព និងការស្តារបនាជាតិឡើងវិញ។

- **កិច្ចការពារជាតិ:**ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញរបស់ខ្មែរក្រហម

រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចាត់វិធានការដូចតទៅ៖

  – ការបង្កើតកងសេនាជនតាមភូមិ
  – បង្កើតក្រុមស្វ័យការពារ ក្រុមយាមកាម
  – ធ្វើការជ្រើសកងទ័ព
  – បង្កើតកាតព្វកិច្ចយោធា
  – ធ្វើការហ្វឹកហ្វឺន ហ្វឹកហាត់ ក្បួនយោធាដល់សិស្ស និស្សិត មុនចូលរៀន
  – លើកទ័ពវាយប្រហារលើកងទ័ពខ្មែរក្រហមនារដូវប្រាំង និងធ្វើការគ្រប់គ្រងតាមតំបន់ព្រំដែន
  – បង្កើតការការពារនៅតាមព្រំដែនកម្ពុជាខ្មែរ- ថៃ ដោយបានអនុវត្តផែនការ «ក ៥» កេណ្ឌកងកម្លាំងកាប់ឆ្ការព្រៃការពារព្រំដែនកម្ពុជា)
  – ស្វែងរកការចរចារបញ្ចប់សង្គ្រាម

☞ **ការកសាងជាតិ: រដ្ឋាភិបាលបានរៀបចំកសាងជាតិដូចជា៖**

☞ **ការស្តារបនាសេដ្ឋកិច្ច:** បញ្ហាបន្ទាន់គឺ បញ្ហាស្បៀង ដូចនេះរដ្ឋាភិបាលបាន៖

  – អំពាវនាវសុំជំនួយពីសហគមន៍អន្តរជាតិ
  – បង្កើតក្រុមសាមគីបង្ករបង្កើនផលឆ្នាំ ១៩៨៣ ដល់ ១៩៨៦ ប្តូរពីក្រុមសាមគីបង្ករបង្កើនផលទៅជាម្ចាស់ការទាំងស្រុង ដោយបានធ្វើការចែកដីធ្លី
  – និងឈានទៅរកកម្មសិទ្ធឯកជនអនុវត្តមុខព្រួញទាំង ៤នៃសេដ្ឋកិច្ច

☞ **ការស្តារបនាសង្គម:**

– **វិស័យអប់រំ**: ប្រព័ន្ធអប់រំត្រូវបានស្តារឡើងវិញដោយ៖
– បើកទ្វារសាលាទទួលសិស្ស និស្សិតឱ្យចូលរៀន
– ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន
– ជំរុញចលនាអក្ខរកម្ម និងបំពេញវិជ្ជា
– អនុវត្តនយោបាយ «អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកអត់ចេះ»
– បញ្ជូននិស្សិតទៅសិក្សានៅបរទេស
– **វិស័យវប្បធម៌:**
* បើកសេរីភាពដល់ជំនឿ សាសនា ប្រពៃណីទំនៀមទំលាប់
* បើកទ្វារសាលាវិចិត្រសិល្ប: និងប្រមូលផ្តុំសិល្បករ
– **វិស័យសង្គម:**
* បង្កើតមជ្ឈមណ្ឌលកុមារកំព្រា
* បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវ: សម្រាប់ជនពិការ និងស្ត្រីមេម៉ាយ
* បង្កើតច្បាប់ការពារកម្មសីទឯកជន(១៩៨៧)
– **វិស័យសុខាភិបាល:**
* បើកទ្វារមន្ទីពេទ្យ ទទួលពិនិត្យ និងព្យាបាលជំងឺ
* បើកទ្វារសាលាបណ្តុះបណ្តាលពេទ្យ មានមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តសាស្ត្រ

៤. មូលហេតុ និងផលវិបាកនៃរដ្ឋប្រហារឆ្នាំ១៩៧០

❖ **ហេតុដែលនាំឲ្យមានរដ្ឋប្រហារឆ្នាំ១៩៧០:** មុនរដ្ឋប្រហារប្រទេសកម្ពុជាជួបនូវវិបត្តិសង្គម សេដ្ឋកិច្ច នយោបាយយ៉ាងធ្ងន់ធ្ងរ ដែលមិនអាចដោះស្រាយបានដូចជា៖

• **វិបត្តិសង្គម:**
– ការបែកបាក់សាមគ្គីជាតិទៅតាមមនោគមន៍វិជ្ជាដែលសាបព្រួសដោយអ្នកនយោបាយ(ខ្មែរក្រហម ខ្មែរខៀវ ខ្មែរស)
– សង្គមជួបនូវអំពើពុករលួយ បក្សពួកនិយម អនាធិបតេយ្យ អយុត្តិធម៌ ចោរកម្ម

- ប្រជាជនរស់នោតាមព្រំដែនកម្ពុជា វៀតណាមរងនូវការទម្លាក់គ្រាប់បែកពីសហរដ្ឋអាមេរិកយ៉ាងខ្លាំង
- ភាពចលាចល បាតុកម្ម កុប្បកម្មប្រឆាំងនឹងវត្តមានប្រជាជន និងកងទ័ពវៀតណាមកាន់តែច្រើនឡើងលើទឹកដីកម្ពុជា

- **វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**: សេដ្ឋកិច្ចជាតិធ្លាក់ចុះយ៉ាងខ្លាំងដើបលែងរួចដោយ៖
  - ការធ្វើជាតិតូបនីយកម្មបានធ្វើឱ្យធនាគារឯកជន ក្រុមហ៊ុនឯកជនត្រូវបិទទ្វារ ប្រជាជនអត់ការងារធ្វើ
  - រដ្ឋបាត់បង់នូវប្រាក់ចំណូល ដោយសារទំនិញគេចពន្ធ អំពើពុករលួយ និងការបដិសេធជំនួយពីសហរដ្ឋអាមេរិក
  - ការចំណាយ និងចំណូលខ្វះតុល្យភាព
  - ទំនិញឡើងថ្លៃ អតិផរណាក្រដាសប្រាក់ សេវាដឹកជញ្ជូនត្រូវរាំងស្ទះ
- **វិបត្តិនយោបាយ**: ឥទ្ធិពលនៃសង្គ្រាមត្រជាក់បានបណ្តាលឱ្យកើតមានបញ្ហាដូចជា៖
  - ការអនុវត្តគោលនយោបាយអព្យាក្រឹត្យមិនចំទិសដៅនិងបានលូកដៃចូលក្នុងសង្គ្រាមវៀតណាម
  - អ្នកនយោបាយខ្មែរបែកបាក់សាមគីជាតិ គិតតែកអំណាច គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន
  - អ្នកនយោបាយខ្លះទៀតរៀបចំផែនការក្បត់សម្តេច នរោត្តម សីហនុ
  - មានការផ្លាស់ប្តូររដ្ឋាភិបាលញឹកញាប់ពេក(ពីរដ្ឋាភិបាលសំណាងចុងក្រោយទៅរដ្ឋាភិបាលស្រោចស្រង់ជាតិ)
  - ខ្មែរក្រហមបានពង្រឹងកម្លាំងនៅតាមភូមិភាគឥសាន្ត ឧត្តរ ពាយ័ព្យ ហើយបានវាយប្រហារលើរបបសង្គមរាស្ត្រនិយម ព្រមទាំងបានគ្រប់គ្រងទឹកដីបានមួយចំនួន
  - រដ្ឋាភិបាលពុំអាចទប់ស្កាត់ការបះបោររបស់ប្រជាជនប្រឆាំងនឹងវត្តមានប្រជាជន និងកងទ័ពវៀតណាមកាន់តែច្រើនលើទឹកដីកម្ពុជា

មូលហេតុខាងលើនេះហើយបណ្តាលឱ្យមានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ចេញពីប្រមុខរដ្ឋនាថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០។

❖ ផលវិបាកនៃរដ្ឋប្រហារឆ្នាំ ១៩៧០: រដ្ឋប្រហារពុំបាននាំឱ្យប្រទេសកម្ពុជាឈានទៅរកដំណោះស្រាយ និងភាពចម្រុងចម្រើននោះទេ មានតែនាំមកនូវសង្គ្រាមស៊ីវិល ការបាត់បង់ ការខូចខាត និងភាពវិនាសកម្មដូចជា៖

- **ខាងសង្គម**:

  - ការបែកបាក់ជាតិបាតុកម្ម កូដកម្ម កុប្បកម្ម ដែលបង្កនូវភាពច្របូកច្របល់ភាពអនាធិបតេយ្យទូទាំងប្រទេស
  - ប្រជាជានរងទុក្ខវេទនា ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង រងគ្រោះទ្ឆ្ពិក្ស
  - ប្រជាជនរស់នៅប្រឈមមុខនឹងមនោគមន៍វិជ្ជានៃសង្គ្រាមត្រជាក់ សឹកសង្គ្រាម និងការទម្លាក់គ្រាប់បែក
  - ប្រជាជនមួយចំនួនបានរត់ចូលព្រៃតាមការអំពាវនាវរបស់សម្តេចនរោត្តម សីហនុ ឯខ្លះទៀតរត់ភៀសខ្លួនទៅកាន់ទីក្រុងភ្នំពេញ រស់នៅដោយខ្វះអាហារ និងអត់មានការងារធ្វើ
- **ខាងសេដ្ឋកិច្ច**: រដ្ឋប្រហារធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាជាប់គាំងដោយ៖
  - ដីស្រែចំការទុកទំនេរចោល ទិន្នផលធ្លាក់ចុះ
  - រោងចក្រសហគ្រាសត្រូវបានបិទទ្វារ
  - ទំនិញឡើងថ្លៃ អតិផរណាសាច់ប្រាក់
- **ខាងនោបាយ**:
  - កម្ពុជាបាត់បង់កេរ្តិ៍ឈ្មោះ កិត្តិយសលើឆាកអន្តរជាតិ
  - អស្ថេរភាពខាងផ្នែកនយោបាយធ្វើឱ្យប្រជាជនបាត់បង់នូវជំនឿលើមេដឹកនាំ
  - កម្ពុជាបាត់បង់ឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី
  - មានការផ្លាស់ប្តូររបបនយោបាយជាការបើកផ្លូវឱ្យខ្មែរក្រហមឡើងកាន់អំណាច ដែលនាំកម្ពុជាទៅរកការកាន់កាប់របបប្រល័យពូជសាសន៍
  - មានចម្លើយត្រឹមត្រូវផ្សេងទៀត។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រឡង ០៤ សីហា ២០១៤ (លើកទី១)

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)

រយៈពេល ៩០ នាទី ពិន្ទុ៧៥

ប្រធាន

(២៥ពិន្ទុ) ១. ពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមាននៃសាកលភាវូបនីយកម្ម ។

(២៥ពិន្ទុ)២.តើព្រះបាទនរោត្តមសីហនុ និង សម្តេចហ៊ុន សែន មានតួនាទីអ្វីខ្លះ ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា ?

(២៥ពិន្ទុ)៣. តើអាស៊ានជាអ្វី ? ហើយមានសារៈសំខាន់អ្វីខ្លះសម្រាប់កម្ពុជា ?

អត្ថាធិប្បាយ

១. ពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមាននៃសាកលភាវូបនីយកម្ម៖

❖ ទិដ្ឋភាពវិជ្ជមាន នៃសាកលភាវូបនីយកម្ម

- ធ្វើឱ្យមានការរីកចម្រើន ផ្នែកសេដ្ឋកិច្ច (កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍) និង សង្គម
- អភិវឌ្ឍផ្នែកបច្ចេកវិទ្យាទំនើប (បង្កើតគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិផ្សេងៗ)
- ធ្វើឱ្យមានការរីកចម្រើនទូរគមនាគមន៍អន្តរជាតិ (ទូរទស្សន៍ ទូរសព្ទ អ៊ីនធឺណេត)
- បង្កើតសេដ្ឋកិច្ចទីផ្សារសេរី (មានការប្រកួតប្រជែង)
- មានទំនាក់ទំនាក់ទំនងល្អនៅក្នុងទំនាក់ទំនងការបរទេស
- បង្កើតកិច្ចសហប្រតិបត្តិការល្អ ដើម្បីដោះស្រាយរាល់បញ្ហា ដែលបង្ការគម្រាមគំហែងដល់ពិភពលោកឱ្យទាន់ពេលវេលា (បរិស្ថាន ជម្ងឺឆ្លង សន្តិសុខ កំណើនប្រជាជន)
- មានភាពងាយស្រួលក្នុងការធ្វើបម្លាស់ប្តូរ របស់ប្រជាជនលើសាកលលោក

❖ អវិជ្ជមាននៃសាកលភាវូបនីយកម្ម

- ប្រទេសតូចតាចត្រូវបាត់បង់អធិបតេយ្យភាពរបស់ខ្លួន នៅចំពោះមុខប្រទេសមហាអំណាច
- មានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ពីសំណាក់ប្រទេសមហាអំណាចមកលើប្រទេសទន់ខ្សោយ ដែលជាហេតុធ្វើឱ្យមានការផ្លាស់ប្តូរ វិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម
- បង្កឱ្យមានសង្គ្រាមរវាងរដ្ឋ នឹងរដ្ឋ (អ៊ីស្រាអែល និង ប៉ាឡេស្ទីន)
- ធ្វើឱ្យមានការរីកសាយភាយយ៉ាងខ្លាំង នូវបច្ចេកវិទ្យាយោធាទំនើប ដែលបង្ការគម្រាមគំហែងដល់ពិភពលោក
- កំណើនប្រជាជននាំឱ្យមានបញ្ហាចោទដល់សេដ្ឋកិច្ច និង សង្គម

- ○ ប្រពន្ធ័ផ្តាយរណបក៏ជាប្រភពនាំឱ្យកើតបញ្ហា ដែលធ្វើឱ្យរដ្ឋាភិបាលរឹតតែបាត់បង់ប្រសិទ្ធភាពក្នុងការ គ្រប់គ្រងប្រពន្ធ័ពត៌មាន ។ (មានទិដ្ឋភាពផ្សេងទៀត)

២. ព្រះបាទនរោត្តមសីហនុ និង សម្តេចហ៊ុន សែន មានតួនាទី ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា ដូចជា៖

- ❖ **តួនាទីរបស់ព្រះបាទនរោត្តមសីហនុ ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា**
  - ○ ជាអ្នកតំណាងចលនាតស៊ូត្រីភាគី (ក្រុមរាជានិយម សីនសាន និង ក្រុមខ្មែរក្រហម)
  - ○ ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់
  - ○ ជាអ្នកផ្តួចផ្តើមឱ្យមានកិច្ចចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា ដែលនាំឱ្យមានកិច្ចព្រមព្រៀង ២៣ តុលា ឆ្នាំ ១៩៩១ ដើម្បីបញ្ចប់សង្គ្រាម នៅកម្ពុជា
  - ○ ជាបិតាផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ ជាក់ស្តែងក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ប្រទេសកម្ពុជាមានវិបត្តិនយោបាយ គឺមានការបែងចែកអំណាចនៃគណបក្សពីរ គឺគណបក្សហ្ជុនស៊ិនប៉ិច និងគណបក្សប្រជាជន នៅពេលនោះដែរ សម្តេចនរោត្តមសីហនុ បានរិះរកមធ្យោបាយមួយ គឺការបង្កើតសហនាយករដ្ឋមន្ត្រី ដើម្បីធ្វើឱ្យទទួលបាននូវសន្តិភាព ។
- ❖ **តួនាទីរបស់សម្តេចហ៊ុន សែន មានតួនាទី ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា**
  - ○ ជាតំណាងរដ្ឋាភិបាលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា ក្រោយមកជានាយករដ្ឋមន្ត្រី របស់ប្រទេសកម្ពុជា
  - ○ ផ្តួចផ្តើមឱ្យមានកិច្ចចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា ដោយមានការអញ្ជើញចូលរួមគ្រប់ភារកិច្ច មិនថាក្នុងឬក្រៅប្រទេស ដែលសម្តេចបានអញ្ជើញទៅហ្សាកាតាប្រទេសឥណ្ឌូនេស៊ី និងប្រទេសបារាំងជាដើម ។
  - ○ ចូលរួមកិច្ចចរចាសន្តិភាព ២៣ តុលា ឆ្នាំ ១៩៩១ ដែលនាំឱ្យមានការបោះឆ្នោត នៅកម្ពុជា
  - ○ ផ្តល់កិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់ ដើម្បីឱ្យមានការបោះឆ្នោតនៅកម្ពុជា

- ជាពិសេសក្រោយឆ្នាំ១៩៩៣ សម្តេចបានព្រមព្រៀង ធ្វើសមាហរណកម្ម ដើម្បីបញ្ចប់វិបត្តិនយោបាយនៅកម្ពុជា ដោយកម្ទេចអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហម នៅឆ្នាំ១៩៩៨ ។ (មានទិដ្ឋភាពផ្សេងទៀត)

៣.អាស៊ានគឺជា សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។

- ❖ ការចូលជាសមាជិកអាស៊ាន មានសារសំខាន់សម្រាប់ប្រទេសកម្ពុជា ដូចជា ៖ ប្រទេសកម្ពុជាមានលទ្ធភាពច្រើនក្នុងការបង្កលក្ខណៈងាយស្រួល
  រកមធ្យោបាយទំនាក់ទំនងពាណិជ្ជកម្ម លើការនាំចេញ ព្រោះអាស៊ានមានទីផ្សារធំ ហើយនៅជិត ងាយស្រួលសម្រាប់ការដឹកជញ្ជូន ។
- ❖ កម្ពុជាអាចទាក់ទាញវិនិយោគទុនបរទេស ចូលមកធ្វើវិនិយោគលើវិស័យផ្សេងៗ និងអាចកសាងសេដ្ឋកិច្ចរបស់ខ្លួន បានយ៉ាងឆាប់រហ័ស ។
- ❖ កម្ពុជាលែងព្រួយបារម្ភ ចំពោះការគំរាមគំហែងផ្នែកសន្តិសុខ និងលែងនៅឯកា
- ❖ មានសន្តិសុខ និងសេរីភាពក្នុងតំបន់ ព្រមទាំងចូលរួមដោះស្រាយបញ្ហាផ្សេងៗជាមួយអាស៊ាន និងមានអាទិភាពដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី
- ❖ មានការផ្លាស់ប្តូរចំណេះដឹង សង្គម វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ របស់សមាជិកទាំងអស់
- ❖ ផ្លាស់ប្តូរផ្នែកធនធានមនុស្ស វិទ្យាសាស្ត្រ បច្ចេកវិទ្យា
- ❖ កម្ពុជានិងទទួលបានការខ្ចីប្រាក់ ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងបណ្តាប្រទេសជាមិត្ត ក្នុងអត្រាការប្រាក់ទាប ហើយមានរយៈពេលយូ
- ❖ កម្ពុជាលេចមុខមាត់ក្នុងឆាកអន្តរជាតិ និងមានសិទ្ធប្រតិបត្តិការដោយសមភាព
- ❖ កម្ពុជាទទួលបានប្រាក់ចំណេញ យ៉ាងច្រើនទាំងផ្នែកកិច្ចការបរទេស និងកិច្ចការបរទេស
- ❖ កម្ពុជាចំណេញផ្នែកនយោបាយ និងមានឱកាសស្រូបយកអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចអាស៊ាន ក៏ដូចជាសហគមន៍អន្តរជាតិទាំងមូល
- ❖ (មានទិដ្ឋភាពផ្សេងទៀត)។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រឡង ១៣ តុលា ២០១៤ (លើកទី២)

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)

រយៈពេល ៩0 នាទី ពិន្ទុ៧៥

ប្រធាន

(១0ពិន្ទុ)១. តើព្រះបាទជ័យវ៉ែនទី៧ បានធ្វើអ្វីខ្លះក្នុងប្រវត្តិសាស្ត្រខ្មែរ?

(៣0ពិន្ទុ)២. ពណ៌នាពីបញ្ហាសន្តិសុខស្បៀង ដែលពិភពលោកកំពុងតែជួបប្រទះ?

(៣0ពិន្ទុ)៣.តើមូលហេតុអ្វី បានជាត្រូវកាត់ទោសមេដឹកនាំ នៃរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម)?

អត្រាកំណែ

១. ស្នាព្រះហស្តរបស់ព្រះបាទជ័យវ៉ែនទី៧ មានដូចជា ៖

- រំដោះប្រទេសឱ្យរួចផុតពីការឈ្លានពានរបស់ពួកចាម នៅក្នុងឆ្នាំ១១៧៧
- កសាងទីក្រុងអង្គរធំ (ត្រង់ប្រាសាទបាយ័ន)
- កសាងប្រាសាទជាច្រើនដូចជា ប្រាសាទបាយ័ន ប្រាសាទបន្ទាយឆ្មារ ប្រាសាទកីមែ
- កសាងមន្ទីរពេទ្យ និងសាលាសំណាក់
- កសាងផ្លូវគមនាគមន៍
- ពង្រីកអំណាចចក្រភពខ្មែរឱ្យធំទូលាយ
- លើកតម្កើនវិស័យព្រះពុទ្ធសាសនាបែបមហាយាន
- លើកស្ទួយអារ្យធម៌ខ្មែរឱ្យល្បីរន្ទឹនៅអាស៊ី
- វិស័យវប្បធម៌ឈានដល់កម្រិតកំពូល
- ព្រះអង្គជាបិតាជាតិខ្មែរ
- (មានទិដ្ឋភាពផ្សេងទៀត)

២. បញ្ហាសន្តិសុខស្បៀង ដែលពិភពលោកកំពុងជួបប្រទះមានដូចជា ៖

- បញ្ហាកង្វះគ្រឿងឧបភោគបរិភោគ
- បញ្ហាប្រឈមនឹងគ្រោះទ្ភិក្ស
- បញ្ហាដំណើការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោក
- បញ្ហារបបគំហើញផ្នែកបច្ចេកវិទ្យា និងបច្ចេកទេស
- បញ្ហាអត្រាកំណើនប្រជាជនលើពិភពលោក
- ការប្រើប្រាស់ថាមពល

- បញ្ហាការប្រើប្រាស់ដី និងថ្នាំសម្លាប់សត្វល្អិត មិនបានសមស្រប និងហួសកម្រិតបច្ចេកទេស
- បញ្ហាសង្គ្រាម (ជនភៀសខ្លួន)
- បញ្ហាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ការកាប់បំផ្លាញព្រៃឈើ ការជីកយកវ៉ែ រញ្ជួយដី បន្ទុះភ្នំភ្លើង ។
- (មានមតិត្រឹមត្រូវផ្សេងទៀត) ។

៣. មូលហេតុដែលនាំឱ្យមានការកាត់ទោសមេដឹកនាំ នៃរបបកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម)ព្រោះ៖

- ជម្លៀសប្រជាជនដោយបង្ខំ ចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជននានា
- ពលកម្មដោយបង្ខំ ដោយឱ្យប្រជាជនធ្វើការហួសកម្លាំង ហើយការទទួលទានមិនគ្រប់គ្រាន់
- បិទសិទ្ធសេរីភាពគ្រប់បែបយ៉ាង
- ផ្តាច់មនោសញ្ចេតនាគ្រប់បែបយ៉ាង
- លុបបំបាត់ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់
- ការសម្លាប់រង្គាលលើប្រជាជនស្លូតត្រង់
- វិសុទ្ធកម្ម (ការសម្រិតសម្រាំងយកប្រជាជនបដិវត្ត) នាំឱ្យមានការសម្លាប់កាន់តែច្រើន
- ក្របង្កើតមន្ទីរសន្តិសុខគ្រប់ទីកន្លែង (គុក) ។ អំពើវិនាសកម្មខាងលើនេះ ផ្ទុយពីសន្ធិសញ្ញាអន្តរជាតិ ដែលចែងអំពី
    - ឧក្រិដ្ឋកម្មសង្គ្រាម
    - ឧក្រិដ្ឋកម្មបប្រឆាំងមនុស្សជាតិ
    - ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបញ្ហាខាងលើនេះ បាននាំឱ្យរដ្ឋាភិបាលកម្ពុជាធ្វើសំណើទៅ អង្គការសហប្រជាជាតិ បង្កើតតុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្នុងសម័យខ្មែរក្រហម ដែលហៅថាតុលាការកូនកាត់ គឺសាលាក្តីខ្មែរក្រហម។ ការកាត់ទោសនេះមានទិសដៅដើម្បី ៖

- ផ្សះផ្សាជាតិ
- បង្រួបបង្រួមជាតិ
- ទប់ស្កាត់កុំឱ្យមានរបបនេះកើតឡើងម្តងទៀត
- ព្យាបាលផ្លូវចិត្តជនរងគ្រោះ
- ជាមេរៀនដល់មេដឹកនាំជំនាន់ក្រោយ
- មានមតិត្រឹមត្រូវផ្សេងទៀត ។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
សម័យប្រឡង ២៤ សីហា ២០១៥
វិញ្ញាសា : ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)
រយៈពេល ៩០នាទី ពិន្ទុ ៧៥

ប្រធាន :

(៥ពិន្ទុ) ១. តើរដ្ឋប្រហាសម្តេចនរោត្តម សីហនុកើតឡើងនៅឆ្នាំណា ?

(១៥ពិន្ទុ) ២.តើរដ្ឋប្រហានេះបាននាំមកអ្វីខ្លះដល់កម្ពុជា ?

(២០ពិន្ទុ) ៣. ចូរព័ណ៌នាពីគោលនយោបាយឈ្នះឈ្នះរបស់សម្តេចហ៊ុន សែនក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា ។

(២០ពិន្ទុ) ៤. ចូរវិភាគពីព្រះរាជាណាចក្រកម្ពុជាទី២ និងការកសាងកម្ពុជាឡើងវិញ។

(១៥ពិន្ទុ) ៥. ចូរវិភាគពីតួនាទីព្រះពុទ្ធសាសនាក្នុងសង្គមកម្ពុជា។

អត្ថាកំណែ

១. រដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុកើតឡើងនៅថ្ងៃទី១៧ មីនា ឆ្នាំ១៩៧០ ។

២. សម្រាប់កម្ពុជា រដ្ឋប្រហារនេះបាននាំមកនូវ ៖

- ការប្តូររបបរាជានិយម មកជារបបសាធារណរដ្ឋខ្មែរ
- ប្រទេសបែកជាពីរបក្ស ក្នុងក្រុងភ្នំពេញសាធារណរដ្ឋសេរី ជនបទកុម្មុយនីស្ត
- នៅទីក្រុងប៉េកាំងព្រះបាទនរោត្តម សីហនុ បង្កើតរដ្ឋាភិបាលនិរទេសខ្លួន
- សម្តេច សីហនុ អំពាវនាវអោយប្រជាជនចូលព្រៃម៉ាគីគីដើម្បីប្រឆាំងរបបសាធារណរដ្ឋខ្មែរ
- មានសង្គ្រាមរវាងពួកសាធារណរដ្ឋ និងខ្មែរក្រហម
- សង្គ្រាមស៊ីវិលធ្វើអោយមានមនុស្សស្លាប់ របួស និងពិការជាច្រើន
- ការកើតឡើងនូវអំពើពុករលួយ
- ទីក្រុងភ្នំពេញឡោមព័ទ្ធដោយពួកខ្មែរក្រហម
- ប្រជាជនរស់នៅដោយខ្វះជំរក ខ្វះសុវត្ថិភាព ខ្វះស្បៀងអាហារ ខ្វះសុខុមាលភាព
- ប្រជាជននៅទីក្រុងភ្នំពេញរស់នៅដោយភាពភ័យខ្លាច
- គ្រឹស្ថានសិក្សាមួយចំនួនត្រូវបានបិទទ្វារ ព្រោះលោកគ្រូអ្នកគ្រូបានរត់ភៀសខ្លួន
- កើតមានសង្គ្រាមត្រជាក់ (សេរី និងកុម្មុនីស្ត)
- ខ្មែរក្រហមមានឧកាសឡើងកាន់អំណាច ១៧ មេសា ១៩៩៥
- ខ្មែរក្រហមបានសម្លាប់ប្រជាជនថាជាខ្មាំងរបស់អង្គការ ។

៣. ពណ៌នាពីគោលនយោបាយឈ្នះឈ្នះរបស់សម្តេចហ៊ុន សែនក្នុងការបញ្ចប់សង្គ្រាម ៖

- ❖ វិស័យនយោបាយ
  - ១៩៩៨ សមាហរណកម្មកងទ័ពខ្មែរក្រហមជាមួយកងទ័ពរដ្ឋាភិបាល ធ្វើអោយកំងកម្លាំងមានឯកភាពដើម្បីក៏សាងប្រទេស
  - ក្រោយពីដកកម្លាំងខ្មែរក្រហមដួលរលំនៅតាមព្រំដែនមានសុវត្ថិភាព និងការអភិវឌ្ឍ
  - កម្ទេចអង្គការចាត់តាំងរបស់ខ្មែរក្រហម
  - មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនរបស់ប្រជាជនតាមព្រំដែន
  - មានការបែងចែកដីធ្លីកាន់តែកាន់កាប់ជាកម្មសិទ្ធដល់បងប្អូនជនភៀសខ្លួន (អតីតខ្មែរក្រហម)
  - បងប្អូនខ្មែរក្រហមត្រូវបានផ្តល់ទួនាទី និងបុណ្យសក្តិដល់បបងប្អូនដែលធ្លាប់មានពីមុន ។

- ❖ វិស័យសង្គម
  - ▪ ចាប់ពីឆ្នាំ ១៩៩៨ ដល់បច្ចុប្បន្នប្រទេសកម្ពុជាមានសុវត្ថិភាព និងសន្តិភាពពេញលេញ
  - ▪ ធ្វើអោយមានឯកភាពជាតិ និងបង្រួបបង្រួមជាតិ
  - ▪ ធ្វើអោយមានសម្ទិធលជាច្រើនបានកើតឡើងដូចជាសាលារៀន (ពីមត្រេយ្យរហូតដល់សកលវិទ្យាល័យ) មន្ទីពេទ្យ ស្ពាន ជាដើម
- ❖ វិស័យសេដ្ឋកិច្ច
  - ▪ ទំនាក់ទំនងពាណិជ្ជកម្មអន្តជាតិជាមួយអាស៊ាន និងមហាអំណាចពិភពលោកធំៗ
  - ▪ ការរីកចម្រើនវិស័យទេសចរណ៍
- ❖ វិស័យអប់រំ
  - ▪ បណ្តុះបណ្តាលធនធានមនុស្ស
  - ▪ ធ្វើកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំពីបឋមដល់ឧត្តមសិក្សា។

៤. វិភាគព្រះរាជាណាចក្រកម្ពុជាទី២ និងការកសាងកម្ពុជាឡើងវិញ ៖

- ❖ វិភាគពីព្រះរាជាណាចក្រកម្ពុជាទី២
  - ▪ កើតឡើងនៅថ្ងៃទី២៧ កញ្ញា ១៩៩៨ ដែលមានព្រះមហាក្សត្រសោយរាជ្យសម្តេចព្រះនរោត្តម សីហនុ
  - ▪ មានរដ្ឋធម្មនុញ្ញថ្មី សេរីពហុបក្ស
  - ▪ មានរដ្ឋាភិបាលស្របច្បាប់មួយ
  - ▪ ព្រះរាជាណាចក្រទី២កើតឡើងតាមរយៈការបោះឆ្នោតនៅថ្ងៃទី២៣ ២៨ ឧសភា ១៩៩៣ រៀបចំដោយអង្គការសហប្រជាជាតិ
  - ▪ ចាប់ពីឆ្នាំ ១៩៩៣ រហូតដល់បច្ចុប្បន្នកម្ពុជាមានការបោះឆ្នោតជាសកលដោយជ្រើសតាំងតំណាងរាស្ត្របាន ៥អាណាត្តិនៃរដ្ឋសភា ដែលប្រមុខរដ្ឋាភិបាលគឺ សម្តេចហ៊ុនសែន និងសម្តេច នរោត្តម រណឬទ្ធិ ជានាយករដ្ឋមន្ត្រី ។
- ❖ ការកសាងកម្ពុជាឡើងវិញ
  - ▪ ការស្តារវិស័យសេដ្ឋកិច្ច (កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម)
  - ▪ វប្បធម៌ និងអប់រំ (បង្កើតសាលារៀន គ្រប់កម្រិតសិក្សាបង្កើតវត្តអារាម ជំនឿ សាសនា)
  - ▪ ធ្វើកំណែទម្រង់គ្រប់ហេថារចនាសម្ព័នជាតិ
  - ▪ ធ្វើកំណែតម្រង់លើវិស័យកងទ័ព នគរបាលជាតិ

- បង្កើតឲ្យមានទីផ្សារ សេដ្ឋកិច្ចសេរី ផ្តល់កម្មសិទ្ធឯកជន
- ផ្តល់សិទ្ធសេរីភាពដល់ប្រជាជន។

៥. វិភាគពីតួនាទីព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ ៖

- បានអប់មនុស្សប្រកាន់នូវចំណុចល្អ (ស្គាល់បុណ្យ ស្គាល់បាប)
- ជាទីកន្លែងស្នាក់នៅនិងជម្រកសំរាប់ការអប់រំផ្លូវចិត្ត
- ផ្តល់ចំណោះធ្វើ គោរពប្រណិបត្តិអំពើល្អអោយស្រឡាញ់ជាតិ និងមិនប្រកាន់ពូជសាសន៍ មិនប្រព្រឹត្តិខុសគន្លងព្រះពុទ្ធ
- សីលធម៍មានអត្តចរិកថ្លៃថ្នូមានការគោរព
- ចេះរស់នៅក្នុងសង្គម មានទំនាក់ទំនង ចេះអត់អោនអធ្យាស្រ័យ សាមគ្គីក្នុងសង្គមប្រជាធិបតេយ្យ ជាកន្លែងផ្សព្វផ្សាយវប្បធម៍ជាតិ និងរស់នៅដោយសន្តិភាពអហិង្សា រស់នៅក្នុងវប្បធម៍ចែករំលែក។
- មានមតិត្រឹមត្រូវផ្សេងទៀត។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
សម័យប្រលង ២២ សីហា ២០១៦
វិញ្ញាសា : ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)
រយៈពេល ៩០នាទី ពិន្ទុ ៧៥
ប្រធាន :

(៥ពិន្ទុ) ១.តើនរណាជាមេដឹកនាំខ្មែរក្រហម? សូមរាប់ឲបាន៣នាក់។

(១៥ពិន្ទុ) ២.ហេតុអ្វីបានជាកម្ពុជារងការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហម?

(១៥ពិន្ទុ) ៣.តើអាស៊ានជាអ្វី? ហើយតើកម្ពុជាទទួលបានផលប្រយោជន៍អ្វីខ្លះ
ពីការចូលជាសមាជិកអាស៊ាន?

(២០ពិន្ទុ) ៤.ចូលពណ៌នាពីការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហមឆ្នាំ១៩៧៩ ដល់១៩៩០?

(២០ពិន្ទុ) ៥.តើពិភពលោកយើងនាពេលបច្ចុប្បន្ននេះ កំពុងជួបប្រទះបញ្ហាធំៗអ្វីខ្លះ?

អត្ថាកំណែ

១.មេដឹកនាំខ្មែរក្តហមរួមមាន ប៉ុល ពត នួនជា អៀងសារី។

២.កម្ពុជារងការបំផ្លិចបំផ្លាញក្នុងរបបខ្មែរក្រហម ព្រោះ ៖

- ប្រកាន់យករបបនយោបាយផ្តាច់ការ ខ្មៅងងឹត
- មេដឹកនាំមានចរិតជាតិនិយមជ្រុល
- ប្រល័យពូជសាសន៍
- បង្ខំប្រជាជនខ្មែរឲធ្វើការជាទម្ងន់
- បង្អត់អាហារ
- បំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង
- បំបាត់ជំនឿសាសនា ប្រពៃណីទំនៀមទម្លាប់ ការអប់រំ
- ធ្វើទារុណកម្ម
- ជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា
- មនោគមវិជ្ជាជ្រុលនិយម។
  (អាចមានទិដ្ឋភាពផ្សេងៗទៀត)

៣.អាស៊ានជាសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍។

❖ កម្ពុជាទទួលផលប្រយោជន៍ពីការចូលជាសមាជិកអាស៊ានដូចជា ៖

- កម្ពុជាអាចធ្វើទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជាសមាជិកក្នុងតំបន់
- មក្ពុជាមានឱកាសប្រកួតប្រជែងខ្ពស់ជាមួយប្រទេសក្នុងតំបន់ធ្វើឲសេដ្ឋកិច្ចរីកចម្រើន
- កម្ពុជាទទួលបានកំណើនភ្ញៀវទេសចរណ៍
- កម្ពុជាលែងបារម្ភចំពោះការគំរាមកំហែងផ្នែកសន្តិសុខ និងលែងនៅឯកា
- កម្ពុជាចូលរួមដោះស្រាយបញ្ហាផ្សេងៗជាមួយអាស៊ាន
- មានការផ្លាស់ផ្តូរផ្នែកចំណេះដឹង សង្គមកិច្ចវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ កីឡាពីប្រទេសជាសមាជិកទាំងអស់
- ផ្លាស់ប្តូរគ្នាទៅវិញទៅមកផ្នែកវិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងព័ត៌មានថ្មីបន្ថែមទៀត

- កម្ពុជាទទួលបានផលចំណេញយ៉ាងច្រើនពីការអភិវឌ្ឍពីវិស័យផ្សេងៗដូចជា កិច្ចការនយោបាយ និងទំនាក់ទំនងការបរទេស។
- (អាចមានទិដ្ឋភាពផ្សេងទៀត)

៤.ពណ៌នាពីការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧៩ ដល់១៩៩០ មាន ដូចជា៖

- សេដ្ឋកិច្ច

- បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃដើម្បីជួយដល់ស្ត្រីមេម៉ាយ ចាស់ជរា កុមារកំព្រា ជនពិការ ក្នុងការងារកសិកម្ម
- កសាងហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ចមានផ្លូវថ្នល់ កំពង់ផែ សាលារៀន មន្ទីពេទ្យ
- ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយប្រទេសជិតខាងក្នុងតំបន់ និងពិភពលោក
- ពង្រឹងសុខសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមដើម្បីទាក់ទាញវិនិយោគទុនពីបរទេស
- បង្កើតសេដ្ឋកិច្ចទីផ្សារសេរី និងជម្រុញការអភិវឌ្ឍធនធានមនុស្ស

-ផ្នែកសង្គម និងនយោបាយ

- រំដោះប្រជាជនឲ្យចេញផុតពីរបបប្រល័យពូជសាសន៍ប៉ុល ពត
- ទប់ស្កាត់អំពើអសកម្មក្នុងសង្គម ការជួញដូរមនុស្ស អាវុធ គ្រឿងញៀន
- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ
- ធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ
- អនុវត្តនយោបាយបង្រួបបង្រួម។
- (មានផ្សេងៗទៀត)

៥.ពិភពលោកយើងនាពេលបច្ចុប្បន្ន កំពុងជួបប្រទះនិងបញ្ហាធំៗដូចជា៖

- បញ្ហាបរស្ថាន (រញ្ជួយដី ខ្យល់ព្យុះ ទឹកជំនន់ ការឡើងកម្តៅ គ្រោះរាំងស្ងួត)
- បញ្ហាកំណើនប្រជាជន (កង្វះអនាម័យ បញ្ហាអប់រំ បញ្ហាសុខភាព)
- បញ្ហាជនអន្តោប្រវេសន៍ (មានការចំណាកស្រុក កើតចលាចល បញ្ហាជំនឿ)

- បញ្ហាសុន្ទិសុខស្បៀង (ដីថយគុណភាព ស្បៀងឡើងថ្លៃ បញ្ហាបជិវត្តន៍បែតង)
- បញ្ហាភេរវកម្មអន្តរជាតិ (សង្គ្រាម បង្កើតចលាចលសង្គម ការកាប់សម្លាប់ ការជួញដូរមនុស្ស គ្រឿងញៀន។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រលង ២១ សីហា ២០១៧

វិញ្ញាសា: ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)

រយៈពេល ៩០នាទី ពិន្ទុ៧៥

ប្រធាន:

១. តើសហគមអាស៊ាន មានសមាជិកប៉ុន្មាន? ប្រទេសណាខ្លះ? (១០ ពិន្ទុ)

២. ហេតុអ្វីបានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំង ដោយចុះសន្ធិសញ្ញាអាណាព្យាបាលបារាំង? (១៥ ពិន្ទុ)

៣. ចូរពណ៌នាពីនយោបាយអព្យាក្រឹត នៅក្នុងរបបសង្គមរាស្ត្រនិយម (ឆ្នាំ ១៩៥៣-១៩៧០)។

៤. តើសង្គ្រាមនៅកម្ពុជាក្នុងឆ្នាំ ១៩៧០-១៩៧៥ និងឆ្នាំ ១៩៧៩-១៩៩៨ និងរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?

៥. មូលហេតុអ្វីបានជាគេចាត់ទុកថា សម្តេចនរោត្តមសីហនុ និងសម្តេចហ៊ុនសែន ជាបិតាសន្តិភាពនៅកម្ពុជា?

អត្ថាកំណែ

១. សមាគមអាស៊ានមាន ១០ ប្រទេសគឺ

- ព្រះរាជាណាចក្រថៃឡង់ដ៍
- សាធារណរដ្ឋហ្វីលីពីន
- សហព័ន្ធម៉ាឡេស៊ី
- សាធារណរដ្ឋសិង្ហបុរី
- ប្រ៊ុយណេដារុយសាឡឹម
- សាធារណរដ្ឋសង្គមនិយមវៀតណាម
- សហព័ន្ធមីយ៉ាន់ម៉ា
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- ព្រះរាជាណាចក្រកម្ពុជា

២.បានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំង ដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំងព្រោះ៖

- ប្រទេសកម្ពុជាកាន់តែចុះទន់ខ្សោយទៅៗ និងមានវិបត្តិផ្ទៃក្នុង
- សៀម
  និងយួនប៉ុនប៉ងលេបត្រាប់ទឹកដីខ្មែរដោយយកទន្លេមេគង្គធ្វើជាព្រំប្រទល់នៃប្រទេសទាំងពីរ
- កម្ពុជាចង់បានមហាអំណាចអឺរ៉ុបណាមួយ (បារាំង) មកជួយការពារទឹកដីពូជសាសន៍ខ្មែរ
- និងមតិផ្សេងៗទៀត

៣.ពណ៌នានយោបាយអព្យាក្រឹតក្នុងរបបសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) មានដូចជា៖

–មូលហេតុបណ្តាលឱ្យកម្ពុជាអនុវត្តនយោបាយអព្យាក្រឹត៖

- អនុវត្តតាមសេចក្តីសម្រេចរបស់សន្និសីទក្រុងហ្សឺណែវឆ្នាំ ១៩៥៤ ដែលស្នើដោយសូវៀត និងចិន
- កម្ពុជាចង់រួមរស់ដោយសន្តិសហវិជ្ជមានជាមួយបណ្តាលប្រទេសនានាលើពិភពលោកពិសេសប្រទេសជិតខាង
- មានមតិត្រឹមត្រូវផ្សេងៗទៀត

- ដើម្បីពង្រឹងនយោបាយអព្យាក្រឹត របបសង្គមរាស្ត្រនិយមបានគឺ
- ១៨ មីនា ១៩៥៥ ក្នុងដំណើរទស្សនកិច្ចនៅឥណ្ឌា សម្តេចនរោត្តមសីហនុ
  បានចុះហត្ថលេខាជាមួយលោក នេរុ
  លើសេចក្តីប្រកាសរួមមួយគឺការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព
- ១៨-២៤ មេសា ១៩៥៥ ក្នុងសន្និសីទកំពូលនៃប្រជាជាតិអាស៊ី-អាហ្វ្រិកនាទីក្រុងបានឌុង
  ព្រះអង្គបានប្រកាសពីគោលនយោបាយ អព្យាក្រឹត្យ និងបានរួមរស់ជាមួយគ្នាដោយសុខសន្តិភាព
- ១៤ ធ្នូ ១៩៥៥ ក្នុងពេលដែលកម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ
  កម្ពុជាបានប្រកាសពីមាគ៌ានយោបាយអព្យាក្រិត
- ១៩៥៦ នៅទីក្រុងប្រ៊ីយូនី ព្រះអង្គបានចុះហត្ថលេខាលើធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ
- មានមតិត្រឹមត្រូវផ្សេងៗទៀត
  - ❖ លទ្ធផលនៃនយោបាយអព្យាក្រឹតគឺ
    - ០ ជំហានដំបូង
      - •កម្ពុជាល្បីសុះសាយក្នុងតំបន់
      - •បក្សប្រឆាំងពុំហ៊ានដំទាស់ហើយសរសើរពីនយោបាយនេះ
      - •កម្ពុជាបានសុខសន្តិភាពអស់រយៈពេល ១៥ ឆ្នាំ (១៩៥៥-១៩៧០)
        ស្របពេលដែលប្រទេសជិតខាងជួបនឹងសង្គ្រាម
      - •និងមតិផ្សេងៗទៀត
  - ❖ ដំណាក់កាលសង្គ្រាមត្រជាក់

  នយោបាយអព្យាក្រឹតកាន់តែចុះទន់ខ្សោយទៅដោយសារ៖

  - មហាអំណាចមនោគមវិជ្ជាទាំងពីរគឺសេរី និងកុំម្មុយនីស្តពុំទុកកម្ពុជាក្នុងមាគ៌ាសន្តិភាព
    និងបំពានលើនយោបាយអព្យាក្រឹត្យ
  - ជំនួយពីសហរដ្ឋអាមេរិក មានចរិកចិញ្ចឹមពួកស្តាំនិយម
  - ប្រទេសថៃឧបត្ថម្ភគាំទ្រដល់ចលនាខ្មែរសេរី ឱ្យវាយសង្គមរាស្ត្រនិយម
  - រៀតណាមខាងត្បូងឈ្លានពានព្រំដែនកម្ពុជា

- រៀតណាមខាងជើងប្រើប្រាស់ផ្លូវលំហូជីមិញឆ្លងកាត់ទឹកដីខ្មែរ និងបោះមូលដ្ឋានទ័ពលើទឹកដីកម្ពុជា
- សង្គមរាស្ត្រនិយមអនុវត្តនយោបាយអព្យាក្រឹតមិនចំទិសដៅ ដោយលំអៀងទៅរកកុំម្មុយនីស្ត
- និងមតិផ្សេងៗទៀត

៤.សង្គ្រាមនៅកម្ពុជា (១៩៧០-១៩៧៥) និង (១៩៧៩-១៩៩៨) និងរបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មានផលវិបាកដល់កម្ពុជាដូចតទៅ៖

– សង្គ្រាម ១៩៧០-១៩៧៥ និង១៩៧៩-១៩៩៨ ផ្តល់នូវវិនាសកម្មដូចតទៅ

○ ផ្នែកសង្គម

- សម្លាប់ជីវិតមនុស្សជាង ៣ លាននាក់
- បន្សល់នូវរបួស ពិការ ក្មេងកំព្រា ស្ត្រីមេម៉ាយ
- បាត់បង់ធនធានមនុស្ស
- ព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង រងទុក្ខវេទនា គ្រោះទុរភិក្ស
- ជួបនូវអនាធិបតេយ្យ ចោរកម្ម ពុករលួយអយុត្តិធម៌
- បំបាត់សិទ្ធិសេរីភាពជំនឿសាសនា
- និងមតិផ្សេងៗទៀត

○ ផ្នែកសេដ្ឋកិច្ច៖

- ដីស្រែចម្ការទុកទំនេរចោលក្លាយជាចំការមើន រណ្តៅគ្រាប់បែក
- រោងចក្រ សហគ្រាស ចំការកៅស៊ូត្រូវបំផ្លាញ
- បំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ពាន ផ្លូវថ្នល់ សំណង់បរិក្ខាផ្សេងៗ
- បាត់បង់ធនធាន និងអ្នកវិនិយោគទុនមិនហ៊ានចូលមក
- ទំនិញឡើងថ្លៃ អតិផរណាក្រដាសប្រាក់
- និងមតិផ្សេងៗទៀត

- ខាងនយោបាយ៖
  - ប្រទេសកម្ពុជាបាត់បង់កេរ្តិ៍ឈ្មោះកិត្តិយស លើឆាកអន្តរជាតិ

- ប្រជាជនបាត់បង់ជំនឿលើថ្នាក់ដឹកនាំ និងអស់សង្ឃឹមលើជោគវាសនាប្រទេសជាតិ
- នាំកម្ពុជាទៅរកការសម្លាប់រង្គាលលើជាតិសាសន៍ខ្លួនឯង
- កម្ពុជាជាប្រទេសរស់នៅដោយឯកោ
- និងមិតផ្សេងៗទៀត។

៥.បានជាគេចាត់ទុកថា សម្តេចនរោត្តមសីហនុ និងសម្តេចហ៊ុនសែន ជាបិតាសន្តិភាពនៅកម្ពុជាព្រោះ៖

– សម្តេចនរោត្តមសីហនុ៖

- ជាអ្នកផ្តួចផ្តើមឱ្យមានការចរចារកសន្តិភាព
- ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC)
- ជាអ្នកចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១
- ជាអ្នកបង្រួបបង្រួមជាតិ ជាអ្នកផ្សះផ្សាជាតិដោយធ្វើការផ្សះផ្សារវិបត្តិក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ ដែលកើតចេញពីការដណ្តើមឥទ្ធិពលគ្នារវាងគណបក្សហ្វុនស៊ិនប៉ិច និងគណបក្សប្រជាជនកម្ពុជា បង្កើតបានជារដ្ឋាភិបាលចម្រុះ។

– សម្តេចហ៊ុនសែន៖

- ជាអ្នកផ្តួចផ្តើមឱ្យមានការចរចារសន្តិភាព
- ជាអ្នកចុះហត្ថលេខាលើសន្ធិសញ្ញាក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១
- ជាអ្នកធានាអះអាងសុនសន្តិសុខ
  សណ្តាប់ធ្នាប់ក្នុងពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រថ្ងៃទី២៣ ដល់២៨ ឧសភា ១៩៩៨
- ជាអ្នកផ្សះផ្សារវិបត្តិក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ឆ្នាំ១៩៩៨ ឆ្នាំ២០១៣
- ជាអ្នកបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅកម្ពុជា ដោយអនុវត្តនយោបាយឈ្នះ-ឈ្នះ ដែលបានរំសាយអង្គការចាត់តាំងខ្មែរក្រហម
  និងធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមជាមួយកងទ័ពជាតិ។
- (មានមតិផ្សេងៗទៀត)

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រលង ២០ សីហា ២០១៨

វិញ្ញាសា: ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)

រយៈពេល ៩០នាទី ពិន្ទុ៧៥

ប្រធាន:

១.សហគមន៍អឺរ៉ុបជាអ្វី?

២.ចូរអត្ថាធិប្បាយពីចំណុចវិជ្ជមាន និងអវិជ្ជមាននៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា។

៣.ចូរពណ៌នាពីកម្ពុជាសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០)។

៤.ចូលហេតុអ្វីបានជារបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សម្លាប់មនុស្ស ហើយតើវាមានផលវិបាកអ្វីខ្លះដល់កម្ពុជា?

៥.ចូរពណ៌នាពីដំណើរការកសាងកម្ពុជាឡើងវិញចាប់ពីឆ្នាំ ១៩៩៨ មកទល់ពេលបច្ចុប្បន្ន។

អត្ថាកំណែ

១.សហគមន៍អឺរ៉ុប គឺជាសហគមន៍សេដ្ឋកិច្ច និងនយោបាយដ៏ធំសម្បើមមួយ ដែលមានរដ្ឋអឺរ៉ុបចំនួន២៧ ប្រទេសជាសមាជិក ដោយឈរលើគោលការណ៍សេរីភាព ប្រជាធិបតេយ្យ សិទ្ធិមនុស្ស។

២.ចំណុចវិជ្ជមាន និងអវិជ្ជមាននៃរបបអាណាព្យាបាលបារាំងគឺ

- លទ្ធផលវិជ្ជមាន៖
  - ការពារទឹកដី និងពូជសាសន៍ខ្មែរឱ្យគង់វង្ស
  - កែទម្រង់សង្គមខ្មែរ ប្រព័ន្ធច្បាប់តុលាការ រដ្ឋបាល ពន្ធដារ ការចុះបញ្ជីដីធ្លី អប់រំសិក្សាធិការ...ឱ្យមានលក្ខណៈប្រសើរជាងមុន
  - សិក្សាស្រាវជ្រាវ ចងក្រងពីអរិយធម៌ប្រវត្តិសាស្ត្រខ្មែរ និងធ្វើការផ្សព្វផ្សាយទៅលើឆាកអន្តរជាតិ និងជួយជួសជុល ការពារប្រាសាទរបស់ខ្មែរឱ្យបានគង់វង្សតាមរយៈសាលាចុងបូព៌ាប្រទេស
  - សាងសង់ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ និងសមិទ្ធផលផ្សេងៗទៀត
  - ទាមទារយកទឹកដីខ្មែរពីសៀមមកឱ្យខ្មែរវិញដូចជា៖
    - ខេត្តស្ទឹងត្រែងនៅឆ្នាំ ១៨៩៣
    - ខេត្តត្រាត កោះកុង ម្លូវព្រៃ ទន្លេពៅ នៅឆ្នាំ ១៩០៤
    - ខេត្តសៀមរាប បាត់ដំបង សេរីសោភ័ណ្ឌ នៅឆ្នាំ ១៩០៧
    - គូសផែនទីដងរ៉ែកនៅឆ្នាំ ១៩០៨ ទុកជាប្រយោជន៍ដល់ខ្មែរ
- លទ្ធផលអវិជ្ជមាន៖
  - ជំរិតទារពន្ធដារយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យប្រជាពលរដ្ឋខ្មែរកាន់តែក្រីក្រ និងធ្វើឱ្យមានគម្លាតរវាងអ្នកមាន និងអ្នកក្រនិងជនបទ
  - ប្រមូលយកកេតនភណ្ឌ និងសម្បត្តិមានតម្លៃយកទៅស្រុកបារាំង
  - កាត់ទឹកដីខ្មែរឱ្យសៀម និងយួនស្រេចតែចិត្តដូចជា៖
    - ១៩០៧ កាត់ខេត្តត្រាតឱ្យទៅសៀម

- ៣១ មករា ១៩៣៩
  បារាំងដាក់បញ្ចូលកោះត្រល់ចូលក្នុងដែនរដ្ឋបាលកូសាំងស៊ីន
- ០៤ មិថុនា ១៩៤៩ បារាំងកាត់ដែនដីកូសាំងស៊ីន (កម្ពុជាក្រោម)
  ឱ្យទៅអំណាចបាវដោយវៀតណាម
- ទិដ្ឋភាពផ្សេងៗទៀត

៣.ពណ៌នាពីកម្ពុជាសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៥៣) រួមមាន៖

- ការបង្កើតរបបសង្គមរាស្ត្រនិយម៖
  - រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ បានបញ្ញត្តិពីអំណាចព្រះមហាក្សត្រដោយ
    - ព្រះអង្គសោយរាជ្យមួយជីវិត ប៉ុន្តែមិនកាន់អំណាច
    - រាល់ទស្សនយោបាយរបស់ព្រះមហាក្សត្រត្រូវដាក់អោយសភាអនុម័ត
      ទើបយកទៅអនុវត្ត
  - សភាតែងតែជំទាស់រាល់គំនិតទស្សនៈនយោបាយរបស់ព្រះមហាក្សត្រ
  - ព្រះរាជាពុំចង់ឃើញការខ្វែងគំនិតគ្នា និងការបែកបាក់គ្នា ក្នុងរង្វង់អ្នកដឹកនាំ
  - ព្រះរាជាចង់ឱ្យប្រជាជន អ្នកនយោបាយគ្រប់និន្នាការ
    នយោបាយស្ថិតក្រោមម្លប់រាជបល្ល័ង្ក តែមួយ
  - ដូច្នេះហើយបានជាព្រះអង្គដាក់រាជ្យ នៅថ្ងៃទី ០៣ មីនា ១៩៥៥
    ហើយបង្កើតអង្គការសង្គមរាស្ត្រនិយម ថ្ងៃទី២៣ មីនា ១៩៥៥
    ដោយចូលរួមបោះឆ្នោតនៅថ្ងៃ ១១ កញ្ញា ១៩៥៥ ទទួលបានជោគជ័យ ៨៣.៨៧%
    ហើយសង្គមរាស្ត្រនិយមក៏បានកើតឡើង។
- សមាជជាតិ៖
  - ជាវេទិកានៃលទ្ធិប្រជាធិបតេយ្យ ដែលតម្រូវអោយប្រជាជន
    ចូលរួមបញ្ចេញមតិយោបល់ ជាមួយថ្នាក់ដឹកនាំជាតិ ដើម្បីប្រយោជន៍រួមរបស់ជាតិ
  - សមាជជាតិត្រូវបានប្រារព្ធឡើងមួយឆ្នាំ ០២ ដង
- នយោបាយអព្យាក្រឹតនៅកម្ពុជា៖

- គោរពស្មារតីសន្និសីទក្រុងហ្ស៊ីណែវឆ្នាំ ១៩៥៥
- ដើម្បីរក្សាសន្តិភាពនៅកម្ពុជា
- ដើម្បីរួមរស់ដោយសន្តិសហវិជ្ជមាន
- មានសុខសន្តិភាពរយៈពេល១៥ ឆ្នាំ
- ទប់ទល់នឹងឥទ្ធិពលនៃសង្គ្រាមត្រជាក់
- ឥទ្ធិពលនៃសង្គ្រាមត្រជាក់ ធ្វើអោយនយោបាយអព្យាក្រឹតដួលរលំ

- សមិទ្ធផល៖
  - សេដ្ឋកិច្ច៖ រីកចម្រើនផ្នែកកសិកម្ម និងនេសាទ
  - គមនាគមន៍៖ ផ្លូវទឹក គោក អាកាស
  - ពាណិជ្ជកម្ម ឧស្សាហកម្ម៖ មានការរីកចម្រើនផ្នែកអហរ៉ណ នីហរ៉ណជាតិ
  - វិស័យធនាគារ៖ ប្រាក់រៀលត្រូវបានចរាចរណ៍នៅទូទាំងប្រទេស
  - វប្ប៉ធម៌៖ រីកចម្រើនផ្នែកសិក្សាធិការ កីឡា សិល្ប:
  - សង្គមកិច្ច៖ ផ្តោតលើបញ្ហាពីរគឺ សុខាភិបាល និងការអនុវត្តច្បាប់

៤.មូលហេតុបានជារបបប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សម្លាប់មនុស្ស និងផលវិបាក មានដូចជា

- មូលហេតុ៖
  - ប្រកាន់យកបដិវត្តន៍កុំម្មុយនីស្តដែលតម្រូវឱ្យមានការ " កម្ទេច"
  - គោលការណ៍ " មហាលោតផ្លោះមហាអស្ចារ្យ" ដើម្បីសម្រេចគោលដៅឱ្យចាប់រហ័ស
  - គំនិតស្នេហាជាតិនិយមជ្រុលងងឹតងងុល ដោយតម្រូវឱ្យជឿជាក់តែលើអង្គការមួយ បើពុំនោះទេត្រូវសម្លាប់ចោល
  - ការអប់រំបំពាក់កំហឹងវណ្ណ:ដល់កម្មាភិបាលខ្មែរក្រហម តាំងពីមុនឆ្នាំ ១៩៧៥
  - នយោបាយរឹមជ្ឈការសិទ្ធិអំណាចកាប់សម្លាប់មនុស្សដល់កម្មាភិបាលថ្នាក់ទាប ដែលភាគច្រើនជាមនុស្សមានការសិក្សារតិចតួច ឬល្ងង់ខ្លៅ និងបានក្លាយជាអ្នកដឹកនាំតាមមូលដ្ឋាន

- គោលនយោបាយបោសសម្អាត សម្រិតសម្រាំង យកមនុស្សបដិវត្តន៍បរិសុទ្ធ
- ផ្សេងៗ

- ផលវិបាកមាន៖
  - បាត់បង់កិត្តិយស និងកិត្យានុភាពជាតិលើឆាកអន្តរជាតិ
  - ជាច់និរន្តភាពអភិវឌ្ឍន៍ជាតិ៖
    - សេដ្ឋកិច្ចជាតិរលត់រលាយ
    - ប្រព័ន្ធអប់រំត្រូវបំផ្លាញទាំងស្រុង
    - បាត់បង់ធ្នធានមនុស្ស
    - បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា ជនបាក់កម្លាំង
    - ប្រជាជនរាប់សែននាក់ រត់ចោកចោលប្រទេស
    - បង្កជាវិបត្តិផ្លូវចិត្ត
    - ហេដ្ឋារចនាសម្ព័ន្ធត្រូវបំផ្លាញ
    - វប្ប្ធម៌ សាសនា និងជំនឿត្រូវបំផ្លាញចោល
    - សិទ្ធិសេរីភាព កម្មសិទ្ធិឯកជន តម្រូវការជាមូលដ្ឋានត្រូវបានដកហូត...។

៥.ពណ៌នាពីដំណើរការកសាងកម្ពុជាឡើងវិញចាប់ពីឆ្នាំ ១៩៩៨ មកដល់បច្ចុប្បន្នរួមមានគឺ

- វិស័យនយោបាយ៖
  - ឆ្នាំ ១៩៩៨ មានការធ្វើសមារណកម្មកងទ័ពខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាលធ្វើឱ្យមានកម្លាំងឯកភាពគ្នា ដើម្បីស្តារប្រទេស និងកសាងប្រទេសកម្ពុជាឡើងវិញ
  - ក្រោយពីកងកម្លាំងខ្មែរក្រហមដួលរលំ នៅតាមតំបន់ព្រំដែនមានសុវត្ថិភាព និងការអភិវឌ្ឍ
  - ការកម្ទេចរចនាសម្ព័ន្ធអង្គការចាត់តាំងខ្មែរក្រហម
  - ការបែងចែកដីធ្លីកាន់កាប់ជាកម្មសិទ្ធិដល់បងប្អូនអតីតខ្មែរក្រហម
  - បងប្អូនខ្មែរក្រហមបានទទួលតួនាទី និងបុណ្យសក្តិដែលធ្លាប់មានពីមុន

- វិស័យសង្គម៖
  - ១៩៩៨ មកដល់បច្ចុប្បន្នមានសុវត្ថិភាព និងសន្តិភាពពេញលេញ
  - ធ្វើឱ្យមានសមិទ្ធផលជាច្រើនបានកើតឡើងដូចជា៖
    - កសាងសាលារៀនចាប់ពីមត្តេយ្យសិក្សារហូតដល់សាកលវិទ្យាល័យ
    - កសាងមន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន ស្ពានអាកាស ប្រព័ន្ធធារាសាស្ត្រ ជាពិសេសសេដ្ឋកិច្ចមានការរីកច្រើន
    - និយាយរួមគឺមានការរីកចម្រើនលើគ្រប់វិស័យ
- វិស័យសេដ្ឋកិច្ច៖
  - មានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ជាមួយអាស៊ាន និងមហាអំណាចធំៗ លើពិភពលោក
  - កសិកម្មមានការរីកចម្រើនដោយរដ្ឋាភិបាលយកចិត្តទុកដាក់ ក្នុងការបង្កើត ប្រព័ន្ធធារាសាស្ត្រ និងបង្ការ៖ត់ពូជ
  - អនុវត្តសេដ្ឋកិច្ចទីកផ្សារសេរី កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
  - វិស័យឧស្សាហកម្មមានការរីកចម្រើន ផ្នែករោងចក្រសហគ្រាសតូចធំជាច្រើន ពិសេសរោងចក្រវាយនភ័ណ្ឌ សម្រាប់បង្កើនការងារដល់ប្រជាពលរដ្ឋ ចៀសវាងការធ្វើចំណាក់ស្រុក និងកាត់បន្ថយភាពក្រីក្រ
  - វិស័យទេសចរណ៍ វប្បធម៌ មានប្រាសាទបុរាណជាច្រើន និងទេសចរណ៍ធម្មជាតិ សម្រាប់ ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ
- វប្បធម៌៖
  - ការបង្កើតពហុកីឡាដ្ឋាន បណ្តុះបណ្តាលជំនាញ ធ្វើឱ្យកីឡាករមានសមត្ថភាព ក្នុងការប្រកួតប្រជែងលើឆាកអន្តរជាតិ
  - អភិរក្សសម្បត្តិវប្បធម៌ រូបិយនិងសម្បត្តិវប្បធម៌អរូបិយ ព្រមទាំងដាក់បញ្ចូលសម្បត្តិវប្បធម៌ ជាបេតិកភ័ណ្ឌពិភពលោក (រម្មណីយដ្ឋានអង្គរ ប្រាសាទព្រះវិហារ...)

- ការអនុវត្តច្បាប់៖
  - មានការទប់ស្កាត់ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងអំពើកេរវកម្ម
  - មានសេរីភាពផ្នែកសារពត៌មាន
    និងអនុញ្ញាតឱ្យមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការសង្គមស៊ីវិល
  - សមភាពយេនឌ័រ (ផ្តល់សិទ្ធិដល់ស្ត្រី)
  - ផ្សេងៗ...។

ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

សម័យប្រលង ១៩ សីហា ២០១៩

វិញ្ញាសា: ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)

រយៈពេល ៩០នាទី ពិន្ទុ៧៥

ប្រធាន:

(១០ពិន្ទុ) ១.អ្វីជាគោលនយោបាយអញ្ញាក្រឹត្យ? ចូលអ្នកពណ៌នា។

(១៥ពិន្ទុ) ២.ហេតុអ្វីបានជារបបសាធារណរដ្ឋខ្មែរឆ្នាំ១៩៧០ ដល់ ១៩៧៥ ដួលរលំ?

(១៥ពិន្ទុ) ៣.ហេតុអ្វីបានជាតុលាការយកមេដឹកនាំកំពូលរបស់ខ្មែរក្រហម ដែលកាន់អំណាច

នៅឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ទៅកាត់ទោស?

(១៥ពិន្ទុ) ៤.ចូរអ្នកពិពណ៌នាពីការខិតខំចរចារសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជា។

(២០ពិន្ទុ) ៥.ចូរអ្នកពិពណ៌នាពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅកម្ពុជាឆ្នាំ១៩៩៣ ដល់សព្វថ្ងៃ។

អត្ថាកំណែ

១.គោលនយោបាយអព្យាក្រឹត្យ

- គោនយោបាយអព្យាក្រឹត្យ
  គឺជាការរួមរស់សន្តិសហវិជ្ជមានជាមួយបណ្តាលប្រទេសនានាលើពិភពលោក
  ដោយនៅកណ្តាលមិនប្រកាន់មនោគមន៍វិទ្យាសេរី ឬមនោគមន៍វិទ្យាកុម្មុយនិស្ត។

- មូលហេតុនៃការអនុវត្តនយោបាយអព្យាក្រឹត
  - អនុវត្តតាមសេចក្តីសម្រេចនៃសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ដែលស្នើដោយសហភាពសូវៀតនិងចិន
  - កម្ពុជាចង់រួមរស់ដោយសន្តិភាពសហវិជ្ជមានជាមួយបណ្តាលប្រាទេសនានាលើពិភពលោកពិសេសប្រទេសជិតខាង
- ការពង្រឹងនយោបាយអព្យាក្រឹត្យ
  - ថ្ងៃទី១៨ មីនា១៩៥៥ ក្នុងដំណើរទស្សនកិច្ចនៅឥណ្ឌាសម្តេចនរោត្តម សីហនុ
    បានចុះហត្ថលេខាជាមួយលោកនេរុ លើសេចក្តីប្រកាសរួមមួយ
    គឺការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព
  - ថ្ងៃទី១៨ ដល់២៤មេសា ១៩៥៥ សន្និសីទកំពូលប្រទេសអាស៊ី អាហ្វ្រិកនៅទីក្រុងបានឌុង (ឥណ្ឌូនេស៊ី) សម្តេចនរោត្តម សីហនុ
    បានធ្វើសេចក្តីអះអាងពីកម្មវិធីនយោបាយអព្យាក្រឹត្យរបស់កម្ពុជា
    និងការរួមរស់ជាមួយគ្នាដោយសន្តិភាព
  - ថ្ងៃទី១៤ ធ្នូ ១៩៥៥ ក្នុងពេលដែលកម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ
    តំណាងរាជរដ្ឋាភិបាលកម្ពុជាបបានប្រកាសពីមាគ៌ានយោបាយអព្យាក្រឹត្យនៃកម្ពុជា។
- លទ្ធផលនៃការប្រកាន់នយោបាយអព្យាក្រឹត្យ
  - ✓ ដំហានដំបូង
    - ធ្វើឲសេដ្ឋកិច្ចកម្ពុជាល្បីរីកលូតលាស់ក្នុងតំបន់
    - មានការអភិវឌ្ឍប្រទេសលើគ្រប់វិស័យ

- ប្រទេសកម្ពុជាបានសុខសន្តិភាពរយៈពេល១៥ឆ្នាំ
- ក្រុមអ្នកប្រឆាំងពុំហ៊ានប៉ះពាល់ និងទទួលស្គាល់នយោបាយអព្យាក្រឹត្យ

✓ ដំណាក់កាលសង្គ្រាមត្រជាក់ ៖ ឥទ្ធិពលនៃសង្គ្រាមត្រជាក់ មហាអំណាចមនោគមវិជ្ជាទាំងពីរ ពុំទុកកម្ពុជាក្នុងមាគ៌ាសន្តិភាព ឯសហរដ្ឋអាមេរិក ថៃ វៀតណាមខាងត្បូង និងវៀតណាមខាងជើង ធ្វើសកម្មភាពប្រឆាំងទៅនិងនយោបាយអព្យាក្រឹត្យ ដែលធ្វើឱ្យកម្ពុជា
អនុវត្តនយោបាយអព្យាក្រឹត្យមិនចំទិសដៅ និងនាំកម្ពុជាធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាម។

✓ ការដាក់នយោបាយអព្យាក្រឹត្យ ៖ នយោបាយអព្យាក្រឹត្យត្រូវបានបញ្ចប់ដោយកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុពីប្រមុខរដ្ឋ ថ្ងៃទី ១៨ មីនា ១៩៧០ ដោយលោក
លន់ នល់ និងសេរីមតៈ។

(មានមតិផ្សេងទៀត)

២.មូលហេតុដែលបណ្តាលឲ្យរបបសាធារណរដ្ឋខ្មែរដួលរលំ ៖

- ប្រជាជននៅទីក្រុងភ្នំពេញ និងនៅតំបន់រំដោះនឿយណាយនិងរបបសាធារណរដ្ឋខ្មែរ ដែលពោលពេញដោយភាពអាប់អួរ
- ប្រជាជននៅក្រុងភ្នំពេញរស់នៅដោយបាត់បងការងារ កង្វះចំណីអាហារ កង្វះជម្រក ទំនិញឡើងថ្លៃ អតិផរណា អនាធិបតេយ្យ ចោរកម្ម អយុត្តិធម៌ ពុករលួយ បនល្បែងពាណា ភាពច្របូកច្របល បាតុកម្ម កុប្បកម្មពេញទីក្រុង
- រដ្ឋាភិបាលលន់ នល់គ្រប់គ្រងបានតែទីក្រុង និងទីប្រជុំជន ឯជនបទស្រែចម្ការគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា (ខ្មែរក្រហម)
- សេដ្ឋកិច្ចរបបសាធារណរដ្ឋខ្មែរមិនដំណើរការ របបនេះរស់ដោយសារជំនួយពីសហរដ្ឋអាមេរិក
- ការដឹកជញ្ជូនស្បៀង សព្វាវុធ របស់សហរដ្ឋអាមេរិកដើម្បីជួយរដ្ឋាភិបាលលោកលន់ នល់ត្រូវបានខ្មែរក្រហមកាត់ផ្តាច់ទាំងផ្លូវទឹក និងផ្លូវគោក
- ខ្មែរក្រហមធ្វើការហ៊ុំព័ទ្ធទីក្រុងភ្នំពេញ និងរឹតបន្តឹងការនាំស្បៀងចូល
- ការចរចារវាងតំណាងសាធារណរដ្ឋខ្មែរ និងតំណាងសម្តេចនរោត្តម សីហនុត្រូវបរាជ័យ
- ថ្ងៃទី០១ មេសា ១៩៧៥ លោកលន់ នល់បានភៀសខ្លួនទៅសហរដ្ឋអាមេរិក
- ថ្ងៃទី១៧ មេសា ១៩៧៥ កងទ័ពខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ។

- (មានមតិផ្សេងទៀត)

៣.បានជាតុលាការយកមេដឹកនាំកំពូលរបស់ខ្មែរក្រហមទៅកាត់ទោសព្រោះ ៖

- មេដឹកនាំខ្មែរក្រហមទាំងនេះបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មក្នុងពេលកាន់អំណាចមាន
  - ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
  - ឧក្រិដ្ឋកម្មប្រឆាំងនិងមនុស្សជាតិ
  - ឧក្រិដ្ឋកម្មប្រឆាំងនិងសង្គ្រាម
  - ឧក្រិដ្ឋកម្មប្រឆាំងនិងអ្នកទទួលបានការការពារអន្តរជាតិ
  - ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្ស៊ីណែវឆ្នាំ១៩៤៩
  - ការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ជាតិ
- ការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនេះដើម្បី
- ផ្តល់យុត្តិធម៌ ផ្តល់ភាពស្ងប់ចិត្ត ការផ្សះផ្សារវិបត្តិផ្លូវចិត្តដល់ជនរងគ្រោះដែលរស់រានមានជីវិត
  - ជាមេរៀនគំរូដល់មេដឹកនាំជំនាន់ក្រោយ កុំគ្រាប់តាម និងដើម្បីទប់ស្កាត់ កុំឱ្យរបបនេះកើតមានជាថ្មីម្តងទៀត
  - ធ្វើការបង្រួបបង្រួមជាតិ ផ្សះផ្សារជាតិ
  - ផ្តល់យុត្តិធម៌ដល់ជនរងគ្រោះដែលបានបាត់ជីវិត
  - ជាការដាក់ទណ្ឌកម្មដល់អ្នកដែលបានប្រព្រឹត្តកុំឱ្យរួចខ្លួន។

៤.ការខិតខំចរចារសន្តិភាព និងការបង្រួបបង្រួមជាតិនៅកម្ពុជារួមមាន ៖

- នៅខែវិច្ឆិការ១៩៨៤ ប្រទេសបារាំងបានរៀបចំគម្រោងជំនួបរវាងសម្តេចនរោត្តម សីហនុ និងតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា
- ឆ្នាំ១៩៨៤ សភាពការណ៍នយោបាយនៅអាស៊ី អនុគ្រោះដល់ការចរចារសន្តិភាពនៅកម្ពុជា
- ខែកក្កដា ឆ្នាំ១៩៨៧ ទស្សនកិច្ចជាផ្លូវការរបស់រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ីនៅវៀតណាមពិភាក្សាលើរូបមន្តនៃការជួបគ្នា រវាងបណ្តាលភាគីខ្មែរបដិបក្សទាំងពីរ ការជួបគ្នារវាងភាគីខ្មែរ និងប្រទេសពាក់ព័ន្ធដើម្បីដោះស្រាយ បញ្ហានយោបាយនៅកម្ពុជា ដូចជា ៖

- ឆ្នាំ១៩៨៧ ជំនួបកំពូលរវាងអាមេរិក និងសហភាពសូវៀតធ្វើឱ្យសភាពការណ៍នៅកម្ពុជាធូរស្រាល
- ខែសីហា និងខែតុលា ១៩៨៧ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដាក់សំណើរសន្តិភាព និងបង្រួបបង្រួមជាតិទៅកាគីនរោត្តម សីហនុ
- ថ្ងៃទី០២ ធ្នូ ១៩៨៧ ជំនួបលើកទីមួយរវាងសម្តេចនរោត្តម សីហនុ និងលោកហ៊ុន សែន
- ជំនួបលើកទី២ សម្តេចនរោត្តម សីហនុ និងលោកហ៊ុន សែនថ្ងៃទី២១,២២ ខែមករា ១៩៨៨ នៅប្រទេសបារាំង ជំនួបលើកទី៣,៤,៥ សម្តេចនរោត្តម សីហនុបានលុបចោល
- វេទិកាសម្តេចនរោត្តម សីហនុ និងឯកឧត្តមហ៊ុន សែនប្រព្រឹត្តទៅនៅទីក្រុងប៉ារីស ហ្សាកាតា និងប៉ាតាយ៉ា ដើម្បីដោះស្រាយនយោបាយកម្ពុជា
- ថ្ងៃទី២៦ កញ្ញា១៩៨៩ កងទ័ពវៀតណាមដកចេញពីកម្ពុជា
- រដ្ឋាភិបាលកម្ពុជាខិតខំ និងមានការគាំទ្រពីមតិជាតិ និងអន្តរជាតិដើម្បីទប់ទល់កងទ័ពខ្មែរក្រហម និងកម្លាំងតស៊ូពីរក្រុមទៀត
- ថ្ងៃ៣០កក្កដា ៣០ សីហា ១៩៨៩ នៅទីក្រុងប៉ារីស សហប្រធាន (ឥណ្ឌូចិន+បារាំង) បានបង្កើតក្រុមព្រឹក្សាជាតិជាន់ខ្ពស់ (SNC) នៅថ្ងៃទី១០ កញ្ញា ១៩៩០ ដែលមានសមាជិក១២រូប (៦រូបមកពីភាគីរដ្ឋកម្ពុជា និង៦រូបទៀតមកពីសម្ព័ន្ធត្រីភាគី) ក្រុមព្រឹក្សាជាតិជាន់ខ្ពស់ប្រជុំនៅទីក្រុងបឹងកក បារាំង ក្រុងញូយ៉ក ហ្សាកាតា ប៉ាតាយ៉ា និងប៉េកាំង ដើម្បីរកដំណោះស្រាយបញ្ចប់សង្គ្រាមនៅកម្ពុជា
- ថ្ងៃ២៣,២៤ មិថុនា ១៩៩១ ភាគីទាំងបួនបានស្រោះស្រួលគ្នាដោះស្រាយបញ្ហាជាតិ
- ២៣ តុលា ១៩៩១ សន្និសីទទីក្រុងប៉ារីសបានព្រមព្រៀង ដើម្បីចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាព ហើយវិបត្តិនយោបាយនៅកម្ពុជាត្រូវបានបញ្ចប់
- ថ្ងៃទី២៣,២៨ ឧសភា ១៩៩៣ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ត្រូវបានរៀបចំឡើងដោយអ៊ុន តាក់
- នយោបាយឈ្នះ១របស់សម្តេច ហ៊ុន សែន នៅចុងឆ្នាំ១៩៩៨ សមាហរណកម្មកម្លាំងខ្មែរក្រហម ឱ្យចូលមករួមរស់ជាមួយរដ្ឋាភិបាលដែលនាំសន្តិភាពពេញលេញមកឱ្យកម្ពុជា។

- ○ មានមតិត្រឹមត្រូវផ្សេងទៀត។

៥.ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅកម្ពុជាឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន៖

- នយោបាយឈ្នះ១ បានធ្វើឲ្យរាជរដ្ឋាភិបាលដាក់ចេញនៅយុត្តិសាស្ត្រត្រីកោណ និងយុត្តិសាស្ត្រចតុកោណក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម តាមរយៈកំណែទម្រង់សាធារណៈ លុបបំបាត់អំពើពុករលួយ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

- ចំពោះវិស័យសេដ្ឋកិច្ច
  - បង្កើនទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន និងមហាអំណាចធំៗលើពិភពលោក
  - កសិកម្មមានការរីកចម្រើន ដោយរដ្ឋាភិបាលយកចិត្តទុកដាក់ ក្នុងការបង្កើតប្រព័ន្ធធារាសាស្ត្រ កាបង្កាត់ពូជ ការប្រើប្រាស់ដី
  - អនុវត្តសេដ្ឋកិច្ចប្រព័ន្ធទីផ្សារសេរី កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
  - ជំរុញ និងលើកទឹកចិត្តការវិនិយោគពីឯកជន បង្កើនទុនពីបរទេស
  - ជំរុញវិស័យឧស្សាហកម្មឲ្យមានការរីកចម្រើន ផ្នែករោងចក្រសហគ្រាសតូចធំជាច្រើន ពិសេសរោងចក្រវាយនភ័ណ្ឌសម្រាប់បង្កើនការងារដល់ប្រជាពលរដ្ឋ ចៀសវាងការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ
  - ជម្រុញឱ្យមានការយកចិត្តទុកដាក់លើវិស័យទេសចរណ៍ វប្បធម៌ និងទេសចរណ៍ធម្មជាតិ សម្រាប់ទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ
  - ធ្វើឱ្យអត្រាប្តូរប្រាក់មានស្ថេរភាព
  - កម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកឆ្នាំ២០០៤

- វិស័យសង្គម
  - ឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្នរាជរដ្ឋាភិបាលបានរៀបចំសណ្តាប់ធ្នាប់សង្គម រក្សាសន្តិសុខសុវត្ថិភាព និងសន្តិភាពពេញលេញ
  - ធ្វើឱ្យមានសមិទ្ធិផលជាច្រើនបានកើតឡើង ដូចជា ការកសាងសាលារៀន ចាប់ពីមត្តេយ្យសិក្សារហូតដល់វិទ្យាល័យ កសាងមន្ទីពេទ្យ ផ្លូវថ្នល់ ស្ពាន

ស្ពានអាកាស ប្រព័ន្ធធារាសាស្ត្រ ជាពិសេសសេដ្ឋកិច្ចមានការរីកចម្រើន និងធ្វើឱ្យប្រជាជនមានជីវភាពកាន់តែប្រសើរ។

- មានមតិត្រឹមត្រូវផ្សេងទៀត ។

ផ្នែកទី២

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ **សម័យប្រឡង៖.....**
វិញ្ញាសាប្រវត្តិវិទ្យា ថ្នាក់វិទ្យាសាស្ត្រពិត **មណ្ឌលប្រឡង៖ .....**
រយៈពេល៖ ៦០នាទី **ឈ្មោះបេក្ខជន៖ .....**
ពិន្ទុសរុប៖ ៥០ពិន្ទុ

<u>វិញ្ញាសាទី១</u>

១. តើស្តេចអង្គណាដែលទាមទារឯករាជ្យបានសម្រេចពីបារាំង? (៥ពិន្ទុ)

២. ក្រោយថ្ងៃ១៧ មេសា ១៩៧៥ តើខ្មែរក្រហមបានចេញអនុវត្តន៍គោលការណ៍សំខាន់ៗអ្វីខ្លះ? (១០ពិន្ទុ)

៣. តើអង្គការសហប្រជាជាតិបានជួយដោះស្រាយបញ្ហាអ្វីខ្លះដល់ប្រទេសកម្ពុជាចាប់តាំងប្រទេសកម្ពុជាចូលជា សមាជិក រហូតដល់បច្ចុប្បន្ន?(១០ពិន្ទុ)

៤. ចូររៀបរាប់អំពីសមិទ្ធផលសម័យសង្គមរាស្ត្រនិយម។ (១០ពិន្ទុ)

៥. ពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្ម? (១៥ពិន្ទុ)

<u>អត្រាកំណែ</u>

១. ស្តេចអង្គណាដែលទាមទារឯករាជ្យបានសម្រេចពីបារាំង គឺ សម្តេចព្រះនរោត្តម សីហនុ។)

២. ថ្ងៃ១៧ មេសា ១៩៧៥ ខ្មែរក្រហមអនុវត្តន៍គោលការណ៍ចំនួន៨ចំណុច
គោលការណ៍ទាំងនោះមានដូចជា៖

- ជម្លៀសប្រជាជនឲ្យចេញពីក្រុងភ្នំពេញទាំងអស់
- លុបបំបាត់ទីផ្សារ
- លុបបំបាត់ការប្រើប្រាស់និងចរាចរណ៍រូបិយប័ណ្ណ
- ផ្សឹកលោកសង្ឆក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ ហើយឱ្យទៅធ្វើស្រែ ចំការ នៅតំបន់មូលដ្ឋានជនបទ
- ប្រហារជីវិតមេដឹកនាំរបស់របបលន់ នល់
- បង្កើតសហករណ៍កម្រិតខ្ពស់ទូទាំងប្រទេស
- បណ្តេញជនជាតិកាគតិចវៀតណាមឲ្យចេញទាំងអស់
- បញ្ជូនទ័ពទៅតាមព្រំប្រទល់ជាពិសេសព្រំទល់វៀតណាម។

៣. អង្គការសហប្រជាជាតិបានជួយដោះស្រាយបញ្ហា ដល់ប្រទេសកម្ពុជាច្រើនដូចជា៖

- ១៥ មិថុនា ១៩៦២ ជួយដោះស្រាយរឿងក្តីប្រាសាទព្រះវិហារ
- ២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស
- ២៣-២៦ ឧសភា ១៩៩៣ រៀបចំការបោះឆ្នោតនៅកម្ពុជា
- ៧ កក្កដា ២០០៨ បញ្ជូលប្រាសាទព្រះវិហារក្នុងបញ្ជីបេតិកភណ្ឌពិភពលោក
- ក្រុមប្រឹក្សាសេដ្ឋកិច្ចនិង សង្គម (អប់រំសុខាភិបាល)

- ១៨ តុលា ២០១១ តុលាការអន្តរជាតិ បានបញ្ជាឲ្យកងទ័ពថៃនិងកម្ពុជាដកចេញ ពីប្រាសាទព្រះវិហារ។

៤. សមិទ្ធផលសម័យសង្គមរាស្ត្រនិយម

- វិស័យនយោបាយ
  - អនុវត្តនយោបាយអព្យាក្រឹត្យ ធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមានសន្តិភាពរយៈពេល១៥ឆ្នាំ (១៩៥៥-១៩៧០) ស្របពេលប្រទេសជិតខាងកំពុងតែ ជួបប្រទះសង្គ្រាម
  - កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ (១៤ ធ្នូ ១៩៥៥)
  - ឈ្នះក្នុងរឿងក្តីប្រាសាទព្រះវិហារ (១៥ មិថុនា ១៩៦២)
- វិស័យកសិកម្ម
  - រដ្ឋាភិបាលយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយពង្រីកផ្ទៃដីកសិកម្ម ការជ្រើសរើសពូជនិងការរៀបចំប្រព័ន្ធទឹក
  - ទិន្នផលរីកចម្រើនជាលំដាប់រួមមាន ផលិតផលស្រូវ កប្បាស ការចិញ្ចឹមសត្វ នេសាទ និងព្រៃឈើ
- វិស័យគមនាគមន៍
  - ពង្រីកកំពង់ផែភ្នំពេញនិងក្រុងព្រះសីហនុ
  - កសាងផ្លូវជាតិលេខ៤ ពីភ្នំពេញទៅក្រុងព្រះសីហនុ ប្រវែង២២៦គ.ម
  - ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង
  - កសាងអាកាសយានដ្ឋានអន្តរជាតិសៀមរាប
  - កសាងស្ពានជ្រោយចង្វារនិង ផ្លូវរថភ្លើងខ្សែរទី២ ពីភ្នំពេញទៅក្រុងព្រះសីហនុ ប្រវែង២៧០គ.ម

- ○ បានភ្ជាប់ខ្សែរទូរស័ព្ទជាមួយក្រុងតូក្យូ សាន់ហ្វ្រាន់ស៊ីស្កូ ក្រុងអូសាកា

➢ វិស័យពាណិជ្ជកម្មនិងឧស្សាហកម្ម

- ○ ក្រុមហ៊ុនពាណិជ្ជកម្មធំៗរបស់បារាំង និងសហរដ្ឋអាមេរិកបានដាក់វិនិយោគទុន នៅកម្ពុជា ដូចជា ក្រុមហ៊ុនញ្ជូរហែមពូរ អេសូ កាល់តិច និងសែល ក្រៅពីនេះមានក្រុមហ៊ុន អង់គ្លេស និងជប៉ុន ដែលបម្រើលើឥណទានសម្រាប់ពាណិជ្ជកម្ម។
- ○ ការប្រើប្រាស់ឥណទានសម្រាប់ពាណិជ្ជកម្មក្រៅប្រទេស កម្ពុជាបាន ប្រកួតប្រជែងជាមួយ មូលធនបារាំង អាមេរិក ជប៉ុន និងអង់គ្លេស
- ○ រាជរដ្ឋាភិបាលបង្កើតក្រុមហ៊ុនពាណិជ្ជកម្មថ្មីគឺ ក្រុមហ៊ុនអាហារ៉ណានីហ៉ារណ (សូណិចស៊ីម)
- ○ រាជរដ្ឋាភិបាលបង្កើតក្រុមហ៊ុនពីរទៀតគឺ សូ៉ាប៉ា និងសូណាត្រីម
- ○ រាជរដ្ឋាភិបាលបានកសាងរោងចក្រជាច្រើនដូចជា រោងចក្រវាយនភ័ណ្ឌ នៅកំពង់ចាម រោងចក្រ ក្តារបន្ទះ រោងចក្រដីឥដ្ឋ រោងចក្រកែវនៅចំការដូង រោងចក្រក្រដាសនៅឆ្លូង រោងចក្រស៊ីម៉ង់ចក្រទីង រោងចក្រក្រចៅ នៅដូនទាវ រោងចក្រស្ករសនៅកំពង់ត្រាច រោងចក្រស្រាលបៀល និង តម្លើងត្រាក់ទ័រនៅក្រុងព្រះសីហនុ។

➢ វិស័យវប្បធម៌

- ○ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យសិក្សាធិការជាតិ ដោយបណ្តុះបណ្តាលគ្រូបង្រៀន និងមានការកសាងសាលារៀនចាប់ពីបឋម សិក្សាដល់សាកលវិទ្យាល័យ។
- ○ លើកស្ទួងវិស័យកីឡា ដោយមានការបណ្តុះបណ្តាលកីឡាករគ្រប់ខេត្តក្រុង និងបានកសាងពហុ កីឡាដ្ឋានអូឡាំពិច

- ○ ខាងព្រះពុទ្ធសាសនា សម្តេចសីហនុ បានបង្កើតពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិមហាវិទ្យាល័យ

- ➢ វិស័យសង្គមកិច្ច
  - ○ មានការកសាងមន្ទីរពេទ្យដូចជា មន្ទីរពេទ្យគន្ធបុប្ផា ឱសថការល័យព្រះសុវាម្រឹត មហាវិទ្យា ល័យកូមិន្ទវិជ្ជាពេទ្យ មន្ទីរសម្ភពផ៉ះង៉ាង៉ាម មន្ទីរពេទ្យព្រះកុសម: (ពេទ្យលោកសង្ឆ) .....
  - ○ អភិវឌ្ឍជនបទប្រព្រឹត្តិទៅយ៉ាងសស្រាក់សស្រាំ ដូចជា ជីកអណ្តូងទឹក សង់ផ្ទះ ជីកស្រះ
  - ○ ផ្តល់សិទ្ធឲ្យស្ត្រីមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត។

៥. ពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្ម

- ➢ ភាពវិជ្ជមាន
  - ▪ ធ្វើឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច (កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍) និងសង្គម (វប្បធម៌ សិល្ប:)
  - ▪ អភិវឌ្ឍផ្នែកបច្ចេកវិទ្យាទំនើប (បង្កើតគ្រឿងម៉ាស៊ីនស្វ័យប្រវត្តិផ្សេងៗ
  - ▪ មានការរីកចម្រើនផ្នែកទូរគមនាគមន៍អន្តរជាតិ (ទូរស័ព្ទ ទូរទស្សន៍ អ៊ីនធីណេត)
  - ▪ បង្កើតសេដ្ឋកិច្ចទីផ្សារសេរី ដោយមានការប្រកួតប្រជែង)
  - ▪ មានទំនាក់ទំនងល្អ នៅក្នុងការទំនាក់ទំនងការបរទេស
  - ▪ បង្កើតកិច្ចសហប្រត្តិបត្តិការដើម្បីដោះស្រាយបញ្ហាដែលបង្ការគម្រាមកំហែងដល់ពិភពលោក ទាន់ពេលវេលា(បរិស្ថាន ជំងឺឆ្លង សន្តិសុខ កំណើនប្រជាជន ការជួញដូរមនុស្ស ជនភៀសខ្លួន)
  - ▪ មានភាពងាយស្រួលក្នុងការធ្វើបម្លាស់ប្តូរទីលំនៅ ក្នុងសាកលលោក។
- ➢ ភាពអវិជ្ជមាន

- ប្រទេសតូចតាចត្រូវបាត់បង់អធិបតេយ្យភាព របស់ខ្លួននៅចំពោះមុខប្រទេសមហាអំណាច (អ៊ុយក្រែន អ៊ីរ៉ាក់ លីប៊ី.....)
- មានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ពីសំណាក់ប្រទេសមហាអំណាចមកលើប្រទេសទន់ខ្សោយ ដែលធ្វើឲ្យមានការផ្លាស់ប្តូរនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ចនិងសង្គម
- បង្កឲ្យមានសង្គ្រាមរវាងរដ្ឋនិងរដ្ឋ (អ៊ីស្រាអែលនិង ប៉ាលេស្ទីន)
- ធ្វើឲ្យមានការរីកសាយភាយយ៉ាងខ្លាំង នូវបច្ចេកវិទ្យាយោធាទំនើប ដែលបង្ការគម្រោមកំហែងដល់ពិភពលោក
- កំណើនប្រជាជនធ្វឲ្យមានបញ្ហាចោទដល់សេដ្ឋកិច្ចនិងសង្គម
- ប្រព័ន្ធផ្ការយណបក៏អាចជាប្រភពបញ្ហា ដែលធ្វើឲ្យរដ្ឋាភិបាលរិតតែបាត់បង់ប្រសិទ្ធិភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន។

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ **សម័យប្រឡង៖.....**
វិញ្ញាសាប្រវត្តិវិទ្យា ថ្នាក់វិទ្យាសាស្ត្រពិត **មណ្ឌលប្រឡង៖ .....**
រយៈពេល៖ ៦០នាទី **ឈ្មោះបេក្ខជន៖ .....**
ពិន្ទុសរុប៖ ៥០ពិន្ទុ

<u>វិញ្ញាសាទី២</u>

១. តើប្រាសាទព្រះវិហារចូលជាសម្បត្តិបតិកភណ្ឌពិភពលោកនៅឆ្នាំណា ?(៥ពិន្ទុ)

២. ក្រោយសង្គ្រាមលោកលើកទី២
តើតំបន់អាស៊ីអាគ្នេយ៍មានការលេចឡើងនូវចលនាតស៊ូប៉ុន្មានរូបភាព ? អ្វីខ្លះ ?(១០ពិន្ទុ)

៣. ដូចម្តេចដែលហៅថាសង្គ្រាមត្រជាក់ ? ចូរពន្យល់ ។(១០ពិន្ទុ)

៤. តើមូលហេតុអ្វីខ្លះ
ដែលនាំឱ្យមានការចម្រើនៃសាកលភាវូបនីយកម្មលើពិភពលោក ?ចូរពន្យល់ ។(១០ពិន្ទុ)

៥. តើកត្តាអ្វីខ្លះ ដែលនាំឱ្យកម្ពុជាអាចបញ្ចប់សង្គ្រាមស៊ីវិលតាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នាំមកនូវសន្តិភាព និងការអភិវឌ្ឍន៍ជាតិ ?(១៥ពិន្ទុ)

<u>អត្រាកំណែ</u>

១. ប្រាសាទព្រះវិហារចូលជាសម្បត្តិបតិកភណ្ឌពិភពលោកនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៧។

២. ក្រោយសង្គ្រាមលោកលើកទី២ តំបន់អាស៊ីអាគ្នេយ៍មានការលេចឡើងនូវចលនាតស៊ូជាពីររូបភាពគឺ៖

- ចលនាតស៊ូបែបជាតិនិយម៖ ជាចលនាតស៊ូបែបប្រជាធិបតេយ្យ មានទិសដៅកសាងនយោបាយ សេដ្ឋកិច្ច សង្គម ដោយសន្សឹមៗ ក្រោយពេលទទួលឯករាជ្យ ស្រប់តាមប្រទេសលោកខាងលិច។ ចលនាទាំងនោះមាននៅដូចជា កម្ពុជា ឥណ្ឌូនេស៊ី ម៉ាឡេស៊ីជាដើម។
- ចលនាតស៊ូបែបប្រឆាំងនឹងមូលធននិយមនិងសក្តិភូមិនិយម៖ ដឹកនាំដោយពួកកុម្មុយនិស្ត និយមប្រឆាំនឹងពួកម្ចាស់អាណានិគមនិយម មានទិសដៅកសាងអំណាចប្រជាជន និងមូលដ្ឋានសង្គមនិយម នឹងប្រែក្លាយជារដ្ឋកុម្មុយនិស្តនិយម។ ចលនាទាំងនេះកើតមាននៅប្រទេសវៀតណាម និងប្រទេសឡាវ។

៣. ដែលហៅថាសង្គ្រាមត្រជាក់ គឺជាសង្គ្រាមមដែលធ្វើការប្រណាំងប្រជែងខាងផ្នែកសេដ្ឋកិច្ច មនោគមវិជ្ជា នយោបាយ បច្ចេកវិទ្យា និងការផលិតសញ្ញាវុធទំនើប រវាងប្លុកកុម្មុយនិស្ត (សហភាពសូវៀត) និងប្លុកសេរី (សហរដ្ឋអាមេរិក)ជាអ្នកបង្កឡើង។ ចំណុចចាប់ផ្តើមនៃសង្គ្រាមត្រជាក់

- ការបែងចែកទឹកដីគ្រប់គ្រងប្រទេសអាឡឺម៉ង់ជាពីរ ក្រោយសង្គ្រាមលោកលើកទី២
- ការកសាងជញ្ជាំងក្រុងប៊ែរឡាំង
- ការបង្កើតអង្គការអ្ងតង់ និងសន្ធិសញ្ញាវ៉ាសូវី
- ការបង្កើតទ្រឹស្តីទ្រូម៉ាន់ (ផែនការម៉ាសាល់) និងអង្គការសេដ្ឋកិច្ចកូមេកុង។
- សង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ទៅវិញនៅឆ្នាំ១៩៩១នៅពេលដែលសហភាពសូវៀតបានដួលរលំនិងបាត់បង់ឥទ្ធិពលដ៏ខ្លាំងខ្លារបស់ខ្លួននៅលើឆាកអន្តរជាតិតទៅទៀត។
  (ចម្លើយផ្សេងទៀត)

៤. កត្តាដែលនាំឱ្យមានសកលភាវូបនីយកម្មលើពិភពលោកមានដូចជា៖

- ប្រទេសនៅលើសកលលោកកាន់តែមានទំនាក់ទំនងជាមួយគ្នាខ្លាំងឡើងៗ ខាងផ្នែកសេដ្ឋកិច្ច នយោបាយ វប្បធម៌ឱ្យមានភាពស្និតរមួត។
- អស្ថិរភាពនៃការរីកម្រើនលើវិស័យសេដ្ឋកិច្ច របស់បណ្តាប្រទេសនានានៅលើពិភពលោក
- បង្កើនចំណងមិត្តភាពជាមួយបណ្តាប្រទេសនៅលើសកលលោក ដើម្បីថែរក្សា និងការពារសន្តិភាពពិភពលោក
- កំណើនយ៉ាងខ្លាំងនូវបម្លាស់ទីប្តូរទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋនៅលើសកលលោក
- ការរីកចម្រើនយ៉ាងខ្លាំងនុវប្រព័ន្ធទំនាក់ទំនងទូរគមន៍អន្តរជាតិ
- ការរីកចម្រើនសាយភាយយ៉ាងខ្លាំងនូវបច្ចេកវិទ្យាយោធាទំនើប ដែលជានិច្ចជាកាលបានក្លាយចជាឧបករណ៍នយោបាយពិភពលោក
- បញ្ហារួមជាច្រើនបានកើតឡើង ដែលទាមទារឱ្យមានការសម្រេចចិត្តដោះស្រាយបញ្ហាទាំងនេះតាមរយៈថ្នាក់ដឹកនាំរដ្ឋាភិបាល អង្គការអន្តរជាតិ សហគមន៍អន្តរជាតិជាដើម។ ចម្លើយផ្សេងទៀត

៥. កត្តានាំឱ្យកម្ពុជាអាចបញ្ចប់សង្គ្រាមស៊ីវិលតាមរយៈការចរចាសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ នាំមកនូវសន្តិភាព និងការអភិវឌ្ឍន៍ជាតិមានដូចជា៖

- **កត្តាខាងក្នុង**
  - គូភាគីទំនាស់នៅកម្ពុជា ឈប់ទទួលបានការគាំទ្រ និងជំនួយផ្សេងៗដល់ការធ្វើសង្គ្រាម
  - ការធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញពីសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ទៅជារដ្ឋកម្ពុជាអនុគ្រោះដល់ការចរចារជាមួយភាគទំនាស់ទាំងអស់នៅកម្ពុជា
  - ភាពនឿយនាយសង្គ្រាមរបស់មេដឹកនាំ និងប្រជាជន ដែលពុំទទួលបានផលប្រយោជន៍អ្វីសោះ
  - ធនៈមេដឹកនាំក្នុងការបញ្ចប់ទំនាស់មានដូចជា សម្តេច នរោត្តម សីហនុ និងសម្តេច ហ៊ុន សែន តាមរយៈជំនួបចរចារគ្នាជាច្រើនលើកដូចជា នៅហ្វ្រេអង់តាជីន័រប្រទេសបារាំងថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៨៧

និងជាបន្តបន្ទាប់ទៀតនៅបារាំង ឥណ្ឌូនេស៊ី ជប៉ុន ថៃ ចិន និងសហរដ្ឋអាមេរិកជាដើម រហូតដល់មានកិច្ចចរចារជាលើកចុងក្រោយដែលធ្វើឡើងនៅទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលគូភាគីជម្លោះនៅកម្ពុជា ចាប់ដៃគ្នាដើម្បីបញ្ចប់ជម្លោះប្រដាប់អាវុធនៅកម្ពុជា ដោយមានប្រទេសជាច្រើនចូលរួមជាសាក្សី។

- ការយល់ព្រមឱ្យមានការដកកងទ័ពវៀតណាមចេញពីទឹកដីកម្ពុជា នៅឆ្នាំ១៩៨៩។

- **កត្តាខាងក្រៅ**

  - បរិបទពិភពលោកនៅពេលនោះកំពុងឈានទៅរកការបញ្ចប់សង្គ្រាមត្រជាក់ ដែលអនុគ្រោះដល់នយោបាយពិភពលោក ក៏ដូចជាប្រទេសកម្ពុជា
  - កំណែទម្រង់ពេរ៉ូស្រ្តយការនាំទៅរកការដួលរលំសហភាពសូវៀត និងប្រទេសប្រកាន់យករបបកុម្មុយនិស្តផ្សេងទៀត ជាពិសេសនៅអឺរ៉ុបខាងកើត
  - ជំនួបរវាងប្រទេសមហាអំណាច ជាពិសេសប្រទេសពាក់ព័ន្ធក្នុងទំនាស់នៅកម្ពុជា បានជួបចរចារគ្នាដើម្បីស្វែងរកការបញ្ចប់ទំនាស់នៅកម្ពុជាតួយ៉ាង ដូចជាសន្និសិទ្ធអន្តរជាតិស្តីពី កម្ពុជា សម័យប្រជុំលើកទី១ នៅថ្ងៃទី៣០ ខែកក្តដា ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៨៩ នៅប៉ារីស ដែលមានបារាំង និងឥណ្ឌូនេស៊ីជាសហប្រធាន និងលើកទី២ ទទួលបានជោគជ័យតាមរយៈ កិច្ចព្រមព្រៀងទីក្រុងប៉ារីដ ថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩១ដែលទទួលស្គាល់ដោយស្ថាប័នអន្តរជាតិផ្សេងៗ។
  - ប្រទេសមហាអំណាចយល់ព្រមបញ្ឈប់ការផ្តល់ជំនួយដល់ភាគីទំនាស់នៅកម្ពុជា និងដាក់គំនាប ឱ្យមានការចរចារវាងភាគីទំនាស់ទាំងសងខាង គឺរដ្ឋកម្ពុជា និងចលនាត្រីភាគី។
  - កម្ពុជា ឆ្នាំ១៩៨៩ ការផ្តល់អំណាចដល់រដ្ឋកម្ពុជាដើម្បីចរចារជាមួយភាគីទំនាស់ផ្សេងៗ
  - **ចម្លើយផ្សេងទៀត។**

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ **សម័យប្រឡង៖.....**
វិញ្ញាសាប្រវត្តិវិទ្យា ថ្នាក់វិទ្យាសាស្ត្រពិត **មណ្ឌលប្រឡង៖ .....**
រយៈពេល៖ ៦០នាទី **ឈ្មោះបេក្ខជន៖ .....**
ពិន្ទុសរុប៖ ៥០ពិន្ទុ

<u>វិញ្ញាសាទី៣</u>

១. តើព្រះមហាក្សត្រខ្មែរអង្គណាជាអ្នកពឹងបព្វជិតកាតូលិក ឱ្យជួយទាក់ទងបារាំង?

២. មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ បែងចែកប្រជាជនជាប៉ុន្មាន? អ្វីខ្លះ?

៣. មូលហេតុអ្វីខ្លះដែលធ្វើឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ?

៤. ហេតុអ្វីបានជាសហរដ្ឋអាមេរិកក្លាយជាមហាអំណាចសេដ្ឋកិច្ចក្រោយសង្គ្រាមលោកលើកទី២?

៥.ហេតុអ្វីបានជាគេនិយាយថាប្រទេសកម្ពុជានាសម័យសង្គមរាស្ត្រនិយមជា“កោះសន្តិភាព”? ចូររកអំណះអំណាង មកបញ្ជាក់។

<u>អត្រាកំណែ</u>

១. ព្រះមហាក្សត្រខ្មែរដែលបានពឹងបព្វជិតកាតូលិក ឱ្យជួយទាក់ទងបារាំងគឺ ព្រះបាទ អង្គដួង។

២. មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ បែងចែកប្រជាជនជាពីរគឺ

- ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់ សំដៅលើប្រជាជនដែលរស់នៅក្នុងតំបន់គ្រប់គ្រងរបស់បក្សកុម្មុយនិស្តកម្ពុជា មុនថ្ងៃរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឬហៅថាតំបន់រំដោះ។
- ប្រជាជនថ្មី ឬប្រជាជន១៧មេសា សំដៅលើប្រជាជនដែលរស់នៅតាម តំបន់ទីប្រជុំជននានា និងក្នុងទីក្រុងភ្នំពេញ ហើយត្រូវបានជម្លៀសចេញទៅតាមពីទីក្រុង ទៅកាន់តំបន់រំដោះនានា ដើម្បីធ្វើការកសាង និងអភិវឌ្ឍសេដ្ឋកិច្ច។

៣. មូលហេតុដែលនាំឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមានដូចជា៖

- **កត្តាសង្គម**
  - ប្រជាជនបានងើបឡើងប្រឆាំងដោយរត់ចូលព្រៃ និងរត់ទៅប្រទេសវៀតណាម
  - ប្រជាជនកម្ពុជាស្អប់របបនេះព្រោះ ធ្វើបាប បង្អត់អាហារ បង្ខំឱ្យធ្វើការជាទម្ងន់គ្មានថ្នាំព្យាបាល គ្មានទីជម្រក គ្មានសម្លៀកបំពាក់គ្រប់គ្រាន់ ជាពិសេសកាប់សម្លាប់ប្រជាជនគ្មានត្រាប្រណី។
  - ពួកប៉ុល ពត លែងទុកចិត្តគ្នាឯង តាំងពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន ដែលប៉ុល ពត បានសម្លាប់ វន រ៉ែត ,កុយ ធួន,ញ៉ឹម រស់,សោភ៉ឹម...។
  - ការបង្កើតសង្គមភ័យខ្លាច មិនទុកចិត្តគ្នា និងមូលធនសង្គម
  - សង្គមដែលគ្មានវណ្ណៈ:មានតែនៅក្នុងការស្រមើស្រមៃរបស់ពួកទ្រឹស្តីនិយម និងគម្ពីរនិយមតែប៉ុណ្ណោះ។
- **កត្តានយោបាយ**
  - ១៩៧៥:ប៉ុលពតបានបង្ករសង្គ្រាមជាមួយវៀតណាមនៅតាមព្រំដែន

- នៅពាក់កណ្តាលឆ្នាំ១៩៧៧: ខ្មែរក្រហមបានបាញ់ផ្លោងចូលខេត្តចូវដុក ស្រុកហាទៀង និងខេត្តមួយចំនួនទៀតរបស់វៀតណាម
- នៅខែធ្នូឆ្នាំ១៩៧៧: វៀតណាមបានវាយប្រហារជាទ្រង់ទ្រាយធំមកលើកម្ពុជាប្រជាធិបតេយ្យ ដោយវៀតណាមបានកាន់កាប់បានតំបន់ចំពុះទា(ចំពុះសេក) ក្នុងខេត្តស្វាយរៀង
- កម្លាំងសាមគ្គីភាពនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលបង្កើតឡើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨
- ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩: ទ័ពវៀតណាម និងរណសិរ្សវាយឈ្នះពួកខ្មែរក្រហម។

- **សេដ្ឋកិច្ចធ្លាក់ចុះ**
  - ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន មហាលោតផ្លោះ មហាអស្ចារ្យ ការសម្លាប់អ្នកចេះដឹង ការប្រើកម្លាំងមនុស្សជំនួសបច្ចេកវិទ្យា ដែលនាំឱ្យសេដ្ឋកិច្ចធ្លាក់ចុះ
  - ការអនុវត្តរបស់ខ្មែរក្រហមបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាដើរថយក្រោយ។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៤. បានជាសហរដ្ឋអាមេរិកក្លាយជាមហាអំណាចសេដ្ឋកិច្ចសក្រោយសង្គ្រាមលោកលើកទី២ព្រោះ៖

- ការរួចផុតពីការបំផ្លាញនៃសង្គ្រាមលោកលើកទាំងពីរលើក ដោយសារកត្តាទីតាំងភូមិសាស្ត្ររបស់សហរដ្ឋអាមេរិកនៅឆ្ងាយពីទ្វីបអឺរ៉ុបរាប់ពាន់គីឡូម៉ែត្រ
- សហរដ្ឋអាមេរិកបានក្លាយជាម្ចាស់បំណុល និងម្ចាស់ជំនួយចំពោះការស្តារសេដ្ឋកិច្ចឡើងវិញរបស់បណ្តា ប្រទេសនៅទ្វីបអឺរ៉ុប។
- ការពង្រីកទីផ្សារសេដ្ឋកិច្ចរបស់ខ្លួនទៅកាន់តំបន់អឺរ៉ុប ក្រោយបញ្ចប់សង្គ្រាមភ្លាមតាមរយៈការនាំចូលទំនិញ និងសម្ភារៈប្រើប្រាស់ផ្សេង ធ្វើឱ្យអាមេរិកចំណេញប្រាក់វាល់លានដុល្លា។
- ការពង្រីកផ្នែកដឹកជញ្ជូន លើវិស័យកសិកម្ម អភិវឌ្ឍវិស័យឧស្សាហកម្ម និងបច្ចេកវិទ្យាទំនើបៗ ដើម្បីប្រកួតប្រជែងជាមួយសហភាពសូវៀត។

- ការពង្រីកឥទ្ធិពលនយោបាយរបស់ប្រទេស ទៅកាន់ទ្វីបអាស៊ី និងតតិយលោកប្រទេសកាន់តែខ្លាំងជាមុន
- **មានចម្លើយត្រូវផ្សេងទៀត។**

៥. ប្រទេសកម្ពុជានាសម័យសង្គមរាស្ត្រនិយមជាកោះសន្តិភាព

ពាក្យ«**សន្តិភាព**» មានន័យថា គ្មានបរិយាសកាសហិង្សា ។ ប្រទេសមួយ ប្រកបដោយសេចក្តីសុខ គ្មានអសន្តិសុខ ។ ពលរដ្ឋម្នាក់ៗមានសេចក្តីសុខទាំងកាយ សុខទាំងផ្លូវចិត្ត ។ គ្មានអារម្មណ៍ភ័យខ្លាច ថានឹងមានកើតសង្គ្រាមឡើយ។ រដ្ឋមួយមានការគោរពសិទ្ធិមនុស្ស បរិបូរណ៍ពេលគ្មានជំលោះរវាងក្រុមមួយ និងក្រុមមួយទៀត ឬ សហគមន៍មួយ និងសហគមន៍មួយទៀត។

ចំណែក«**កោះសន្តិភាព**»មានន័យថាប្រទេសមួយដែលរួចផុតពីភ្លើងសង្គ្រាម ខណៈពេលដែលប្រទេសជុំវិញនៅក្នុង តំបន់កំពុងតែឆាបឆេះដោយភ្លើងសង្គ្រាម។ កម្ពុជាជាកោះសន្តិភាពនាសម័យសង្គមរាស្ត្រនិយមព្រោះ៖

- កម្ពុជាអាចរួចផុតពីការទទួលយកមនោគមន៍វិជ្ជាសេរី ឬកុម្មុយនីស្ត ក្នុងរយៈពេល១៥ឆ្នាំ
- កម្ពុជាអាចចូលជាសមាជិកអង្គការសហប្រជាជាតិនាថ្ងៃទី១៤ ធ្នូ ១៩៥៥
- កម្ពុជាបានក្លាយជាសមាជិកអង្គការស្ថាប័នអន្តរជាតិនានា
- កម្ពុជាមានទំនាក់ទំនងអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិក្នុងកិច្ចសហប្រតិបត្តិការណ៍ផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម
- កម្ពុជាអាចទាក់ទាញវិនិយោគគិន ទេសចរ មកកម្ពុជា
- កម្ពុជាអាចស្ថិតក្នុងសន្តិភាពខណៈពេលប្រទេសវៀតណាម កំពុងស្ថិតក្នុងភ្លើងសង្គ្រាម
- ទីក្រុងភ្នំពេញ ជាទីក្រុងដែលមានដំណើរការពាណិជ្ជកម្ម ខណៈពេលដែលទីក្រុងហាណូយ និងបាងកក ជាទីក្រុងអនាធិបតេយ្យ
- វិស័យអប់រំមានការរីកចម្រើន
- កម្ពុជាមានវេលាក្នុងការអភិវឌ្ឍគ្រប់វិស័យដូចជា សុខាភិបាល កសិកម្ម សិប្បកម្ម ឧស្សាហកម្ម...
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ **សម័យប្រឡង៖.....**

វិញ្ញាសាប្រវត្តិវិទ្យា ថ្នាក់វិទ្យាសាស្ត្រពិត **មណ្ឌលប្រឡង៖ .....**

រយៈពេល៖ ៦០នាទី **ឈ្មោះបេក្ខជន៖ .....**

ពិន្ទុសរុប៖ ៥០ពិន្ទុ

<u>វិញ្ញាសាទី៤</u>

១. តើប្រទេសកម្ពុជាទទួលបានឯករាជ្យ ពេញលេញពីបារាំង នៅខែ ឆ្នាំ ណា? (៥ពិន្ទុ)

៣. តើមេដឹកនាំកំពូលៗ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមាននរណាខ្លះ?(៥ពិន្ទុ)

២. តើសង្គ្រាមស៊ីវិលពីឆ្នាំ ១៩៧០ ដល់១៩៧៥ បានធ្វើឱ្យកម្ពុជា ជួបប្រទះបញ្ហាអ្វីខ្លះ? (១០ពិន្ទុ)

៤. ចូររៀបរាប់ពី សមិទ្ធផលរបស់សម័យសង្គមរាស្ត្រនិយម។ (១៥ពិន្ទុ)

៥. ចូរពណ៌នាពីការស្តារបនាជាតិឡើងវិញ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ (១៥ពិន្ទុ)

<u>អត្រាកំណែ</u>

១.ប្រទេសកម្ពុជា ទទួលបានឯករាជ្យពេញលេញពីបារាំង នៅថ្ងៃទី០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣។

២. មេដឹកនាំកំពូលៗ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានដូចជា៖

- ខៀវ សំផន
- ប៉ុល ពត
- នួន ជា
- អៀង សារី
- និង សុន សេន

៣ សង្គ្រាមស៊ីវិលឆ្នាំ ១៩៧០ ដល់១៩៧៥ ធ្វើឱ្យប្រទេសកម្ពុជាជួបប្រទះនូវបញ្ហា ដូចជា៖

- សង្គ្រាមបានធ្វើឱ្យប្រជាជនកៀសខ្លួនពីជនបទទៅកាន់ក្រុងភ្នំពេញនិងទីប្រជុំជននានាដែលនាំឱ្យកើតភាពច្របូកច្របល់ អំពើចោរកម្ម និងភាពអាណាធិបតេយ្យ។
- ខូចខាតហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ស្ពានជាដើម
- រោងចក្រឧស្សាហកម្មត្រូវបំផ្លាញ
- ស្រែចម្ការត្រូវក្លាយជាចម្ការមីនដែលធ្វើឱ្យប្រជាជនមិនអាចធ្វើស្រែចម្ការបាន និងប្រឈមមុខនិងភាពអត់ឃ្លាន
- សាលារៀនជាច្រើនត្រូវបិតទ្វាដែលធ្វើឱ្យសិស្សនិងគ្រូមិនអាចទៅរៀនបានហើយធ្វើឱ្យបាត់បង់នូវធនធានមនុស្សសម្រាប់អភិវឌ្ឍន៍សង្គមជាតិ
- ប្រជាជនត្រូវបាត់បង់ជីវិតដោយសារសង្គ្រាម អស់ជាងមួយលាននាក់
- អំពើពុករលួយ ការកេងប្រវ័ញ្ចកើតមាននៅក្នុងសង្គមកាន់តែច្រើន
- **មានចម្លើយផ្សេងៗទៀត .....។**

៤. ការស្តាបនាជាតិឡើងវិញក្រោយ របបខ្មែរក្រហមមានដូចជា៖

- មានការស្តាបនាឡើងវិញ នូវវិស័យសេដ្ឋកិច្ច កសិកម្ម ពាណិជ្ជកម្ម និង ឧស្សាហកម្ម។
- ការបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃ ដើម្បីជួយដល់ស្ត្រីមេម៉ាយ ចាស់ជរា កុមារកំព្រា ដែលគ្មានគោក្របី ។

- ចំពោះវិស័យអប់រំ រដ្ឋាភិបាលបាន បង្កើតឱ្យមានសាលារៀនដំណើរការដូចពីមុនវិញ ហើយអនុវត្តតាមពាក្យស្លោកអ្នកចេះច្រើនបង្រៀនអ្នកចេះតិចអ្នកចេះតិចបង្រៀនអ្នកអត់ចេះ។
- មានការបញ្ជូននិស្សិតឱ្យទៅសិក្សានៅបរទេស
- ដើម្បីជួយអភិវឌ្ឍប្រទេសឱ្យមានការរីកចំរើន។
- ចំពោះវិស័យ នយោបាយ មានការបង្កើតនយោបាយបង្រួបបង្រួមជាតិ ហើយឈានទៅដល់ការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា (២៣ តុលា ឆ្នាំ១៩៩១)។
- មានចំលើយផ្សេងៗទៀត ....។

៥. សមិទ្ធផល របស់សម័យសង្គមរាស្ត្រនិយម មានដូចជា៖

❖ **វិស័យកសិកម្ម**

- រដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការពង្រីកផ្ទៃដីដាំដុះការជ្រើសរើសពូជក្នុងការដាំដំណាំ និងការប្រើប្រាស់ដីដាដើម។
- មានការធ្វើនយោបាយទឹក ដែលធ្វើឱ្យវិស័យកសិកម្មទទួលបាននូវទិន្នផលខ្ពស់
- ទិន្នផលស្រូវ កប្បាស កៅស៊ូ ការនេសាទ ព្រៃឈើនិងការចិញ្ចឹមសត្វមានការរីកចំរើន។

❖ **វិស័យគមនាគមន៍**

- ឆ្នាំ១៩៥៤ មានការពង្រីកកំពង់ផែភ្នំពេញ និងក្រុងព្រះសីហនុ
- ឆ្នាំ១៩៥៦ មានការកសាងផ្លូវជាតិលេខ៤ ដែលតភ្ជាប់ពីភ្នំពេញទៅព្រះសីហនុ ប្រវែង២២៦ គីឡូម៉ែត
- ឆ្នាំ១៩៥៦ មានការពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង
- ឆ្នាំ១៩៥៨ កសាងអាកាសយានដ្ឋានអន្តរជាតិ ខេត្តសៀរាប
- ឆ្នាំ១៩៦០ កសាងស្ពានជ្រោយចង្វារ និងផ្លូវរថភ្លើងខ្សែទី២ ពីភ្នំពេញទៅព្រះសីហនុ ប្រវែង២៧០ គីឡូម៉ែត
- ភ្ជាប់ខ្សែទូរសព្ទ ជាមួយក្រុងតូក្យូ សាន់ហ្វ្រាន់ស៊ីស្កូ និង អូសាកា ។

❖ **វិស័យវប្ផធម៌**

- រដ្ឋាភិបាលយកចិត្តទុកដាក់លើវិស័យសិក្សាធិការដោយមានការបណ្តុះបណ្តាលគ្រូបង្រៀន ។
- មានការកសាងសាលារៀនតាំងពីថ្នាក់បឋមសសិក្សារហូតដល់សាកលវិទ្យាល័យ។
- លើកស្ទួយវិស័យកីឡាទូទាំងខេត្តនិងបានបង្កើតពហុកីឡាដ្ឋានជាតិអូឡាំពិក។
- បញ្ជូននិស្សិតខ្មែរឱ្យទៅសិក្សានៅបណ្តាប្រទេសផ្សេងៗ ដូចជា
  នៅប្រទេសបារាំងជាដើម។

❖ **វិស័យឧស្សាហកម្ម**

- ឆ្នាំ១៩៥៥ ក្រុមហ៊ុនពាណិជ្ជកម្មធំ របស់បារាំង និងអាមេរិក បានដាក់ការវិនិយោគទន់នៅកម្ពុជា ដូចជា ក្រុមហ៊ុនញ្ជូរហ៊ែមពួរ អេសូ (Esso) កាល់តិច (CALTEX) និងមានក្រុមហ៊ុមរបស់ជប៉ុន និងអង់គ្លេសផងដែរ។
- ឆ្នាំ១៩៦៣ រដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្ម " ក្រុមហ៊ុនអារ៉ាហណានីរ៉ណ" និងសូណិចស៊ីម ហើយក្រោយមមកក៏មានការបង្កើតក្រុមហ៊ុនពីរទៀត គឺសូ៉ាប៉ា និងសូណាត្រីម។
- កសាងរោងចក្រវាយនភ័ណ្ឌកំពង់ចាម រោងចក្រក្តារបន្ទះ រោងចក្រកែវ រោងចក្រក្រដាសឆ្លូង រោងចក្រស៊ីម៉ង់ត៍ចក្រីទីង រោងចក្រស្ករ និងដំឡើងត្រាក់ទ័រជាដើម។

❖ **វិស័យសង្គមកិច្ច**

- យកចិត្តទុកដាក់លើសុខមាលភាពប្រជាជន ដោយបាកសាងនូវ
  មន្ទីរពេទ្យជាច្រើននៅក្នុង
  ប្រទេស ។
- លើកកម្ពស់ការអភិវឌ្ឍន៍ជនបទ ដូចជាការអនាម័យបរិស្ថាន លំនៅដ្ឋាន ...។
- **នៅមានចំលើយផ្សេងៗទៀត ។**

ទិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២០ **សម័យប្រឡង៖.....**
ទិញ្ញាសាប្រវត្តិវិទ្យា ថ្នាក់វិទ្យាសាស្ត្រពិត **មណ្ឌលប្រឡង៖ .....**
រយៈពេល៖ ៦០នាទី **ឈ្មោះបេក្ខជន៖ .....**
ពិន្ទុសរុប៖ ៥០ពិន្ទុ **លេខតុ៖.....លេខបន្ទប់.....**

<u>ទិញ្ញាសាទី៥</u>

១. តើរបបកម្ពុជាប្រជាធិបតេយ្យ បានវាយចូលគ្រប់គ្រងទីក្រុងភ្នំពេញ នៅថ្ងៃខែឆ្នាំណា? (៥ពិន្ទុ)

២. តើសេដ្ឋកិច្ចរបស់កម្ពុជា មុនការធ្វើរដ្ឋប្រហារសម្តេចសីហនុ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០? (១០ពិន្ទុ)

៣. តើប្រភពនៃទំនាស់ក្នុងតំបន់មជ្ឈឹមបូព៌ា លេចចេញមកពីបញ្ហាអ្វី? ចូររៀបរាប់។ (១០ពិន្ទុ)

៤. ចូរពណ៌នាពីនយោបាយឈ្នះ ឈ្នះ របស់សម្តេចហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា។

៥. ចូរបកស្រាយពី តួនាទីវប្បធម៌សន្ធនា ក្នុងសង្គមប្រជាធិបតេយ្យ

<u>អត្រាកំណែ</u>

១. របបកម្ពុជាប្រជាធិបតេយ្យ បានវាយចូលគ្រប់គ្រងទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

២. ស្ថានភាពសេដ្ឋកិច្ច មុនការរដ្ឋប្រហារ ទម្លាក់សម្តេចនរោត្តមសីហនុមានដូចជា ៖

- **កម្ពុជាជួបប្រទះនូវវិបត្តិសេដ្ឋកិច្ច**

– សកម្មភាពសេដ្ឋកិច្ចមានការរាំងស្ទះ ដោយសារមានការបាត់បង់ប្រាក់ចំណូល ចូលជាតិ ដែលវាកើតចេញពីការរត់ពន្ធ ខុសច្បាប់

– ការគ្រប់គ្រងវិស័យឧស្សាហកម្ម មិនបានល្អ ដែលនាំឱ្យមានវិបត្តិកើតឡើង

– ការចំណាយខ្វះតុល្យភាព

– កម្ពុជាជួបប្រទះវិបត្តិកសិកម្ម ដោយសារមានការខូចខាតនូវប្រពន្ធ័ធារាសាស្ត្រ

– ពាណិជ្ជកម្មជួបប្រទះជាមួយបញ្ហា ដោយសារការធ្វើជាតូបនីយកម្ម និងមានការបិទធនាគារខ្មែរ ហើយវានាំឱ្យមានវិបត្តិកើតឡើងកាន់តែច្រើន ។

– កម្ពុជាបាត់បង់ ការនាំចេញទៅក្រៅប្រទេស ដែលជាហេតុធ្វើឱ្យ កម្ពុជាជួបប្រទះនូវបញ្ហាធ្ងន់ធ្ងរ ។

– វិបត្តិសង្គម ក៏នាំឱ្យមានវិបត្តិសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ នឹងឈានដល់ការធ្វើរដ្ឋប្រហារ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ។

– **នៅមានចម្លើយផ្សេងទៀត .....** ។

៣. ប្រភពនៃទំនាស់ក្នុងតំបន់មជ្ឈឹមបូព៌ា លេចចេញមកពីបញ្ហាដូចជា ៖

- **បញ្ហាចម្រុះជាតិសាសន៍** នៅក្នុងតំបន់មជ្ឈឹមបូព៌ា មានបញ្ហាជម្លោះជាតិសាសន៍កើតឡើងយ៉ាងរំដើបរំដួល ហើយមានបញ្ហាទំនាស់ផ្ទៃក្នុងដ៏ស្មុគស្មាញ រវាងបណ្តាប្រទេសអារ៉ាប់ និងពួកជ្វីប និងជម្លោះក្នុងការដណ្តើមរដ្ឋប៉ាឡេស្ទីន ជាមួយអ៊ីស្រ្តាអែលផងដែរ ។

- **បញ្ហាសាសនា** នៅក្នុងតំបន់មជ្ឈឹមបូព៌ាមានប្រជាជនភាគច្រើន កាន់សាសនាអ៊ីស្លាម លើកលែងតែប្រទេសអ៊ីស្រ្តាអែល ដែលកាន់សាសនាផ្សេងៗ (អ៊ីយ៉ារ៉ូ) និងគ្រឹស្តសាសនា

ដែលធ្វើឱ្យជម្លោះ កើតឡើងកាន់តែខ្លាំង ។ ពិសេស គឺការចង់បានរបស់បណ្តាប្រទេសអារ៉ាប់ ដោយចង់ឱ្យមានការរួបរួមគ្នាតែមួយ ប៉ុន្តែការចង់បាននេះ កាន់តែធ្វើឱ្យបណ្តាប្រទេសអារ៉ាប់កាន់តែផុយស្រួយឡើង ។

- **ធនធានធម្មជាតិ** តំបន់មជ្ឈឹមបូព៌ាជាតំបន់ដែលសម្បូរទោដោយធនធានធម្មជាតិ ប្រេងកាត និងធនធានរ៉ែផ្សេងៗទៀត ហើយធនធានទាំងនោះ បានធ្វើឱ្យមហាអំណាចធំៗ ដណ្តើមគ្នាចង់គ្រប់គ្រងលើបណ្តាប្រទេសនៅតំបន់នេះ ។
- **នៅមានចម្លើយត្រឹមត្រូវផ្សេងៗទៀត។**

៤. ពណ៌នាពីនយោបាយឈ្នះ ឈ្នះ របស់សម្តេចហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា៖

- **វិស័យនយោបាយ**
  - ធ្វើសមាហរណកម្មកងទ័ពខ្មែរក្រហម ជាមួយរដ្ឋាភិបាល ដើម្បីធ្វើឱ្យមានកម្លាំងឯកភាពគ្នា ក្នុងការស្តារប្រទេស និងកសាងប្រទេសឡើងវិញ
  - ក្រោយពីដកកម្លាំងខ្មែរក្រហម បានដួលរលំ និង ធ្វើឱ្យតាមតំបន់ព្រំដែនមានសុវត្ថិភាពឡើងវិញ
  - ធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួន មកកម្ពុជាវិញ
  - បែងចែកដីធ្លី និង សិទ្ធិផ្សេងៗឱ្យបងប្អូនភៀសខ្លួន (ខ្មែរក្រហម)
  - បងប្អូនខ្មែរក្រហម ត្រូវផ្តល់មុខតំណែង និងតួនាទី ដែលធ្លាប់មានពីមុនមក
- **វិស័យសេដ្ឋកិច្ច**
  - មានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេស
  - ធ្វើឱ្យសេដ្ឋកិច្ចរបស់ប្រទេសមានការរីកចម្រើន និង មានការទាក់ទាញវិនិយោគទន់មកកម្ពុជា
  - មានការរីកចម្រើនលើវិស័យទេសចរ និង នាំកេរ្តិ៍ឈ្មោះល្បីល្បាញ មកកម្ពុជា
- **វិស័យសង្គម**

- ចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន បានធ្វើឱ្យកម្ពុជាមានសុខសន្តិភាពពេញលេញ
- ធ្វើឱ្យមានឯកភាពជាតិ និង ការបង្រួបបង្រួមជាតិ
- បណ្តុះនូវធនធានមនុស្ស សម្រាប់ធ្វើការអភិវឌ្ឍនៅកម្ពុជា
- ធ្វើឱ្យមានសមិទ្ធិផលផ្សេងៗ បានកើតឡើង ដូចជា ការចាប់ផ្តើមដំណើការសាលារៀនឡើងវិញ ពីមត្តេយ្យរហូតដល់វិទ្យាល័យ មន្ទីរពេទ្យ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន ប្រពន្ធ័ធារាស្ត្រ បានកើនឡើង។
- នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត .....។

៥. តួនាទីវប្បធម៌សន្ធនា ក្នុងសង្គមប្រជាធិបតេយ្យ៖

- វប្បធម៌សន្ធនា បានដើរតួនាទីយ៉ាងសំខាន់ ដែលធ្វើឱ្យប្រជាជន និងអ្នកដឹកនាំគិតពីប្រយោជន៍ជាតិជាធំ
- បញ្ជៀសបាននូវសង្គ្រាមពាក្យសម្តី ជំទាស់ផ្សេងៗនៅក្នុងសង្គមទាំងមូល
- លើកកម្ពស់ស្មារតីចូលរួមដោះស្រាយបញ្ហាផ្សេងៗ ដោយសន្តិវិធី
- ផ្តល់ទមនុកចិត្ត និងភាពស្មោះត្រង់ និងជឿជាក់លើគ្នាទៅវិញទៅមក
- បង្កើនភាពសាមគ្គី និង សហប្រតិបត្តិការបានប្រសើរជាងមុន
- ជាវេទិកាជជែកដេញដោល និងពិភាក្សាលើគោលការណ៍ស្មើភាពគ្នា
- ទប់ស្កាត់ការគម្រាមគំហែងគ្នា ដោយប្រការណាមួយ
- ផ្តល់ជាគម្រូល្អនៅក្នុងសង្គម ប្រកបដោយភាពជឿជាក់ពីប្រជារាស្ត្រ
- គោរពនិងឱ្យតម្លៃគ្នាទៅវិញទៅមក លើភាពផ្ទៃផ្ទ
- មានទមនួលខុសត្រូវ លើផលប្រយោជន៍ជាតិ ក្នុងសង្គមប្រជាធិបតេយ្យ
- បញ្ជៀសរាល់ការប្រើអំពើហឹង្សា និងសង្គ្រាម
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**។

សរុបមកវិញ វប្បធម៌សន្ធនានៅក្នុងសង្គមប្រជាធិបតេយ្យ គឺពិតជាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គម។ ជាពិសេសសម្រាប់អ្នកដឹកនាំ ដែលត្រូវធ្វើជាគម្រូដ៏ល្អ ឱ្យប្រជាជនមានស្មារតីអនុវត្ត និងទទួលខុសត្រូវខ្ពស់ រួមទាំងចូលរួមលើកកម្ពស់វប្បធម៌សន្ធនា ឱ្យបានកាន់តែប្រសើរឡើងថែមទៀត ដើម្បីឱ្យក្លាយជាសង្គមមួយ ដែលពោរពេញ ដោយការសាមគ្គី និងគ្មានសង្គ្រាមពាក្យសម្តី។

១ និញ្ជាសាត្រៀមប្រឡងមធ្យមសិក្សាទុតិយភូមិថ្នាក់១ និទ្យាសាស្ត្រសង្គម

ឯកសារត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ **សម័យប្រឡង**.....

ឯកសារ៖ ប្រវត្តិវិទ្យា (**ថ្នាក់វិទ្យាសាស្ត្រសង្គម**) **មណ្ឌលប្រឡង**.....

រយៈពេល៖ ៩០នាទី **ឈ្មោះបេក្ខជន**.....

ពិន្ទុសរុប៖ ៧៥ពិន្ទុ **លេខបន្ទប់៖**.....**លេខតុ**.....

ហត្ថលេខាបេក្ខជន.....

ឯកសារទី១

១. តើសម័យអាណាព្យាបាលបារាំងមានព្រះរាជាខ្មែរប៉ុន្មានអង្គសោយរាជ្យ? មានអង្គណាខ្លះ?

២. តើសង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០-១៩៦០ បាននាំមកនូវឧបទ្វីបឥណ្ឌូចិនអ្វីខ្លះ?

៣.ហេតុអ្វីបានជាកម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំង ដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំង?

៤.តើសង្គ្រាមនៅកម្ពុជាក្នុងឆ្នាំ១៩៧០-១៩៧៥ និងឆ្នាំ ១៩៧៩-១៩៩៨ នាំមកនូវផលវិបាកដល់កម្ពុជា?

៥. ចូររៀបរាប់អំពីផលវិជ្ជមាននិងអវិជ្ជមាននៃរបបអាណានិគមបារាំងនៅកម្ពុជា។

អត្រាកំណែ

១. សម័យអាណាព្យាបាលបារាំងមានព្រះរាជាខ្មែរ៤ អង្គសោយរាជ្យ

–ព្រះបាទ នរោត្តម ១៨៦០-១៩០៤

– ព្រះបាទ ស៊ីសុវត្ថិ ១៩០៤-១៩២៧

– ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ១៩២៧-១៩៤១

– ព្រះបាទ នរោត្តម សីហនុ ១៩៤១-១៩៥៥។

២. សង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០-១៩៦០ បាននាំមកនូវឧបទ្វីបឥណ្ឌូចិន

– ប្រទេសនៅក្នុងតំបន់ឥណ្ឌូចិនទទួលបានឯករាជ្យ

– មានស្វ័យភាពក្នុងការដឹកនាំប្រទេសជាតិ

– ប្រទេសកម្ពុជាទទួលបានអព្យាក្រឹត

– មានការអភិវឌ្ឍលើគ្រប់វិស័យ

– កម្ពុជាមានស្ថិរភាព និងចូលជាសមាជិកអង្គការសហប្រជាជាតិ

– មានការកៀបសង្កត់ពីមហាអំណាចលើមនោគមវិជ្ជាសេរីនិងកុម្មុយនីស្ត

– សង្គ្រាមនៅវៀតណាមកើតឡើង

  វៀតណាមត្រូវបានបែងចែកពីរ (កុម្មុយនីស្ត និងសេរី)

  ប្រទេសឡាវ ត្រូវបានបែងចែកពីរ (កុម្មុយនីស្ត និងសេរី)

– កម្ពុជាមានទំនាស់ជាមួយប្រទេសជិតខាងជាដើម។

៣. កម្ពុជាចាំបាច់ស្វែងរកកិច្ចការពារពីបារាំង ដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំង

– ប្រទេសកម្ពុជាកាន់តែចុះទន់ខ្សោយទៅៗ ជាលំដាប់ និងមានវិបត្តិផ្ទៃក្នុង

- សៀមនិងយួនប៉ុនប៉ងលេបត្រាប់ទឹកដីខ្មែរ ដោយចែកទឹកដីខ្មែរជាពីរ និងយកទន្លេមេគង្គធ្វើជាព្រំប្រទល់
- កម្ពុជាចង់បានប្រទេសមហាអំណាចអឺរ៉ុបណាមួយ (បារាំង) មកជួយការពារទឹកដីនិងពូជសាសន៍ខ្មែរ

៤. សង្គ្រាមនៅកម្ពុជាក្នុងឆ្នាំ១៩៧០-១៩៧៥ និងឆ្នាំ ១៩៧៩-១៩៩៨ នាំមកនូវផលវិបាកដល់កម្ពុជា

- ផលវិបាកក្នុងសង្គម
- សង្គ្រាមបានសម្លាប់ជីវិតមនុស្សជាង៣លាននាក់បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា ជនពិការ
- ការជម្លៀសប្រជាជនពីទីក្រុងមកតាមខេត្ត មានការធ្វើទុក្ខវេទនា
- មានភាពអយុត្តិធម៌ អាណាធិបតេយ្យទូទាំងប្រទេស
- គ្រឹះស្ថានសិក្សា វត្តអារាម ត្រូវរងការខូចខាតជាខ្លាំង
- បាត់បង់ធនធានមនុស្សព្រាត់ប្រាស់គ្រួសារ ផ្ទះសម្បែង
- បំបិទសិទ្ធិសេរីភាពខាងជំនឿសាសនា
- ផលវិបាកសេដ្ឋកិច្ច
- ដីស្រែចំការត្រូវបោះបង់ចោល ដោយសារដីក្លាយជាចំការមីន រណ្តៅគ្រាប់បែក
- រោងចក្រសហគ្រាសរងការខូចខាត
- បាត់បង់ធនធានមនុស្សនិងអ្នកវិនិយោគទុនមិនហ៊ានចូលមក
- ចំការកៅស៊ូត្រូវបានបោះបង់ចោល
- ផ្លូវគមនាគមន៍ ផ្លូវស្ពាន ថ្នល់ ត្រូវអន្តរាយ
- សេដ្ឋកិច្ចធ្លាក់ចុះជាកំហុក

– វិស័យនយោបាយ

– ប្រទេសជាតិត្រូវបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ កិត្យានុភាពលើឆាកអន្តរជាតិ

– អស្ថេរភាពនយោបាយនិងមានវិនាសកម្មលើគ្រប់វិស័យ ដោយមានសង្គ្រាមស៊ីវិល

– ប្រជាជនបាត់បង់ជំនឿលើមេដឹកនាំប្រទេសនិងអស់សង្ឃឹមលើជោគវាសនាប្រទេសជាតិ

- កម្ពុជាក្លាយជាប្រទេសឯកការ។

៥. រៀបរាប់អំពីផលវិជ្ជមាននិងអវិជ្ជមាននៃរបបអាណានិគមបារាំងនៅកម្ពុជា

- ផលវិជ្ជមាន

–បារាំងជួយការពារទឹកដី ពូជសាសន៍ខ្មែរឱ្យគង់វង្ស

– បារាំងជួយការពារទឹកដីខ្មែរឱ្យ រួចចាកផុតពីការឈ្លានពានរបស់យួននិងសៀម

–បារាំងបានបង្កើតសាលាចុងបូព៌ាប្រទេស ដើម្បីស្រាវជ្រាវ ចងក្រង ផ្សព្វផ្សាយពីអរិយធម៌ សិល្ប:ចម្លាក់ ប្រវត្តិសាស្ត្រខ្មែរ និង ជួសជុលប្រាសាទបុរាណខ្មែរជាច្រើន ធ្វើឱ្យមរតកអតីតកាលខ្មែរដែលបានកប់បាត់រស់ឡើងវិញ

–ក្រោមការគាបសង្កត់របស់បារាំងធ្វើឲ្យសៀម ប្រគល់ទឹកដីមកឲ្យខ្មែរវិញ នូវខេត្តកោះកុង ម្លូព្រៃ ទន្លេរពៅ ស្ទឹងត្រែង បាត់ដំបង សៀមរាប សិរីសោភ័ណ្ឌ

–បារាំងជួយថែរក្សា ជួសជុលប្រាសាទបុរាណខ្មែរ និងកសាងសារមន្ទីរ ដើម្បីថែរក្សាវត្ថុបុរាណ

– នាំចូលវប្ប្ធម៌បារាំងមកស្រុកខ្មែរ រៀបចំរដ្ឋបាលគ្រប់គ្រងយុត្តិធម៌ (បណ្តុះបណ្តាលធនធានមនុស្ស)

– ១៩០៨ បារាំងបានធ្វើផែនទីដងរ៉ែកជាច្រើនផ្ទាំងដែលទទួលស្គាល់ដោយរដ្ឋាភិបាលបារាំងនិងរដ្ឋាភិបាលសៀម
និងនៅលើឆាកអន្តរជាតិរហូតដល់សព្វថ្ងៃ

–កំណែទម្រង់លើវិស័យរដ្ឋបាល វិស័យសិក្សាធិការ វិស័យសេដ្ឋកិច្ច វិស័យកសិកម្ម វិស័យសុខាភិបាល វិស័យគមនាគមន៍ និងសង្គម

–លុបបំបាត់របបទាសភាពនៅកម្ពុជា

– ផ្សព្វផ្សាយវប្បធម៌ប្រពៃណីរបស់ខ្មែរនៅប្រទេសបារាំង

- ផលអវិជ្ជមាន

– បង្ខំប្រជាជនខ្មែរបង់ពន្ធដារយ៉ាងធ្ងន់ធ្ងរ ដោយមិនលើកលែងសូម្បីពន្ធស្រូវ ពន្ធមនុស្ស ពន្ធដីធ្លី ពន្ធសត្ត

– កេណ្ឌប្រជាជនខ្មែរឱ្យចូលបំរើកងទ័ពបារាំងក្នុងសង្គ្រាមលោកលើកទីមួយនិងទីពីរ បណ្តាលឲ្យស្លាប់និងរបួសក្នុងសមរភូមិ

– ៣១ មករា ១៩៣៩ បារាំងបានដាក់បញ្ជូនកោះត្រល់ទៅក្នុងរដ្ឋបាលកូសាំងស៊ីន

– ០៤ មិថុនា ១៩៤៩ កាត់ទឹកដីកម្ពុជាក្រោម និងតំបន់ដាឡាត់ទៅឲ្យស្តេចយួនបាវ ដាយគ្រប់គ្រង

– កាត់ខេត្តត្រាចរបស់ខ្មែរ ឲ្យសៀមកាន់កាប់

– ប្រមូលយកវត្ថុកេតនភ័ណ្ឌរបស់ខ្មែរទៅកាន់ប្រទេសបារាំង។

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ **សម័យប្រឡង**.....

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម) **មណ្ឌលប្រឡង**.....

រយៈពេល៖ ៩០នាទី **ឈ្មោះបេក្ខជន**.....

ពិន្ទុសរុប៖ ៧៥ពិន្ទុ **លេខបន្ទប់៖**.....**លេខតុ**.....

ហត្ថលេខាបេក្ខជន.....

វិញ្ញាសាទី២

១. ប្រាសាទសម្ព្រៃព្រៃគុក ត្រូវបានដាក់បញ្ចូលជាសម្បត្តិបិតិកភណ្ឌពិភពលោកនៅថ្ងៃ ខែ ឆ្នាំណា? ដោយស្ថាប័នអង្គការឈ្មោះអ្វី?

២.តើហេតុផលដែលខ្មែរក្រហមបានពន្យល់ចំពោះការបណ្តេញប្រជាជនឱ្យចេញពី ទីក្រុងនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានអ្វីខ្លះ?

៣. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើខ្មែរក្រហមបែងចែកសត្រូវជាប៉ុន្មាន? អ្វីខ្លះ?

៤. ចូរនិយាយពីនយោបាយអព្យាក្រឹត្យរបស់សម្តេច នរោត្តម សីហនុ សម័យសង្គមរាស្ត្រនិយម។

៥. តើកម្ពុជាជួបប្រទះនឹងផលវិបាកអ្វីខ្លះ ពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម?

អត្ថាធិប្បាយ

១. ប្រាសាទសម្ព្ធរព្រៃគុក ត្រូវបានដាក់បញ្ចូលជាសម្ព្ធត្តិបិតិកកណ្ឌពិភពលោកនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧ ។ ដោយស្ថាប័នអង្គការយូណេស្ក ។

២. ហេតុផលដែលខ្មែរក្រហមបានពន្យល់ចំពោះការបណ្តេញប្រជាជនឱ្យចេញពី

ទីក្រុងនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានដូចជា៖

- ❖ ខ្មែរក្រហមបានប្រាប់ប្រជាជនថា សហរដ្ឋអាម៉េរិកនឹងមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ
- ❖ ខ្មែរក្រហមបានប្រាប់ប្រជាជនអំពីការខ្វះខាតមធ្យោបាយដឹកជញ្ជូនក្នុងការនាំម្ហូបអាហារមកកាន់ទីក្រុង
- ❖ ប៉ុល ពត បាននិយាយថាការជម្លៀសនេះមានសារសំខាន់ណាស់ ដើម្បីបំបែកក្រុមចារកិច្ចរបស់ខ្មាំង ។

៣. ក្នុងរបបកម្ពុជាប្រជាធបិតេយ្យ ខ្មែរក្រហមបែងចែកសត្រូវជាពីរគឺ

- ❖ សត្រូវខាងក្នុង
  - ○ អ្នករាជការរបបចាស់ពិសេសក្នុងសម័យសាធារណរដ្ឋខ្មែរ
  - ○ ក្រុមជនជាតិភាគតិចនានា និងជនជាតិភាគតិចតំបន់ភ្នំ
  - ○ ក្រុមជនជាតិភាគតិខ្មែរឥស្លាម
  - ○ ក្រុមជនជាតិភាគតិវៀតណាម និងចិន
  - ○ បញ្ញាវន្ត និងជនក្បត់ដ៏ទៃទៀត
- ❖ សត្រូវខាងក្រៅ
  - ○ សហរដ្ឋអាមេរិក ដែលជាមហាអំណាចប្តូកសេរី
  - ○ ថៃ ជាសម្ព័ន្ធមិត្តអាម៉េរិក ដែលមានព្រំដែនជាប់ប្រទេសកម្ពុជា

- វៀតណាមបានប្រែក្លាយជាសត្រូវក្រោយពេលខ្មែរក្រហមឡើងកាន់អំណាចពេញលេញ ដោយសារបញ្ហាប្រវត្តិសាស្ត្រ
- អតីតសហភាពសូវៀត ដែលជាមហាអំណាចដឹកនាំប្លុកកុម្មុយនិស្ត និងជាសត្រូវរបស់ចិន ដែលជាខ្នងបង្អែករបស់ខ្មែរក្រហម។

៤. និយាយពីនយោបាអព្យាក្រឹត្យរបស់របស់សម្តេចនរោត្តមសីហនុ ក្នុងសម័យសង្គមរាស្ត្រនិយម

- អត្តន័យ៖ នយោបាយអព្យាក្រឹត្យសម័យសង្គមរាស្ត្រនិយមមានន័យថា ជានយោបាយរបស់ប្រជាជាតិកម្ពុជាទាំងមូលដែលតម្រូវឱ្យប្រកាន់នូវអាកប្បកិរិយាមួយនឹងនរជាជាចខាតរវាងបក្សខាងលិច និងបក្សកុម្មុយនិស្ត គឺអាកប្បកិរិយាមិត្តភាពជាមួយបក្សទាំងពីរ ដែលតែងតែទទួលយកជំនួយទាំងឡាយណាដែលមិនធ្វើឱ្យមានសាបរលាបដល់អធិបតេយ្យភាព និងអព្យាក្រឹត្យភាពរបស់កម្ពុជា។
- មូលហេតុដែលនាំឱ្យកម្ពុជាសម្រេចយកនយោបាយអព្យាក្រឹតព្រោះ
  តាមរយៈសន្និសិទ្ធក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ នយោបាយអព្យាក្រឹតត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចរបស់សន្និសិទ្ធនេះ ដែលជាការទាមទាររបស់សហភាពសូវៀត និងចិនដើម្បីបញ្ជៀសមិនឱ្យអាមេរិកកសាងមូលដ្ឋានទ័ពនៅលើទឹកដីកម្ពុជា។
- ការពង្រឹងនយោបាយអព្យាក្រឹត
  - ១៨ មីនា ១៩៥៥ សម្តេច នរោត្តម សីហនុ បានធ្វើដំណើរទស្សនកិច្ចទៅកាន់ប្រទេសឥណ្ឌា និងបានចុះហត្ថលេខាលើសេចក្តីប្រកាសរួមមួយស្តីពីការរួមរស់ជាមួយគ្នា ដោយសន្តិភាព
  - ១៨-២៤ មេសា ១៩៥៥ សន្និសីទកំពូលនៃប្រជាជាតិអាស៊ី-អាហ្វ្រិក នាទីក្រុងបានឌុងព្រះអង្គបានប្រកាសពីនយោបាអព្យាក្រឹត និងរួមរស់ដោយសន្តិភាព
  - ១៤ ធ្នូ ១៩៥៥ ក្នុងឱកាសដែលកម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ កម្ពុជាបាបានប្រកាសពីមាគ៌ានយោបាយអព្យាក្រឹតរបស់ខ្លួន
  - ១៩៥៦ នៅទីក្រុងប្រ៊ីយូនី ព្រះអង្គបានចុះហត្ថលេខាលើធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ។

❖ លទ្ធផល

- ជំហានដំបូង កិត្យានុភាពរបស់កម្ពុជាល្បីរីកសុះសាយក្នុងតំបន់ ដែលអាចរក្សាសន្តិភាពឱ្យកម្ពុជាបានស្របពេលដែលប្រទេសវៀតណាមកំពុងស្ថិតក្នុងភ្លើងសង្គ្រាម។ ចំណែកឯក្រុមអ្នកប្រឆាំងនឹងសម្តេចនរោត្តម សីហនុ ក៏ទទួលស្គាល់ ពីភាពរីកផលប្រយោជន៍ដែលកម្ពុជាទទួលបានពីនយោបាយអព្យាក្រឹតនេះដែរ។
- ក្នុងដំណាក់កាលសង្គ្រាមត្រជាក់ ដោយសារឥទ្ធិពលនយោបាយរបស់មហាអំណាចទាំងពីរធ្វើឱ្យនយោបាយនេះមានការចុះខ្សោយ។ សកម្មភាពនយោបាយរបស់សហរដ្ឋអាមេរិក ថៃ និងវៀតណាមខាងត្បូង មានទិសដៅប្រឆាំងនឹងនយោបាយសម្តេចនរោត្តម សីហនុ។ សហរដ្ឋអាមេរិកបានផ្តល់ ជំនួយយោធា ដើម្បីចិញ្ចឹមពួកស្តាំនិយម ចំណែកឯថៃវិញ បានគាំទ្រសកម្មភាព ខ្មែរសេរី ដោយផ្តល់កន្លែងសម្រាប់ជំរំហាត់ទ័ពកសាងស្ថានីយ៍វិទ្យុផ្សាយសំឡេង ក្នុងការប្រឆាំង រដ្ឋាភិបាលស្របពេលដែលវៀតណាមខាងត្បូងធ្វើសកម្មភាពឈ្លៀនពានទឹកដីខ្មែរតាមព្រំដែន។
- តំណាក់កាលចុងក្រោយ ៖ នយោបាយនេះត្រូវបានដួលរលំដោយសារកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុ ចេញពីដំណែង នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយលោសេនាប្រមុខ លន់ នល់ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ។

៥. កម្ពុជាជួបប្រទះនឹងផលវិបាកជាច្រើនពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ក្នុងនោះមានដូចជា៖

❖ សេដ្ឋកិច្ច

- សេដ្ឋកិច្ចត្រូវធ្លាក់ដល់ចំណុចសូន្យ គ្មានកំណើនសេដ្ឋកិច្ច គ្មានការនាំចេញនាំចូល
- ខូចខាតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានា ដែលគាំទ្រដល់វិស័យសេដ្ឋកិច្ច
- ប្រជាពលរដ្ឋមិនអាចត្រឡប់ទៅធ្វើស្រែបាន ដោយសារដីស្រែចម្ការត្រូវក្លាយជាចម្ការមិន
- បាត់បង់ធនធាន់មនុស្ស និងសម្ភារៈសម្រាប់ធ្វើកសិកម្ម ឧស្សាហកម្ម សិប្បកម្ម និងពាណិជ្ជកម្មជាច្រើន។

❖ សង្គម

- ធ្វើឱ្យបាត់បង់អាយុជីវិតរបស់ប្រជាជាជនជិត២លាននាក់
- មនុស្សរាប់លានអ្នកត្រូវបែកបាក់គ្រួសារ សាច់ញាតិ បងប្អូន
- បន្សល់ទុកនូវស្ត្រីមេម៉ាយ ជនពិការ កុមារកំព្រា និងជនបាក់កម្លាំងដែលគ្មានលទ្ធភាពការពារខ្លួនឯងបាន
- បាត់បង់ធនធានមនុស្ស អ្នកប្រាជ្ញ អ្នកចេះដឹង បុគ្គលជំនាញ ដែលជាធនធានដ៏សំខាន់សម្រាប់កសាងប្រទេស
- ប្រជាជនកម្ពុជាជាច្រើនត្រូវរស់នៅជាមួយជំងឺផ្លូវចិត្តរ៉ាំរ៉ៃ។

❖ វប្បធម៌ ប្រពៃណីទំនៀមទម្លាប់

- ហេដ្ឋារចនាសម្ព័ន្ធនានាដូចជា សាលារៀន មន្ទីរពេទ្យ វត្តអារាមជាច្រើនត្រូវបានបំផ្លាញ
- វិស័យអប់រំត្រូវឈប់ត្រឹង ព្រោះមនុស្សត្រូវចំណាយពេលស្វែងរកអាហារ
- ការប្រតិបត្តិជំនឿសាសនា នាពេលនោះ មិនជាប់លាប់ឡើយ
- មនុស្សជាច្រើនត្រូវបានខ្មែរក្រហមបង្ខំឱ្យធ្វើខុសពីប្រពៃណី ដូចជាការរៀបការ។

❖ ប្រទេសជាតិ

- បាតបង់កិត្តិយសរបស់ប្រទេសលើឆាកអន្តរជាតិ
- បាត់បង់កិត្យានុភាពរបស់ប្រទេសជាតិ
- ត្រូវក្លាយជាប្រទេសដែលពិភពលោកស្គាល់ថា មានវាលពិឃាត។
- ចម្លើយផ្សេងទៀត។

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ **សម័យប្រឡង**.....

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម) **មណ្ឌលប្រឡង**.....

រយៈពេល៖ ៩០នាទី **ឈ្មោះបេក្ខជន**.....

ពិន្ទុសរុប៖ ៧៥ពិន្ទុ **លេខបន្ទប់៖**.....**លេខតុ**.....

ហត្ថលេខាបេក្ខជន.....

វិញ្ញាសាទី៣

១. សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ជាអ្វី? ប្រទេសណាខ្លះជាសមាជិក?

២. តើខ្មែរក្រហមបែងចែកដែនដីរដ្ឋបាលជាប៉ុន្មានភូមិភាគតំបន់? អ្វីខ្លះ?

៣. កំណែទម្រង់របស់លោក ហ្គោបាចូវ ធ្វើឱ្យពិភពលោកមានការប្រែប្រួលអ្វីខ្លះ ?

៤. មូលហេតុអ្វីខ្លះ ដែលធ្វើមានការដកកងទ័ពវៀតណាមចេញពីកម្ពុជា?

៥. តើយុវជនខ្មែរជំនាន់ក្រោយត្រូវធ្វើដូចម្តេច កុំឱ្យរបបប្រល័យពូជសាសន៍កើតឡើងម្តងទៀត?

អត្ថាធិប្បាយ

១. សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ គឺជាស្ថាប័នអន្តររដ្ឋាភិបាលប្រចាំតំបន់អាស៊ីប៉ែកអាគ្នេយ៍ ដែលធ្វើការសហប្រតិបត្តិការលើកកម្ពស់សេដ្ឋកិច្ច នយោបាយ និងសុខសុវត្ថិភាពក្នុងតំបន់ និងមានប្រទេស១០ជាសមាជិក។ សមាជិកទាំង១០នោះមានដូចជា៖

- ព្រះរាជាណាចក្រកម្ពុជា
- សាធារណរដ្ឋសង្គមនិយមវៀតណាម
- ព្រះរាជាណាចក្រថៃឡង់
- សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
- សហព័ន្ធម៉ាឡេស៊ី
- សាធារណរដ្ឋឥណ្ឌូនេស៊ី
- សាធារណរដ្ឋហ្វីលីពីន
- សាធារណរដ្ឋសិង្គបុរី
- ប្រុយណេដារ៉ូសាឡឹម
- សាធារដ្ឋសហភាពមីយ៉ាន់ម៉ា។

២. ខ្មែរក្រហម បែងចែកដែនដីរដ្ឋបាលរបស់ខ្លួនជា ៧ភូមិភាគ និង៣២តំបន់ដោយតំបន់ ភូមិភាគនីមួយៗរួមបញ្ចូលខេត្តពីរ ឬច្រើនចូលគ្នា និងមានលេខសម្គាល់ទៅតាមភូមិភាគ និងតំបន់ទាំងនោះ។ ភូមិភាគសំខាន់ៗទាំងនោះមានដូចជា៖

- ភូមិភាគបូព៌ា
- ភូមភាគនិរតី
- ភូមិភាគឧត្តរ

- ភូមិភាគពាយ័ព្យ
- ភូមិភាគបស្ចឹម
- ភូមិភាគឦសាន
- ភូមិភាគកណ្តាល។

៣. កំណែទម្រង់របស់លោក ហ្គោបាធ្ចូ ធ្វើឱ្យពិភពលោកមានការប្រែប្រួលដូចជា

- មនោគមវិជ្ជាកុម្មុយនិស្តចាប់ផ្តើមដួលរលំ នាំឱ្យកើតមានប្រជាធិបតេយ្យ
- បណ្តារដ្ឋជាច្រើននៅតំបន់អឺរ៉ុបខាងកើត ប្រកាស់ឯករាជ្យចេញពីសហភាពសូវៀត
- រដ្ឋដែលធ្លាប់ប្រកាន់យកនោយបាយបែបកុម្មុយនិស្ត ប្តូររបបគ្រប់គ្រងមកប្រជាធិបតេយ្យ
- ជញ្ជាំងក្រុងប៊ែរឡាំងត្រូវបានដួលរលំ អាឡឺម៉ង់បង្រួបបង្រួមឡើងវិញ
- អង្គការកូមេកុងរបស់សហភាពសូវៀតបានដួលរលំ
- បម្លាស់ប្តូរសេដ្ឋកិច្ចផែនការ មកជាសេដ្ឋកិច្ចទីផ្សារសេរី
- ការប្រកួតប្រជែងសញ្ញាវុធទំនើប ត្រូវបានបញ្ចប់
- ការដកកងទ័ពសហភាពសូវៀតចេញពីប្រទេសដែលជាសម្ព័ន្ធមិត្ត
- មានសេរីភាពក្នុងការបញ្ចេញមតិ ចំពោះរដ្ឋដែលធ្លាប់ប្រកាន់យករបបកុម្មុយនិស្តពីមុន

៤. មូលហេតុ ដែលធ្វើមានការដកកងទ័ពវៀតណាមចេញពីកម្ពុជានៅឆ្នាំ១៩៨៩មានដូចជា៖

- សហគមន៍អន្តរជាតិថ្កោលទោសពីវត្តមានវៀតណាមនៅកម្ពុជា និងស្នើឱ្យដកទ័ពចេញពីកម្ពុជា
- ការហ៊ុមព័ន្ធវៀតណាមពីខាងក្រៅទាំងសេដ្ឋកិច្ច និងនយោបាយ
- ការហ៊ុមព័ន្ធសូវៀត ឈប់គាំទ្រទាំងសេដ្ឋកិច្ច និងយោធាដល់វៀតណាមក្នុងការរក្សាវត្តមានកងទ័ពរបស់ខ្លួននៅកម្ពុជាជាបន្តទៀត
- ការធ្លាក់ចុះ និងរកខ្សត់ដួលរំរបស់សហភាពសូវៀតឈានដល់ការបញ្ចប់សង្គ្រាមត្រជាក់

- ការចរចារវាងវៀតណាម និងចិន គឺវៀតណាមត្រូវដកទ័ពចេញពីកម្ពុជា ហើយចិនសន្យាឈប់ផ្តល់ជំនួយគាំទ្រឱ្យខ្មែរក្រហម និងជាក់សម្ពាធឱ្យខ្មែរក្រហមចូលរួមតុចរចារ
- យកគំរូតាមសមសហភាពសូវៀតក្នុងការដកទ័ពចេញពីអាហ្គានីស្ថាន
- ដើម្បីកាត់ន្ថយការចំណាយដ៏ច្រើនទាំងសេដ្ឋកិច្ច និងយោធាក្នុងការរក្សាវត្តមាននៅកម្ពុជា
- ខាតបង់អាយុជីវិតកងទ័ពជាច្រើននៅកម្ពុជា
- រដ្ឋកម្ពុជាមានលទ្ធភាពការពារខ្លួនឯងពីការវាយប្រហារពីភាគីទំនាស់ផ្សេងៗទៀតនៅកម្ពុជា
- វៀតណាមទាញយកការអនុគ្រោះពីអន្តរជាតិ
- វិបត្តិសេដ្ឋកិច្ច និងភាពសក្រីក្រក្នុងប្រទេស
- ការធ្វើកំណែទម្រង់ដូយម៉ឺយឆ្នាំ ១៩៨៦ នៅវៀតណាម ដើម្បីកែប្រែសេដ្ឋកិច្ចតាមទីផ្សារសេរី។
- ចម្លើយផ្សេងទៀត។

៥. ដើម្បីការពារកុំឱ្យរបបប្រល័យពូសាសន៍កុំឱ្យកើតឡើងម្តងទៀតយើងត្រូវ

- ទប់ស្កាត់កុំឱ្យមានអំពើហិង្សា និងការប្រើប្រាស់អាវុធ
- ទប់ស្កាត់សង្គ្រាមនៅលើទឹកដីកម្ពុជា
- ទប់ស្កាត់ការបែកបាក់សាមគ្គី ឬ ជម្លោះផ្ទៃក្នុង និងជាមួយបរទេស
- ទប់ស្កាត់មនោគមវិជ្ជាព្រៃផ្សៃ និងមិនជាប្រយោជន៍ជាតិ
- ទប់ស្កាត់ការទម្លាក់រដ្ឋាភិបាលស្របច្បាប់ដោយប្រជាប់អាវុធ ឬសកម្មភាពខុសច្បាប់
- ទប់ស្កាត់ភាពអយុត្តិធម៌សង្គម
- ទប់ស្កាត់អំពើពុករលួយ
- ទប់ស្កាត់សកម្មភាពជ្រុលនិយម
- ទប់ស្កាត់និទណ្ឌភាព

- ទប់ស្កាត់ការបង្កើតតំបន់អប្បគមន៍
- ការពារវប្បធម៌សន្តិភាព
- ការពារសន្តិភាព និងស្ថិរភាពសង្គម
- ការពារលទ្ធិប្រជាធិបតេយ្យ និងគោរពច្បាប់រដ្ឋ
- ដោះស្រាយបញ្ហាដោយសន្តិវិធី
- គោរពសិទ្ធិមនុស្ស ជំនឿ ពិពិធភាពក្នុងសង្គម
- រក្សាភាពយុត្តិធម៌ និងតម្លាភាព
- លើកស្ទួយវិស័យអប់រំ និងអ្នកចេះដឹង
- អប់រំភាពជាពលរដ្ឋដែលមានការយោគយល់គ្នាទៅវិញទៅមក
- បញ្ចូលការអប់រំស្តីពីផលវិបាកនៃសង្គ្រាម និងរបបប្រល័យពូជសាសន៍ក្នុងកម្មវិធីសិក្សា
- សិក្សាប្រវត្តិសាស្ត្រ និងតាមដានស្ថានភាពក្នុងប្រទេស និងជុំវិញពិភពលោក
- បំពេញការកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់
- អភិវឌ្ឍវិស័យសេដ្ឋកិច្ច វិស័យវប្បធម៌ វិស័យអប់រំ វិស័យទំនាក់ទំនង...។
- មានចំណុចត្រឹមត្រូវផ្សេងៗទៀត

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

វិញ្ញាសា៖ ប្រវត្តិវិទ្យា (ថ្នាក់វិទ្យាសាស្ត្រសង្គម)

រយៈពេល៖ ៩0នាទី

ពិន្ទុសរុប៖ ៧៥ពិន្ទុ

សម័យប្រឡង.....

មណ្ឌលប្រឡង.....

ឈ្មោះបេក្ខជន.....

លេខបន្ទប់៖.....**លេខតុ**.....

ហត្ថលេខាបេក្ខជន.....

វិញ្ញាសាទី៤

១. តើនរណាជាមេដឹកនាំរបបខ្មែរក្រហម? សូមរៀបរាប់ឱ្យបានយ៉ាងតិចប្រាំនាក់។

២. តើអ្វីដែលជាប្រភពមូលដ្ឋានដែលនាំឱ្យ មានការលេចឡើងនូវបញ្ហាលើពិភពលោក? ចូរពន្យល់។

៣.តើកម្ពុជាចូលជា សមាជិកអាស៊ានៅថ្ងៃខែឆ្នាំណា? ការចូលជាសមាជិកអាស៊ាននេះ បានធ្វើឱ្យកម្ពុជា ទទួលបាននូវគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះ?

៤. ចូរពណ៌នាពីនយោបាយអព្យាក្រឹត្យ នៅក្នុងរបបសង្គមរាស្ត្រនិយម។

៥.តើមានមូលហេតុអ្វី ដែលគេចាត់ទុកសម្តេចនរោត្តមសីហនុ និងសម្តេច ហ៊ុន សែន ជាបិតាសន្តិភាព។

អត្រាកំណែ

១. មេដឹកនាំក្នុងរបបខ្មែរក្រហមមានដូចជា ៖

– ខៀវ សំផន ប្រមុខរដ្ឋ

– នួន ជា គឺជាលេខាបក្សកម្មុយនីស្តកម្ពុជា

– សាឡុត ស (ប៉ុល ពត) ជាអនុលេខាបក្សកម្មុយនីស្តកម្ពុជា

– អៀង សារី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស

– សុន សេន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

– វ៉ន វ៉ែត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត..... ។

២. ប្រភពជាមូលដ្ឋានដែលនាំឱ្យមានបញ្ហាកើតឡើងនៅលើពិភពលោក មានដូចជា ៖

– ប្រភពទី១.៖ កំណើនទំហំសេដ្ឋកិច្ចពិភពលោក មិនស៊ីចង្វាក់និងលទ្ធភាពដែលផ្តល់ពីធនធាននៅលើដី ឬ មិនស៊ីចង្វាក់គ្នាលើធនធានដែលមានស្រាប់ ។

– ប្រភពទី២.៖ ការរីកចម្រើនបដិវត្តន៍វិទ្យាសាស្ត្របច្ចេកទេស ដោយសារវិទ្យាសាស្ត្របច្ចេកទេសបាននាំមកនូវភាពវិជ្ជមាន និងអវិជ្ជមាន ព្រមគ្នាក្នុងពេលតែមួយមកលើពិភពលោកហើយវាក៏អាចឱ្យមានការប៉ះពាល់ ដល់សុខភាពមនុស្ស បរិស្ថាន សង្គម និងសេដ្ឋកិច្ច ហើយវាក៏អាចក្លាយទៅជាហានិភ័យចំពោះសង្គមជាតិ ។

– ប្រភពទី៣ កំណើនប្រជាជន ៖ ទាមទារឱ្យមានការផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគកាន់តែច្រើនដែលជាហេតុធ្វើឱ្យធនធាន ធម្មជាតិកាន់តែរិចរិលទៅៗ ។

– ប្រភពទី៤ ៖ ការចំណាយយ៉ាងច្រើនសន្ធិកសន្ធាប់ទៅលើ សព្វាវុធ និងកងទ័ព

– ប្រភពទី៥ ៖ ភាពយឺតយ៉ាវរបស់ស្ថាប័នរដ្ឋ ក្នុងការឆ្លើយតប និងរកដំណោះស្រាយឱ្យបានទាន់ពេលវេលា ។

៣.កម្ពុជាចូលជា សមាជិកអាស៊ាននៅថ្ងៃ៣០ ខែ មេសា ឆ្នាំ១៩៩៩។ ការចូលជាសមាជិកអាស៊ាននេះ បានធ្វើឱ្យកម្ពុជា ទទួលបាននូវគុណសម្បត្តិ និង គុណវិបត្តិ ដូចជា ៖

គុណសម្បត្តិ

- ផលប្រយោជន៍ផ្នែកនយោបាយ

– កម្ពុជាអាឈរស្មើមុខមាត់ ជាមួយប្រទេសជាសមាជិក និងបានចូលរួមរាល់ការសម្រេចចិត្ត ក្នុងតំបន់

– សម្រេចបាននូវផ្នែកមួយនៃមុំពីរនៃយុទ្ធសាស្ត្រចតុកោណ គឺសមាហរណកម្មនៃប្រទេសកម្ពុជា ចូលក្នុងតំបន់

– កម្ពុជារក្សាបាននូវសន្តិសុខ សេរីភាព និងអធិបតេយ្យភាព

– កម្ពុជាអាចចូលរួមដោះស្រាយបញ្ហាដោយសន្តិវិធី ពិសេសជម្លោះ ជាមួយប្រទេសជិតខាង

- សេដ្ឋកិច្ច

– កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ

– ងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មជាមួយបរទេស

– ប្រជាជនមានការងារធ្វើច្រើន នាំឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើន

– មានកំណើនភ្ញៀវទេសចរ ចូលមកកម្ពុជា កាន់តែច្រើន

– កម្ពុជាអាចខ្ចីប្រាក់កម្ចីពីធនាគារអភិវឌ្ឍអាស៊ី (ADB) ក្នុងអត្រាការប្រាក់ទាប សម្រាប់ងាយស្រួល ក្នុងការយកមកអភិវឌ្ឍប្រទេសជាតិ។

– កម្ពុជាទទួលបានការអភិវឌ្ឍ លើវិស័យផ្សេងៗ ដូចជា កសិកម្ម ឧស្សាហកម្ម បានទូលាយជាងមុន

– ជម្រុញឱ្យមានការអភិវឌ្ឍលើប្រពន្ធ័ហេដ្ឋារចនាសម្ព័ន្ធ បានប្រសើជាងមុន

- ផ្នែកសង្គម

– កម្ពុជាទទួលបាននូវកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់ ក្នុងការថែរក្សាសន្តិភាព និងសន្តិសុខ ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និង អំពើភេរវកម្ម ។

– លើកម្ពស់ការផ្លាស់ប្តូរចំណេះដឹង សង្គមកិច្ច វប្បធម៌ និង ប្រពៃណីទំនៀមទម្លាប់ ព្រមទាំងបច្ចេកទេស ពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន ទាំងមូល ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត .....។

គុណវិបត្តិ

– ឧបសគ្គនៃលំហូរវិនិយោគទុនមកកម្ពុជា ដែលធ្វើឱ្យប្រជាជនកម្ពុជាមានភាពលំបាកក្នុងការស្វែងរកការងារធ្វើ

– ការគោរពនីតិរដ្ឋមិនបានគ្រប់ជ្រុងជ្រោយ និងអាចមានកង្វះឯករាជ្យនៃប្រពន្ធ័តុលាការ ដែលធ្វើឱ្យអ្នកវិនិយោគ មានការរារែកក្នុងការសម្រេចចិត្តវិនិយោគ នៅកម្ពុជា

– កង្វះធនធានមនុស្ស ដែលធ្វើឱ្យប្រជាជនកម្ពុជាមិនអាចរកការងារដែលល្អៗបានច្រើន និងធ្វើឱ្យមានផលវិបាកសម្រាប់ វិនិយោគទុនដែលចង់មកកម្ពុជា ព្រោះប្រសិនបើ វិនិយោគគិនមកតែកម្ពុជាខ្វះធនធានមនុស្ស សម្រាប់ជួយឱ្យការងារពួកគេដើរ នោះគេប្រាកដជាបង្ខៃដៃគូសហការទៅប្រទេសផ្សេងៗ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត ...។

៤. ពណ៌នាពីនយោបាយអព្យាក្រឹត្យ នៅក្នុងរបបសង្គមរាស្ត្រនិយម (១៩៥៥ ដល់១៩៧០)

មូលហេតុដែលកម្ពុជាប្រកាន់យកនយោបាយអព្យាក្រឹត្យ

– អនុវត្តតាមសេចក្តីប្រកាស របស់សន្និសីទ្ធសឺណែវឆ្នាំ១៩៥៤ ដែលស្នើដោយសូវៀត និងចិន

– កម្ពុជាចង់រស់នៅដោយសន្តិភាព សហវិជ្ជមានជាមួយបណ្តាប្រទេសទាំងអស់លើពិភពលោក

ដំណាក់កាលដំបូង

– កម្ពុជាបានប្រកាន់យកនយោបាយអព្យាក្រិត្យ បានធ្វើឱ្យកម្ពុជាមានភាពល្បីល្បាញក្នុងតំបន់ និងពិភពលោក

– បក្សប្រឆាំងពុំហ៊ានដំទាស់ ហើយសរសើរពីនយោបាយអព្យាក្រឹត្យ

– កម្ពុជារស់នៅបានសុខសន្តិភាព អស់រយៈពេល១៥ឆ្នាំ (១៩៥៥ ១៩៧០) ស្របពេលដែលប្រទេសជិតខាងកំពុងជួបប្រទះបញ្ហាសង្គ្រាម

– កម្ពុជាទទួលបានជំនួយផ្សេងៗសម្រាប់ធ្វើការអភិវឌ្ឍប្រទេសបានកាន់តែប្រសើរឡើង

– មានការរីកចម្រើនលើគ្រប់វិស័យ ទាំងកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម នយោបាយ និ វិស័យអប់រំជាដើម ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត ...។

ដំណាក់កាលសង្គ្រាមត្រជាក់ បានជះឥទ្ធិពលលើនយោបាយអព្យាក្រឹត្យ មានដូចជា ៖

– នយោបាយអព្យាក្រឹត្យកាន់តែទន់ខ្សោយទៅ

– មានមហាអំណាចមនោគមន៍វិជ្ជាពីរ គឺសេរី និង កម្មុយនីស្ត ដែលលបានបំពានលើនយោបាយអព្យាក្រឹត្យ និង មាគ៌ាសន្តិភាព នៅកម្ពុជា

– ជំនួយពីសហរដ្ឋអាមេរិក ចិញ្ចឹមពួកស្តាំនិយម

– ប្រទេសថៃបានឧបត្ថម្ភដល់ខ្មែរសេរី ឱ្យវាយសង្គ្រាមរាស្ត្រនិយម

– រៀតណាមខាងជើងបានប្រើប្រាស់ ផ្លូវហូជីមិញ កាត់ទឹកដីខ្មែរ និងបោះមូលដ្ឋានទ័ពនៅកម្ពុជា

– នៅចុងសម័យសង្គ្រាមរាស្ត្រនិយម អនុវត្តនយោបាយអព្យាក្រឹត្យមិនចំទិសដៅ ដោយមានការលំអៀងទៅរកកុម្មុយនីស្ត

ការបញ្ចប់នយោបាយអព្យាក្រឹត្យ

– បញ្ចប់តាមរយៈ ការធ្វើរដ្ឋប្រហារខាងក្នុងនៅថ្ងៃទី១៨ មីនា ឆ្នាំ ១៩៧០ ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត .....។

៥.បានជាគេចាត់ទុកសម្តេចនរោត្តមសីហនុ និង សម្តេចហ៊ុន សែនជាបិតាសន្តិភាព នៅកម្ពុជាព្រោះ សម្តេចនរោត្តមសីហនុ និងសម្តេច ហ៊ុន សែន បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការស្វែងរកនូវសន្តិភាព សម្រាប់កម្ពុជា ដូចជា ៖

សម្តេចនរោត្តមសីហនុ

– ជាអ្នកផ្តួចផ្តើមឱ្យមានការចរចារកសន្តិភាពនៅកម្ពុជា

– ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC)

– ជាអ្នកចុះហត្ថលេខាលើសន្ធិសញ្ញាទិក្រុងបារីស ថ្ងៃទី២៣ តុលា ១៩៩១

– ជាអ្នកបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ដោយធ្វើការផ្សះផ្សាវិបត្តិ ក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ ដោយនាំឱ្យមានការបង្កើតរដ្ឋាភិបាលចម្រុះ

– ផ្សះផ្សារាល់វិបត្តិនយោបាយ ក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ (១៩៩៨ .២០០៣)

– មានមតិត្រឹមត្រូវផ្សេងទៀត ...។

សម្តេចហ៊ុន សែន

– ជាអ្នកផ្តួចផ្តើមឱ្យមានការចរចារកសន្តិភាពនៅកម្ពុជា

– ជាអ្នកចុះហត្ថលេខាលើសន្ធិសញ្ញាទិក្រុងបារីស ថ្ងៃទី២៣ តុលា ១៩៩១

– ជាអ្នកធានាអះអាងសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ នៅថ្ងៃទី ២៨ ឧសភា ១៩៩៣

– ជាអ្នកផ្សះផ្សារវិបត្តិក្រោយការបោះឆ្នោត ជ្រើសរើសតំណាងរាស្ត្រឆ្នាំ ១៩៩៨ ឆ្នាំ ២០០៨ ឆ្នាំ ២០១៣

– ជាអ្នកបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ដោយអនុវត្តនូវនយោបាយឈ្នះឈ្នះដែលមានការ រំលាយអង្គការ ចាត់តាំងខ្មែរក្រហម និងការធ្វើសមាហរណកម្ម ជាមួយកងទ័ពជាតិ ។

– មានមតិត្រឹមត្រូវផ្សេងទៀត ...។

សរុបមកវិញ តាមរយៈតួនាទី និងការកិច្ច របស់សម្តេចនរោត្តមសីហនុ និង សម្តេច ហ៊ុន សែន គឺពិតជាបាននាំមកនូវសន្តិភាព ពេញលេញសម្រាប់ប្រទេសកម្ពុជា និង ប្រជាជនកម្ពុជាទាំងមូលផងដែរ ។ លើសពីនេះ តាមរយៈការងារនេះ បាននាំមកឱ្យកម្ពុជា នូវសន្តិសុខ សុវត្ថិភាព ស្ថេរភាព សន្តិភាព និងការអភិវឌ្ឍ ប្រកបដោយចីរភាព រួមទាំងកេរ្តិ៍ឈ្មោះ ល្បីល្បាញនៅលើសាកលលោក ។

វិញ្ញាសាត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ **សម័យប្រឡង**.....

វិញ្ញាសា៖ ប្រវត្តិវិទ្យា (**ថ្នាក់វិទ្យាសាស្ត្រសង្គម**) **មណ្ឌលប្រឡង**.....

រយៈពេល៖ ៩០នាទី **ឈ្មោះបេក្ខជន**.....

ពិន្ទុសរុប៖ ៧៥ពិន្ទុ **លេខបន្ទប់៖**.....**លេខតុ**.....

ហត្ថលេខាបេក្ខជន.....

វិញ្ញាសាទី៥

១. តើពិភពលោកបច្ចុប្បន្ននេះ កំពុងជួបប្រទះនឹងបញ្ហាធំៗអ្វីខ្លះ ?

២. តើការចូលជាសមាជិកអាស៊ាន បានផ្តល់ផលប្រយោជន៍អ្វីខ្លះ ដល់កម្ពុជា ? ចូររៀបរាប់ ។

៣. តើនយោបាយអព្យាក្រឹត្យ បានផ្តល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះ ដល់កម្ពុជា ?

៤. តើមានមូលហេតុអ្វីខ្លះ ដែលធ្វើឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ?

៥. ចូរពណ៌នាពីការដំណើរការកសាងកម្ពុជាឡើងវិញ ក្រោយរបបខ្មែរក្រហមដួលរលំទៅ ។

អត្ថាកំណែ

១. នៅក្នុងពិភពលោកបច្ចុប្បន្ន កំពុងជួបប្រទះនូវបញ្ហាធំ ដូចជា បញ្ហាបរិស្ថាន កំណើនប្រជាជន អន្តោប្រវេសន៍ សន្តិសុខស្បៀង ជម្ងឺរាតត្បាត (កូវីត ១៩) ភេរវកម្មអន្តរជាតិ .....។

២. ការចូលជាសមាជិកអាស៊ាន បានផ្តល់នូវផលប្រយោជន៍ ដល់កម្ពុជា ដូចជា៖

- ផលប្រយោជន៍ផ្នែកនយោបាយ

– កម្ពុជាអាឈរស្មើមុខមាត់ ជាមួយប្រទេសជាសមាជិក និងបានចូលរួមរាល់ការសម្រេចចិត្តក្នុងតំបន់

– សម្រេចបាននូវផ្នែកមួយនៃមុំពីរនៃយុទ្ធសាស្ត្រចតុកោណ គឺសមាហរណកម្មនៃប្រទេសកម្ពុជាចូលក្នុងតំបន់

– កម្ពុជារក្សាបាននូវសន្តិសុខ សេរីភាព និងអធិបតេយ្យភាព

– កម្ពុជាអាចចូលរួមដោះស្រាយបញ្ហាដោយសន្តិវិធី ពិសេសជម្លោះ ជាមួយប្រទេសជិតខាង។

- សេដ្ឋកិច្ច

– កម្ពុជាក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ

– ងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មជាមួយបរទេស

– ប្រជាជនមានការងារធ្វើច្រើន នាំឱ្យសេដ្ឋកិច្ចជាតិមានការរីកចម្រើន

– មានកំណើនភ្ញៀវទេសចរ ចូលមកកម្ពុជា កាន់តែច្រើន

– កម្ពុជាអាចខ្ចីប្រាក់កម្ចីពីធនាគារអភិវឌ្ឍអាស៊ី (ADB) ក្នុងអត្រាការប្រាក់ទាប សម្រាប់ងាយស្រួល ក្នុងការយកមកអភិវឌ្ឍប្រទេសជាតិ។

– កម្ពុជាទទួលបានការអភិវឌ្ឍ លើវិស័យផ្សេងៗ ដូចជា កសិកម្ម ឧស្សាហកម្ម បានទូលាយជាងមុន

– បង្កើនទីផ្សារសម្រាប់នាំចេញវត្ថុធាតុដើម

– ជម្រុញឱ្យមានការអភិវឌ្ឍលើប្រពន្ធ័ហេដ្ឋារចនាសម្ព័ន្ធ បានប្រសើជាងមុន

- ផ្នែកសង្គម

– កម្ពុជាទទួលបាននូវកិច្ចសហប្រតិបត្តិការជាមួយប្រទេសក្នុងតំបន់ ក្នុងការថែរក្សាសន្តិភាព និងសន្តិសុខ ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និង អំពើកេរវកម្ម ។

– លើកម្ពស់ការផ្លាស់ប្តូរចំណេះដឹង សង្គមកិច្ច វប្បធម៌ និងប្រពៃណីទំនៀមទម្លាប់ ព្រមទាំងបច្ចេកទេស ពីបណ្តាប្រទេសក្នុងតំបន់អាស៊ាន ទាំងមូល ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត ...។

៣. នយោបាយអព្យាក្រឹត្យ បានផ្តល់ផលវិជ្ជមាន និង អវិជ្ជមានដល់កម្ពុជា ដូចជា ៖

- ផលវិជ្ជមាន

– កម្ពុជាក្លាយជាកោះសន្តិភាព ស្របពេលប្រទេសក្នុងតំបន់កំពុង តែមានសង្គ្រាម (សង្គ្រាមវៀតណាម និងឥទ្ធិពលនៃសង្គ្រាមត្រជាក់)

– កម្ពុជាបានទទួលជំនួយពីបរទេស ទាំងប្លុកកម្មុយនីសន្ត (សូវៀត) និង ប្លុកសេរី មានសហរដ្ឋអាមេរិកជាដើម ។

– ប្រទេសជាតិមានសុខសន្តិភាព ក្នុងរយៈពេល១៥ឆ្នាំ និងមានឱកាសក្នុងការអភិវឌ្ឍប្រទេស ឱ្យមានការរីកចម្រើន ។

– ប្រទេសជាតិមានសាមគ្គីជាតិ

– កម្ពុជាមានពេល សម្រាប់បណ្តុះធនធានមនុស្ស បានច្រើននិង មានធនធានគ្រប់គ្រាន់ សម្រាប់ការអភិវឌ្ឍនៅក្នុងប្រទេសទាំងមូល ។

– កម្ពុជាមានសេរីភាពក្នុងការធ្វើទំនាក់ទំនងការទូត ជាមួយប្រទេសដទៃនៅក្នុងពិភពលោក ដោយមិនប្រកាន់នូវមនោមនវិជ្ជានយោបាយ។

- ផលអវិជ្ជមាន

– ធ្វើឱ្យមានការជ្រៀតជ្រែករបស់បរទេស មកលើកម្ពុជា ពោលគឺប្រទេសថៃបានគាំទ្រសកម្មភាព របស់ខ្មែរសេរី ធ្វើការប្រឆាំងជាមួយនឹងរដ្ឋាភិបាល ។

– ថៃផ្តល់ដីឱ្យខ្មែរសេរី កសាងជំរំហាត់ទ័ព កសាងស្ថានីយ៍វិទ្យុផ្សាយសម្លេង ដើម្បីធ្វើយុទ្ធនាការប្រឆាំង របបសង្គមរាស្ត្រនិយម

– អាមេរិកគាំទ្រពួកស្តាំនិយម ដែលធ្វើឱ្យនយោបាយកម្ពុជាមានភាព ច្របូកច្របល់

– វត្តមានរបស់ពួកយៀកកុង និងវៀតណាមខាងជើងចូលមកកម្ពុជាកាន់តែច្រើន

– នយោបាយអព្យាក្រឹត្យត្រូវបានបញ្ចប់ ដោយកម្លាំងខាងក្នុងធ្វើរដ្ឋប្រហារទម្លាក់ សម្តេច នរោត្តម សីហនុ នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត ...។

៤. មូលហេតុដែលធ្វើឱ្យ របបកម្ពុជាប្រជាធិបតេយ្យដួលរលំមានដូចជា ៖

– ប្រជាជនលែងគាំទ្រ និងមានការស្អប់ខ្ពើម ចំពោះរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដោយសារតែ មានការគាបសង្កត់ បំបិតសិទ្ធិសេរីភាព ប្រជាជនធ្វើការងារធ្ងន់មិនមានអាហារហូបគ្រប់គ្រាន់ និង ខ្វះថ្នាំសម្រាប់ព្យាបាលជម្ងឺ ។

– វិសុទ្ធកម្ម និងការសម្រិតសម្រាំង បានធ្វើឱ្យមានការសម្លាប់រង្គាលលើប្រជាជនខ្មែរនេះដោយសារតែពួកខ្មែរក្រហមចង់សម្រាញ់យកមនុស្សដែលបរិសុទ្ធ ស្មោះត្រង់ជាមួយបដិវត្ត ដើម្បីធ្វើឱ្យការដឹកនាំរបស់គេទទួលបាននូវភាពជោគជ័យ។ ប៉ុន្តែការធ្វើវិសុទ្ធកម្មនេះមិនទទួលបាន នូវលទ្ធផលល្អទេ បែរជាធ្វើឱ្យប្រជាជនកាន់តែលែងគាំទ្រ។

– សង្គ្រាមជាមួយវៀតណាម បានធ្វើឱ្យកម្ពុជាប្រជាធិបតេយ្យកាន់តែ មានភាពទន់ខ្សោយ ដោសារវៀតណាមមានសម្ភារក្នុងការធ្វើសង្គ្រាមទំនើប មានប្រជាជនច្រើន និងមានយុទ្ធសាស្ត្រក្នុងការធ្វើសង្គ្រាម ។

– ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបង្កើតឡើងនៅថ្ងៃទី០២ ធ្នូ ឆ្នាំ ១៩៧៨ ដើម្បីផ្តួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត .....។

៥. ដំណើការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហម ៖

- វិស័យនយោបាយ

– លើកម្ពស់លទ្ធិប្រជាធិបតេយ្យ

– ធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ

– អនុវត្តគោលនយោបាយបង្រួបបង្រួមជាតិ

– ធ្វើកិច្ចសហប្រតិបត្តិការជាមួយបរទេស និងចាប់ផ្តើមបើកចំហទៅកាន់ពិភពលោក លើផ្នែកការទូត

– ស្វែងរកមធ្យោបាយ ដើម្បីចរចាជាមួយរដ្ឋាភិបាលត្រីភាគី

- វិស័យសេដ្ឋកិច្ច

– បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃ ដើម្បីជួយស្តារសេដ្ឋកិច្ចប្រជាជនកម្ពុជា

– ដោះស្រាយបញ្ហាសន្តិសុខស្បៀងជូនប្រជាជន

– បង្កើតសេដ្ឋកិច្ចទីផ្សារសេរី និង នាំឱ្យមានវិនិយោគទន់មកពីបរទេសចូលមកកម្ពុជា

– ពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ឱ្យមានខ្វែងខ្ចាត់ រួមទាំងអភិវឌ្ឍកំពង់ផែឱ្យរីកចម្រើន

– ជម្រុញឱ្យមានការវិនិយោគពីបរទេស ..។

- វិស័យសង្គម

– រំដោះប្រជាជនចេញពីរបបខ្មែរក្រហម

– ពង្រឹងសន្តិសុខ សន្តិភាព និងសុវត្ថិភាពជូនប្រជាជនកម្ពុជា ទាំងមូល

– ទប់ស្កាត់អំពើអសកម្មក្នុងសង្គម ការជួញដូរមនុស្ស អាវុធ គ្រឿងញៀន

– ផ្តល់សិទ្ធសេរីភាពឱ្យប្រជាជន រស់នៅបានស្មើគ្នាក្នុងសង្គម

– ចំពោះវស័យសុខាភិបាលគឺបើកឱ្យមន្ទីរពេទ្យដំណើរការឡើងវិញ និងប្រមូលផ្តុំគ្រូពេទ្យដើម្បីបម្រើការ ជូនប្រជាជនគ្រប់រូប

- វិស័យអប់រំ

– លើកម្ពស់វិស័យអប់រំ

– រៀបចំឱ្យមានដំណើការឡើងវិញ នូវសាលារៀន សាលាសិល្ប: វត្តអារាម និងលើកកម្ពស់ផ្នែកវប្បធម៌ខ្មែរ ឱ្យមានការរីកចម្រើន

– អនុវត្តតាមពាក្យស្លោក អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀន អ្នកអត់ចេះ

– ប្រមូលអ្នកចេះដឹង ដើម្បីរៀបចំឱ្យមានការដំណើការឡើងវិញ នូវស្ថាប័នរដ្ឋផ្សេងៗ

– បញ្ជូននិស្សិត និងធនធានមនុស្សខ្មែរឱ្យទៅរៀននៅបរទេស ដើម្បីពេលត្រលប់មកវិញ អាចជួយអភិវឌ្ឍប្រទេសឱ្យមានការរីកចម្រើន ។

– នៅមានចម្លើយត្រឹមត្រូវផ្សេងទៀត ...។

<u>ឯកសារពិគ្រោះ</u>

១. ក្រសួងអប់រំ យុវជន និងកីឡា. *ប្រវត្តិវិទ្យាថ្នាក់ទី១២.* ២០១២. បោះពុម្ពលោកទី២. គ្រឹះស្ថានបោះពុម្ព និងចែកចាយ

២. ក្រសួងអប់រំ យុវជន និងកីឡា. *ប្រវត្តិវិទ្យា សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ និងពិភពលោក.* ២០២០. ភ្នំពេញ

៣. ប៉ូ សុខា. *ប្រវត្តិសាស្ត្រពិភពលោកសតវត្សទី២០.* ២០១៨. ភ្នំពេញ

៤. ទី សុផល. *វិញ្ញាសាត្រៀមបាក់ឌុប.* ២០១៩. ភ្នំពេញ

៥. រ៉ង់ សុធារ៉ា និងណុប សុខា.*ប្រវត្តិសាស្ត្រខ្មែរ.*២០១៥. ភ្នំពេញ